តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia





# ចោទសួរ
# អំពើពុករលួយ





## ការស្ទង់មតិថ្នាក់ជាតិ
## ស្តីពីការយល់ឃើញរបស់យុវជន
## អំពីអំពើពុករលួយ និងសុចរិតភាពនៅប្រទេសកម្ពុជា

# អង្គការតម្លាភាពកម្ពុជា

ផ្ទះលេខ៩បេ ផ្លូវលេខ៤៦៦ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ១២៣០១ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ: (+៨៥៥) ២៣ ២១ ៤៤ ៣០ / ២៣ ២១ ៤២ ១១

info@ticambodia.org
www.ticambodia.org
www.facebook.com/ticambodia
www.twitter.com/ticambodia



© រូបថតក្របមុខ៖ KIN

មានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានដែលមាននៅក្នុងរបាយការណ៍នេះ។ ព័ត៌មានទាំងអស់ ត្រូវបានជឿថាមានភាពត្រឹមត្រូវ គិតត្រឹមខែកុម្ភៈ ឆ្នាំ ២០១៥។ ទោះយ៉ាងណាក៏ដោយ អង្គការតម្លាភាពកម្ពុជា មិនអាចទទួលខុសត្រូវចំពោះផលវិបាកផ្សេងៗដែលបណ្តាលមកពីការប្រើប្រាស់របាយការណ៍នេះក្នុងគោលបំណងផ្សេង ឬក្នុងបរិបទផ្សេងឡើយ។

© រក្សាសិទ្ធិគ្រប់យ៉ាង

ឯកសារនេះអាចត្រូវបានបោះផ្សាយបន្តក្នុងគោលបំណងបម្រើការអប់រំ និងមិនស្វែងរកប្រាក់ចំណេញ។ ការបោះផ្សាយបន្តក្នុងគោលដៅពាណិជ្ជកម្មមិនត្រូវបានអនុញ្ញាតឡើយ វៀរលែងតែមានការផ្តល់សិទ្ធិជាលាយលក្ខណ៍អក្សរពីអង្គការតម្លាភាពកម្ពុជា។

*អ្នកនិពន្ធទទួលខុសត្រូវទាំងស្រុង ចំពោះព័ត៌មាន និងទស្សនៈទាំងឡាយនៅក្នុងរបាយការណ៍នេះ។*


---


ការបោះពុម្ពរបាយការណ៍នេះអាចធ្វើទៅបានដោយសារការឧបត្ថម្ភគាំទ្រដ៏សប្បុរសពី**ក្រសួងការបរទេសនិងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី** (DFAT) និង**ទីភ្នាក់ងារស៊ុយអែតដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍អន្តរជាតិ** (SIDA)។ យ៉ាងណាក៏ដោយ ខ្លឹមសារនៃរបាយការណ៍នេះ មិនសុទ្ធតែឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ DFAT និង SIDAទេ។


Australian Aid

SWEDEN

អង្គការតម្លាភាពអន្តរជាតិ គឺជាអង្គការសង្គមស៊ីវិលអន្តរជាតិ ដែលដឹកនាំការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅលើពិភពលោក។ តាមរយៈអង្គការសាខាចំនួនជាង១០០ នៅទូទាំងពិភពលោក និងលេខាធិការដ្ឋានអន្តរជាតិនៅទីក្រុងប៊ែរឡាំងយើងលើកកម្ពស់ ការយល់ដឹងអំពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃអំពើពុករលួយ ហើយធ្វើការជាមួយដៃគូរដ្ឋាភិបាល ក្រុមហ៊ុនអាជីវកម្ម និងសង្គមស៊ីវិលដើម្បីបង្កើត និងអនុវត្តវិធានការ ដ៏មានប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយ។

អង្គការតម្លាភាពកម្ពុជាជាសាខាជាតិ ដែលទទួលស្គាល់ជាផ្លូវការដោយអង្គការតម្លាភាពអន្តរជាតិ។ គោលបំណងរបស់យើង គឺសហការរួមគ្នាជាមួយបុគ្គល និងស្ថាប័ននានានៅគ្រប់ជាន់ថ្នាក់ ដើម្បីលើកកម្ពស់សុចរិតភាព និងកាត់បន្ថយអំពើពុករលួយក្នុងប្រទេសកម្ពុជា។

អ្នកនិពន្ធ
Caitlin Graham
ជុនលី សិរីវិចិត្រ

# ក្រុមប្រឹក្សាយោបល់នៃការស្ទង់មតិយុវជនស្ដីពីសុចរិតភាព

| ឈ្មោះ | តួនាទី និងស្ថាប័ន |
|---|---|
| សិទ្ធ ហុង អៀង | ប្រធានសមាគមយុវជនខ្មែរ ( KYA ) |
| ចាន់ គន្ធា | អ្នកសម្របសម្រួលកម្មវិធីប្រចាំតំបន់នៅអង្គការ<br>Just Associates ( JASS ) |
| សុត និមល | មន្ត្រីកម្មវិធីជាតិស្ដីពីការអប់រំនៅអង្គការសហប្រជាជាតិ<br>វិទ្យាសាស្ត្រ និងវប្បធម៌ ( UNESCO ) |
| ជា គីមសុង | អ្នកឯកទេសគោលនយោបាយសង្គមនៅមូលនិធិកុមាររបស់<br>អង្គការសហប្រជាជាតិ ( UNICEF ) |
| លាង ឡូ | សាស្ត្រាចារ្យ នៅដេប៉ាតឺម៉ង់សង្គមកិច្ចវិទ្យា<br>នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ប៊ិច ពិសី | នាយកកម្មវិធីអង្គការតម្លាភាពកម្ពុជា |
| ស៊ឹង សុភា | មន្ត្រីសម្របសម្រួលការត្រួតពិនិត្យ និងការវាយតម្លៃ<br>នៃអង្គការតម្លាភាពកម្ពុជា |
| នូវ សុវត្ថា | ប្រធានកម្មវិធីនៃអង្គការតម្លាភាពកម្ពុជា |
| លី ពិជ័យ | មន្ត្រីកម្មវិធីនៃអង្គការតម្លាភាពកម្ពុជា |

# សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះទទួលបានការជួយជ្រោមជ្រែង និងឧបត្ថម្ភពីសំណាក់បុគ្គល និងស្ថាប័នជាច្រើន។ ក្រុមប្រឹក្សាយោបល់នៃការស្ទង់មតិរបស់យុវជនស្តីពីសុចរិតភាព បានផ្តល់នូវសេចក្តីណែនាំ និងគំនិតយោបល់ល្អៗ នៅគ្រប់ដំណាក់កាលនៃការសិក្សានេះ។ សូមថ្លែងអំណរគុណផងដែរ ដល់ដៃគូសហការស្រាវជ្រាវ ពោលគឺមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ (ជាពិសេស លោកបណ្ឌិត ហ៊ាន សុខុម) ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសយ៉ាងសំខាន់ទៅលើការធ្វើសំណាកសម្រាប់ការស្ទង់មតិ ការបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ និងការវិភាគទិន្នន័យជាបឋម។

គម្រោងសិក្សានេះ នឹងមិនអាចទទួលបានជោគជ័យនោះទេ ប្រសិនបើគ្មានការណែនាំ និងការគាំទ្រដែលផ្តល់ដោយមន្ត្រីគ្រប់គ្រងជាន់ខ្ពស់របស់អង្គការតម្លាភាពកម្ពុជា រួមមាន លោក ព្រាប កុល និងលោក ប៉ិច ពិសី នៅគ្រប់ដំណាក់កាល។ លោកទាំងពីរក៏បានចំណាយពេលវេលា ដើម្បីធ្វើការពិនិត្យ និងកែសម្រួលសេចក្តីព្រាងរបាយការណ៍នេះយ៉ាងម៉ត់ចត់។ សូមថ្លែងអំណរគុណផងដែរទៅដល់ កញ្ញា Elizabeth Johnson អតីតប្រធានគ្រប់គ្រងកម្មវិធីស្រាវជ្រាវ និងតស៊ូមតិចំពោះការចូលរួមចំណែកដ៏មានតម្លៃក្នុងការត្រួតពិនិត្យមើលលើគម្រោងនេះ ចាប់តាំងពីដំណាក់កាលចាប់ផ្តើមរហូតដល់ការធ្វើសេចក្តីព្រាងនៃរបាយការណ៍។ លោក ស៊ឹង សុភា បានផ្តល់នូវជំនួយដ៏សំខាន់ក្នុងការរៀបចំការស្ទង់មតិ សម្របសម្រួល និងធានានូវគុណភាពនៃការស្ទង់មតិនេះ។ កញ្ញាដួង លក្ខិណា និងកញ្ញាសង្វា ក្លងវីណា បានបកប្រែរបាយការណ៍ស្ទង់មតិនេះយ៉ាងស្ទាត់ជំនាញ។ លោក ប៉ូច ពិសាល និង កញ្ញា ឡាយ វង្សឃីម បានផ្តល់ការស្រាវជ្រាវ និងការគាំទ្រផ្នែករដ្ឋបាលដ៏សំខាន់ ខណៈដែលក្រុមការងារប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា បានជួយគម្រោងទាំងមូលឲ្យមានភាពរលូន ជាពិសេសគឺ នាយកប្រតិបត្តិការ លោក ស៊ុន ឡុង និងសហសេវិក លោក សៀង ម៉េងអូន និងលោកស្រី ជា សុគន្ធា។

សេចក្តីណែនាំ និងមតិកែលម្អដែលយើងទទួលបានពីលេខាធិការដ្ឋាន នៃអង្គការតម្លាភាពអន្តរជាតិ បានរួមចំណែកយ៉ាងសំខាន់ក្នុងការធានានូវភាពរឹងមាំ គុណភាព និងសុចរិតភាពក្នុងការស្រាវជ្រាវនេះ។ ជាពិសេស យើងសូមថ្លែងអំណរគុណ ដល់ កញ្ញា Ana Thayenthal សម្រាប់ដំបូន្មានដ៏មានប្រយោជន៍ និងទាន់ពេលវេលា និងចំពោះការពិនិត្យឡើងវិញនូវសេចក្តីព្រាងនៃរបាយការណ៍នេះ។

យើងក៏សូមសម្តែងនូវការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ដល់ក្រុមអ្នកជំនាញប្រមូលទិន្នន័យរបស់យើងដែលបានធ្វើការសម្ភាសនៅក្នុងភូមិចំនួន១៥០ នៅទូទាំងប្រទេស។ យើងក៏សូមអរគុណដល់ យុវជនចំនួន ១២០០នាក់ដែលបានលះបង់នូវពេលវេលារបស់ពួកគាត់ ចូលរួមក្នុងការស្ទង់មតិនេះ ក៏ដូចជាអ្នកដែលបានចូលរួមក្នុងការសម្ភាសសម្រាប់ករណីសិក្សា បន្ទាប់ពីការស្ទង់មតិបានបញ្ចប់ ។

យើងក៏សូមកោតសរសើរ និងទទួលស្គាល់នូវការរួមចំណែក ពីសំណាក់អ្នកកែសម្រួលរបាយការណ៍ទាំងភាសាអង់គ្លេស និងភាសាខ្មែរ អ្នកបកប្រែ និងអ្នករចនាក្រាហ្វិក ដែលបានធ្វើការរួមគ្នា (ក៏ដូចជាបុគ្គលិករបស់យើង) ក្នុងការរៀបចំរបាយការណ៍សម្រាប់ការបោះពុម្ព។

ជាចុងក្រោយ ការសិក្សានេះ អាចធ្វើឡើងទៅបាន ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីម្ចាស់ជំនួយរបស់យើង រួមមាន ក្រសួងការបរទេសនិងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី (DFAT) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA)។ ប្រសិនបើគ្មានការឧបត្ថម្ភពីស្ថាប័នទាំងនេះទេ យើងនឹងមិនអាចធ្វើការស្ទង់មតិនេះ ឬផ្សព្វផ្សាយរបកគំហើញនៃការស្ទង់មតិនេះបានទេ។

# មាតិកា


អារម្ភកថា៖ សុទិដ្ឋិនិយមនិងឧបសគ្គ ..... ១០

បុព្វកថា៖ យុវជននៅលើផ្លូវបំបែក ..... ១២

សេចក្តីសង្ខេប ..... ១៤
- របកគំហើញសំខាន់ៗ ..... ១៤
- អនុសាសន៍គន្លឹះ ..... ១៧

ការស្ទង់មតិយុវជនស្តីពីសុចរិតភាព ..... ១៩
- សេចក្តីផ្តើម ..... ២០
- វិធីសាស្ត្រ ..... ២១
- របកគំហើញសំខាន់ៗ ..... ២៤
  - គោលគំនិតនិងជំនឿ ..... ២៤
  - គុណតម្លៃនិងឥរិយាបថ ..... ២៦
    - ករណីសិក្សា៖ ការជូនអំណោយក្នុងវិស័យថែទាំសុខភាពសាធារណៈ ..... ២៧
    - ការយល់ដឹងពីអំពើពុករលួយ ..... ២៨
  - បទពិសោធន៍នៃអំពើពុករលួយ ..... ៣១
  - សុចរិតភាពស្តែងចេញតាមរយៈឥរិយាបថ ..... ៣១
    - ករណីសិក្សា៖ ការមិនអនុវត្តច្បាប់ដើម្បីទទួលបានប័ណ្ណបើកបរ ..... ៣៤
    - ករណីសិក្សា៖ ការទិញការងារ ..... ៣៦
- ឥទ្ធិពលទៅលើយុវជន ..... ៣៦
- ការពិភាក្សា ..... ៤០
- សេចក្តីសន្និដ្ឋាននិងអនុសាសន៍ ..... ៤១

ឧបសម្ព័ន្ធ១៖ កម្រងសំណួរ ..... ៤៥

## បុព្វកថា

# សុទិដ្ឋិនិយម និង ឧបសគ្គ

ក្នុងចំណោមយុវជននិងមនុស្សវ័យក្មេងទាំង ១២០០ នាក់ដែលត្រូវបានធ្វើការស្ទង់មតិសម្រាប់របាយការណ៍នេះ សឹងតែគ្រប់គ្នាយល់ស្របថា អំពើពុករលួយជាឧបសគ្គធំមួយដល់ការអភិវឌ្ឍជាតិ។ ភាគច្រើននៃយុវជនទាំងនោះបានអះអាងថា ជំនាន់ពួកគេអាចដើរតួយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ហើយជាងពីរភាគបីក្នុងចំណោមនោះនិយាយថា ពួកគេមានឆន្ទៈនឹងរាយការណ៍អំពីករណីពុករលួយទៅថ្ងៃមុខ។

យុវជនទាំងនោះក៏បានរាយការណ៍ឲ្យដឹងដែរអំពីកម្រិតខ្ពស់នៃបទពិសោធន៍ឆ្លងកាត់អំពើពុករលួយ ដោយក្នុងនោះមានចំនួនក្រាស់ក្រែលដែរដែលនិយាយថា ពួកគេមានចេតនានឹងចូលរួមប្រព្រឹត្តអំពើពុករលួយដើម្បីជាផលចំណេញដល់ខ្លួន គ្រួសារ និងមិត្តភ័ក្ត្ររបស់គេ។ របកគំហើញទាំងនេះត្រូវបានដាក់បង្ហាញនិងវិភាគយ៉ាងពិស្តារនៅក្នុងទំព័របន្ទាប់ៗនេះ។ សាធារណៈជនដែលបានសិក្សាអំពីទិន្នន័យនេះនឹងទទួលបាននូវព័ត៌មានច្រើនសម្រាប់យកទៅត្រិះរិះពិចារណា។ ជាក្តីសង្ឃឹមរបស់យើង របាយការណ៍នេះនឹងនាំមកនូវសកម្មភាពគាំទ្រផ្សេងៗថែមទៀត។

តាមទស្សនៈរបស់យើង អ្វីដែលសំខាន់ជាងគេគឺនៅត្រង់ថា បើទោះជាអ្នកដែលបានធ្វើអង្កេតនេះ កំពុងរស់នៅក្នុងប្រទេសមួយក្នុងចំណោមប្រទេសដែលមានអំពើពុករលួយខ្ពស់ក្តី - ដូចការសិក្សា ជាច្រើនទៀតបានរកឃើញកន្លងមក - សុទិដ្ឋិនិយម និង ឧត្តមគតិនិយមកំពុងតែរីកធំធាត់។

ការសិក្សានេះផ្តល់នូវភស្តុតាងថែមទៀតថា ជំនាន់មួយដែលពោរពេញដោយសុទិដ្ឋិជាងគេក្នុង ប្រវត្តិសាស្ត្របច្ចុប្បន្នរបស់កម្ពុជាកំពុងតែលេចចេញជារូបរាងហើយ។ ការស្រាវជ្រាវរបស់យើងក៏រកឃើញដែរថា យុវជនជំនាន់នេះត្រៀមជាស្រេចក្នុងការប្រឈមជាមួយនឹងឧបសគ្គនានាដើម្បីចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសរបស់គេ។ ភាពព្រងើយកន្តើយមិនរវីរវល់ហាក់ដូចជាលែងមានវត្តមានទៀតហើយ រីឯភាពស្ទាក់ស្ទើរក៏កំពុងតែចុះថមថយទៅៗដែរ។

ក៏ប៉ុន្តែ ពួកយុវជននៅតែជួបប្រទះនឹងឧបសគ្គច្រើនសន្ធឹកសន្ធាប់នៅឡើយ រួមមានកង្វះការអប់រំ។ ភាគច្រើននៃពួកគេមិនទាំងដឹងផងថាកម្ពុជាមានច្បាប់ប្រឆាំងអំពើពុករលួយ។ ភាពក្រីក្រ ជាពិសេសនៅតាមទីជនបទ ក៏ជាកត្តាមួយរំលឹកប្រាប់គេថា ភាពរស់រានផ្នែកសេដ្ឋកិច្ចគឺជាអាទិភាពរបស់ពួកគេ។ លើសពីនោះ ការបំពេញកាតព្វកិច្ចគ្រួសារ និងចំណងគ្រួសារជាការលំបាក បើមិនមានការលះបង់ឧត្តមគតិផ្ទាល់ខ្លួន ស្របពេលដែលកង្វះឱកាសការងារមានកម្រៃសមរម្យ ទំនងជាកំពុងក្លាយជាកត្តាជម្រុញឲ្យយុវជន ប្រព្រឹត្តអំពើសូកប៉ាន់ដើម្បីទទួលបានការងារធ្វើ។

អំពើពុករលួយរីកធំធាត់ក្នុងបរិស្ថានបែបនេះ ប៉ុន្តែយុវជនជំនាន់ថ្មីនេះក៏ទទួលស្គាល់ដែរថា អំពើពុករលួយក៏កំពុងតែចិញ្ចឹមស្ថានភាពបច្ចុប្បន្នដែលពួកគេកំពុងស្ថិតនៅដែរ។ ជារឿងសំខាន់ក្នុងការរម្លឹកម្តងទៀតថា ពីរភាគបីនៃអ្នកដែលត្រូវបានធ្វើការអង្កេត មានចេតនានឹងរាយការណ៍អំពីករណីពុករលួយ។ អ្នកដែលមិនទទួលយកនូវគំនិតរបស់យុវជនទាំងនេះ អាចនឹងនាំឲ្យមាននូវគម្លាតសង្គមកាន់តែរីកធំថែមទៀត។ រីឯអ្នកឯទៀតដែលត្រៀមខ្លួនហុចដៃជួយ ពួកគេអាចជួយដល់ការលេចរូបរាងឡើងរបស់អ្នកជំនាន់ថ្មី "ក្រោយសម័យខ្មែរក្រហម" មួយនេះក្នុងដំណើរឆ្ពោះទៅមុខ។

យើងសូមស្វាគមន៍គំនិតផ្តួចផ្តើមនានារបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីលុបបំបាត់អំពើពុករលួយ ដែលរួមមានការបង្កើតក្របខណ្ឌច្បាប់ អង្គភាពប្រឆាំងអំពើពុករលួយ ព្រមទាំងសកម្មភាពនានាដែលបាន ធ្វើកន្លងមកក្នុងជំហានឆ្ពោះទៅសម្រេចឲ្យបាននូវសង្គមមួយកាន់តែមានតម្លាភាពផ្អែកលើនីតិរដ្ឋ។ គំនិតផ្តួចផ្តើមរបស់ ឯកឧត្តម ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងការលុបបំបាត់អំពើពុករលួយក្នុងដំណើរការចុះបញ្ជីធុរកិច្ចថ្មីតាមរយៈការបង្កើតប្រព័ន្ធចុះបញ្ជីតាមអ៊ីនធឺណិត ជាឧទាហរណ៍មួយក្នុងជំហានដែលអាចនាំមកនូវផលប្រយោជន៍វែងឆ្ងាយ ដោយវាអាចជួយទាក់ទាញបាននូវការវិនិយោគបរទេសច្រើនថែមទៀត[1]។

បណ្តាដៃគូអភិវឌ្ឍន៍ សមាគមធុរកិច្ច គណបក្សនយោបាយ និងសហគមន៍អ្នកការទូត ក៏កំពុងតែដើរតួនាទី មួយក្នុងការតស៊ូមតិឲ្យមានការកាត់បន្ថយអំពើពុករលួយនៅកម្ពុជាដែរ។

1 George Styllis and Kang Sothear, "Commerce Minister Promotes Investment". *The Cambodia Daily. 8 October 2014.*
https://www.cambodiadaily.com/business/commerce-minister-promotes-investment-69399/

យើងទាំងអស់បានដឹងហើយថា ដំណើរការទៅមុខមានភាពស្មុគ្រស្មាញច្រើនស្រទាប់ណាស់ ហើយវាត្រូវការកំណែទម្រង់បែបនវានុវត្តន៍មួយ អមដោយសកម្មភាព និងការអប់រំជាប្រចាំនៅគ្រប់ស្រទាប់ សង្គមទាំងអស់។ ការសិក្សាថ្មីៗនេះបានឲ្យដឹងថាយុវជនមានចំណេះដឹងកម្រិតទាបមែនទែនស្តីអំពីគ្រឹះរបស់រដ្ឋាភិបាល និង ស្ថាប័នរដ្ឋនានា។ ដូច្នេះ វាទាមទារឲ្យមានសកម្មភាពជាសមោហភាព និងដោយរន្ថើន ទើបមានការផ្លាស់ប្តូរបាន។

នៅអង្គការតម្លាភាពកម្ពុជា យើងជឿថា ការបង្កើតឲ្យមានផែនការសកម្មភាពជាតិមួយ - ដែលក្នុងនោះត្រូវមានគោលវាស់វែង ក្របខណ្ឌពេលវេលា និងគោលដៅច្បាស់លាស់ - ដើម្បីដោះស្រាយបញ្ហាសុចរិតភាពក្នុងចំណោមយុវជន ជាជំហានមួយធំឆ្ពោះទៅមុខ។ ការបង្កើតឲ្យមានកម្មវិធីសិក្សាច្បាស់លាស់មួយស្តីពីការប្រឆាំងអំពើពុករលួយ និងបញ្ចូលកម្មវិធីទាំងនេះទៅក្នុងគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធអប់រំ ក៏នឹងជួយដល់ការសម្រេចគោលបំណងយូរអង្វែងរបស់រដ្ឋាភិបាលដែរ។

ការធានាថាប្រព័ន្ធអប់រំជាតិ - ដែលជាកត្តាមានឥទ្ធិពលមួយក្នុងចំណោមឥទ្ធិពលធំៗមកលើសុចរិតភាព ដែលត្រូវលើកឡើងដោយអ្នកទាំងឡាយដែលបានចូលរួមក្នុងការអង្កេតនេះ - គ្មានអំពើពុករលួយ ដោយបង្កើន បៀវត្សរបស់គ្រូ កែលំអដំណើរការរើសបុគ្គលិក និងកែទម្រង់ប្រព័ន្ធគ្រប់គ្រងសាលារៀន ជាជំហានធំមួយទៀតក្នុងដំណើរឆ្ពោះទៅមុខដែរ។ ដំណើរការនេះបានចាប់ផ្តើមរួចទៅហើយ។

យើងមានសុទិដ្ឋិថាប្រទេសកម្ពុជាស្ថិតនៅលើគន្លងត្រូវមួយឆ្ពោះទៅលុបបំបាត់អំពើពុករលួយ ហើយការ អង្កេតនេះផ្តល់ភស្តុតាងថា គេអាចបង្កើនសន្ទុះរបស់វាថែមទៀតបាន។ ទិន្នន័យទាំងឡាយនៅក្នុងការសិក្សានេះ ចង្អុលបង្ហាញថា យុវជនកាន់តែមានភាពស្វាហាប់ចង់ចូលរួមក្នុងការជំនះរបារឧបសគ្គដល់ការអភិវឌ្ឍ - ហើយ តាមពិតទៅ ពួកគេប្រហែលជាកត្តាគន្លឹះផងក្នុងបេសកកម្មនេះ។



ព្រាប កុល
នាយកប្រតិបត្តិ
អង្គការតម្លាភាពកម្ពុជា

## អារម្ភកថា

# យុវជននៅលើផ្លូវបំបែក

កម្ពុជាមានប្រជាជនវ័យក្មេងជាងគេនៅតំបន់អាស៊ីអាគ្នេយ៍[1] ដោយក្នុងនោះជាង៣០ ភាគរយនៃ ពលរដ្ឋទាំងអស់មានអាយុពី១៥ ទៅ ៣០ ឆ្នាំ[2] ។ ការពិតស្តីពីប្រជាសាស្ត្រមួយនេះមានអត្ថន័យសំខាន់ពិសេស ដោយសារប្រវត្តិវិវាទដែលកម្ពុជាធ្លាប់ឆ្លងកាត់កន្លងមក។ ការដែល ៦៥ ភាគរយនៃប្រជាជនមានអាយុ ក្រោម ៣០ ឆ្នាំ មានន័យថា ភាគច្រើននៃប្រជាជនបានកើតក្រោយរបបខ្មែរក្រហម ហើយមួយភាគធំក្នុងនោះមិនបានឆ្លងកាត់ផ្ទាល់ នូវបទពិសោធន៍ដ៏អាក្រក់បំផុតនៃវិវាទដែលកើតមានក្រោយពីការផ្តួលរំលំរបប ប៉ុល ពត ទេ។ ជាផលវិបាក គម្លាតរវាងជំនាន់ត្រូវបានគេមើលឃើញថាជាការដាច់ចេញពីគ្នារវាងជំនាន់[3] ដែលញ៉ាំងឲ្យមានភាពចាំបាច់ក្នុងការសិក្សានិងវិភាគទស្សនៈទាន និងបទពិសោធន៍របស់យុវជន ដោយឡែកពីអ្នកជំនាន់មុន។

យុវជនជួបប្រទះនូវឧបសគ្គជាច្រើននៅកម្ពុជា រួមមានភាពគ្មានការងារធ្វើ កង្វះការអប់រំ របាំងរារាំងមិនឲ្យចូលរួមក្នុងជីវភាពនយោបាយ។ កង្វល់ធំរបស់ពួកគេគឺកង្វះការងារធ្វើ។ អត្រាភាពគ្មានការងារធ្វើនៅមានខ្ពស់។ នៅភ្នំពេញអត្រាភាពគ្មានការងារធ្វើសម្រាប់អ្នកមានអាយុ១៥ ទៅ ២៤ ឆ្នាំ មានដល់ទៅ ២០ ភាគរយ[4] ។ ការទទួលបានការអប់រំនៅមិនទាន់មានភាពស្មើគ្នា ហើយថ្លៃចំណាយ រួមមានចំណាយក្រៅផ្លូវការ នៅតែជាឧបសគ្គដល់ប្រជាជនជាច្រើននាក់នៅឡើយ[5]។ មានតែប្រហែលពាក់កណ្តាលនៃពលរដ្ឋកម្ពុជាអាយុក្រោម ៣០ ឆ្នាំប៉ុណ្ណោះដែលរៀនចប់បឋមសិក្សា យោងតាម Asian Barometer Survey[6] ។ ជិត ៤៤ ភាគរយ បានរៀនចប់អនុវិទ្យាល័យ ហើយ ៨ ភាគរយ រៀនចប់កម្រិតវិទ្យាល័យ ដែលជាលទ្ធផលនាំឲ្យមាននូវការ ញែកខណ្ឌដាច់ពីគ្នាស្រឡះក្នុងផ្នែកអប់រំសម្រាប់ក្រុមពលរដ្ឋមួយនេះ[7]។

វាជាតថនិយមដែលថា យុវជនតំណាងឲ្យអនាគត ក៏ប៉ុន្តែក្នុងស្ថានភាពដែលមានការញែកខណ្ឌដាច់ពីគ្នាស្រឡះរវាងជំនាន់មុននឹងជំនាន់ក្រោយបែបនេះនៅកម្ពុជា មានទាំងឱកាសធំៗសម្រាប់ការប្រែប្រួលជាវិជ្ជមានឆាប់រហ័ស និងហានិភ័យបណ្តាលមកពីការខកចិត្តកាន់តែខ្លាំងឡើង ដោយសារមួយផ្នែក មកពីវិសមភាពក្នុងការទទួលបានការអប់រំនិងការងារ។ ដើម្បីជានាឲ្យមានការប្រែប្រួលជាវិជ្ជមាន យុវជនត្រូវ តែមានលទ្ធភាពពេញលេញដើម្បីចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ ប៉ុន្តែដើម្បីអាចធ្វើទៅបាន ពួកគេត្រូវតែជ្រួតជ្រាប អំពីថាតើត្រូវធ្វើយ៉ាងដូចម្តេចជាវិជ្ជមាន។

មានតែ ៣៦ ភាគរយនៃយុវជនប៉ុណ្ណោះដែលដឹងថាតើលទ្ធិប្រជាធិបតេយ្យ ឬ សភាជាតិ ជាអ្វី ហើយមានតែ ៤០ ភាគរយប៉ុណ្ណោះដែលដឹងថាក្រុមប្រឹក្សាឃុំសង្កាត់ជាអ្វី នេះបើយោងតាមការស្រាវជ្រាវមួយរបស់ United Nations Development Programme និង BBC Media Action[8]។ ទោះជាការសិក្សានោះ ផ្តល់ទឡ្ហីករណ៍ថាយុវជនមានចំណាប់អារម្មណ៍ច្រើនជាងមុនក្នុងការចូលរួមក្នុងជីវភាពសង្គម និងលើកកម្ពស់ឲ្យមានអនាគតប្រកប

### ទិដ្ឋភាពសង្ខេបនៃប្រជាសាស្ត្រកម្ពុជា

| | |
|---|---|
| ៦៥.៣% អាយុក្រោម ៣០ ឆ្នាំ[1] | យុវជន (អាយុពី ១៥ ទៅ ៣០ ឆ្នាំ) មាន ៣៣% នៃចំនួនប្រជាជនសរុប[2] |

ប្រភពព័ត៌មាន:

1 United Nations Development Programme, About Cambodia, Available at: http://www.kh.undp.org/content/cambodia/en/home/countryinfo/( Accessed: February 2015 ).

2 Royal Government of Cambodia, National Policy on Cambodian Youth Development, June 2011, p.1

---

1 BBC Media Action and UNDP, *Reaching and Engaging the Cambodian Youth on Issues of Civic Participation*, February 2014, pg.10

2 Royal Government of Cambodia, *National Policy on Cambodian Youth Development*, June 2011, p.1

3 United Nations Country Team, *Situation Analysis of Youth in Cambodia*, May 2009, p iii

4 Ibid. pg.2

5 Ibid. pg.4

6 UNDP, *Youth and Democratic Citizenship in East and South-East Asia*, August 2014, pg.7

7 Ibid.

8 BBC Media Action and UNDP, *Reaching and Engaging the Cambodian Youth on Issues of Civic Participation*, February 2014, pg.20

ដោយវឌ្ឍនភាព និងសមភាពមួយសម្រាប់ប្រទេសខ្លួនក្តី ទិន្នន័យបានបង្ហាញថា ពួកគេមិនទទួលបាននូវការអប់រំចាំបាច់នានាដែលអាចជួយពួកគេឲ្យសម្រេចគោលបំណងនោះបាននៅឡើយទេ។

នៅក្នុងការអង្កេតមួយលើ ១២ ប្រទេសក្នុងតំបន់អាស៊ីបូព៌ា និង អាស៊ីអាគ្នេយ៍ ប្រជាជនកម្ពុជាអាយុ ១៨-៣០ ឆ្នាំ ត្រូវបានគេរកឃើញថាជាអ្នកតាមដានព័ត៌មាននយោបាយក្នុងបរិមាណតិចជាងគេ[9]។ លើសពីនោះ នៅក្នុងប្រទេស ប្រជាជនក្នុងក្រុមវ័យនេះនិយាយថាពួកគេតាមដានព័ត៌មាននយោបាយតិចជាងពលរដ្ឋវ័យចាស់ៗទៅទៀត។ មានតែ ២៦ ភាគរយនៃប្រជាជនកម្ពុជាទេក្នុងរង្វង់វ័យនេះដែលតាមដានព័ត៌មាននយោបាយ ប្រៀបធៀបទៅនឹង ៤១ ភាគរយនៃអ្នកមានអាយុពី ៣០ ទៅ ៥៩ ឆ្នាំ និង ៥៤ ភាគរយនៃអ្នកមានអាយុ ៦០ ឆ្នាំនិង ចាស់ជាងនេះដែលតាមដានព័ត៌មាននយោបាយ[10]។ ប៉ុន្តែ ការគាំទ្រគណបក្សនយោបាយមានកម្រិតដល់ទៅ ៩០ ភាគរយឯណោះក្នុងចំណោមយុវជន[11] ហើយ ២៥ ភាគរយនិយាយថាពួកគេធ្លាប់ប្រឡូកក្នុងសកម្មភាពនយោបាយតាមរូបភាពផ្សេងៗគ្នា[12]។

ការសិក្សាទូទាំងប្រទេសមួយកាលពីពេលថ្មីៗនេះអំពីបទពិសោធន៍ ឥរិយាបថ និងអាកប្បកិរិយារបស់ យុវជនកម្ពុជានៅមានកម្រិតនៅឡើយ។ ប៉ុន្តែ ទិន្នន័យដែលមានបានបង្ហាញថា ក្រុមពលរដ្ឋនេះមានចំណាប់ អារម្មណ៍នយោបាយ ប៉ុន្តែពួកគេខ្វះព័ត៌មាននិងធនធានចាំបាច់នានាដើម្បីចូលរួមឲ្យបានពេញលេញក្នុងសកម្មភាពសង្គមនានា។ បន្ថែមលើនេះ ភាពគ្មានការងារធ្វើ កង្វះការអប់រំសិក្សា និងសម្ពាធផ្សេងៗទៀត មានន័យថា តម្រូវការរស់រានប្រចាំថ្ងៃ និង សន្តិសុខផ្នែកហិរញ្ញវត្ថុ តែងតែជាបញ្ហាមានសម្ពាធខ្លាំងជាងគេដែល ពួកគេជួបប្រទះហើយត្រូវដោះស្រាយមុន។

មុននឹងមានការស្ទង់មតិនេះ មិនទាន់មានការស្រាវជ្រាវណាមួយត្រូវបានធ្វើឡើងជាក់លាក់ដើម្បីស្វាបស្ទង់មើលអំពីផលប៉ះពាល់នៃអំពើពុករលួយមកលើពលរដ្ឋវ័យក្មេងនៅកម្ពុជាទេ។ ទោះជាអំពើពុករលួយមាន ទំនាក់ទំនងទៅនឹងភាពក្រីក្រ ភាពមានការងារធ្វើ វិស័យអប់រំ និងការចូលរួមនយោបាយក្តី ការស្ទង់មតិនេះជាការស្ទង់មតិលើកដំបូងដែលផ្តោតទៅលើអំពើពុករលួយ ដើម្បីស្វែងយល់អំពីផលប៉ះពាល់របស់វាមកលើយុវជនកម្ពុជា។

---

9 UNDP, *Youth and Democratic Citizenship in East and South-East Asia*, August 2014, pg.22

10 UNDP, *Youth and Democratic Citizenship in East and South-East Asia*, August 2014, pg.22

11 Ibid. pg.56

12 Ibid. pg.59

# សេចក្តីសង្ខេប

របាយការណ៍ ករណីសិក្សានានា និងសូចនាករអន្តរជាតិជាច្រើន បានបង្ហាញជាបន្តបន្ទាប់ អំពីអំពើពុករលួយកម្រិតខ្ពស់មួយនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា សមាគមធុរកិច្ច អង្គការសង្គមស៊ីវិល និងសមាជិក របស់សហគមន៍អ្នកផ្តល់ជំនួយ ទាំងអស់គ្នាសុទ្ធតែបាន សម្តែងមតិ និងអនុវត្តន៍នូវកិច្ចផ្តួចផ្តើមប្រឆាំងអំពើពុករលួយមួយចំនួនដែលគួរឲ្យស្ងើចសរសើរ។ ប៉ុន្តែ ដើម្បីសម្រេចបានជោគជ័យ ក្នុងការលើកកម្ពស់សុចរិតភាព និងទប់ស្កាត់អំពើពុករលួយ ការធ្វើការជាមួយយុវជនឲ្យបានកាន់តែច្រើន គឺជារឿងមួយដែលចាំបាច់។

នៅកម្ពុជា ៦៥ ភាគរយនៃប្រជាជន មានអាយុក្រោម ៣០ ឆ្នាំ ហើយជាង ៣០ ភាគរយនៃពលរដ្ឋត្រូវបានគេចាត់ទុកថាជាយុវជន។ ការស្ទង់មតិយុវជនស្តីពីសុចរិតភាពនេះធ្វើឡើងដើម្បីស្វែងយល់និងប៉ាន់ប្រមាណ ឥរិយាបថ និងការយល់ឃើញអំពីសុចរិតភាព និង អំពើពុករលួយក្នុងចំណោមក្រុមប្រជាជនដ៏សំខាន់នេះ។ ការស្ទង់មតិតាមរូបភាពតំណាងថ្នាក់ជាតិ លើកដំបូងគេនៅប្រទេសកម្ពុជានេះ បានសម្ភាសយុវជន ១២០០ នាក់អាយុពី១៥ ដល់៣០ឆ្នាំនៅទូទាំងប្រទេស។ លទ្ធផលនៃការអង្កេតនេះអាចផ្តល់ភស្តុតាងនិងទិន្នន័យ សម្រាប់អង្គភាពរដ្ឋាភិបាល និង អង្គការនានា ដែលមានបំណងស្វែងយល់ឲ្យកាន់តែស៊ីជម្រៅអំពីយុវជន និង ដើម្បីកំណត់វិស័យ សំខាន់ៗសម្រាប់តម្រង់ទិសកិច្ចផ្តួចផ្តើមសកម្មភាពប្រឆាំងអំពើពុករលួយ។

# របកគំហើញសំខាន់ៗ

ភាគច្រើនលើសលុប ពោលគឺ ៩៩ ភាគរយនៃយុវជន ១២០០ នាក់ដែលត្រូវបានធ្វើការស្ទង់មតិ យល់ស្របថា អំពើពុករលួយជាឧបសគ្គ ធំមួយដល់ការអភិវឌ្ឍជាតិ។ ការយល់ដឹងអំពីផលវិបាកនានាដោយសារតែកង្វះសុចរិតភាព[1] ក៏មានការសាយភាយទូលំទូលាយដែរ។ ក៏ប៉ុន្តែ បើទោះជាមានការជឿជាក់ខ្លាំងថាសុចរិតភាពបុគ្គល មានសារៈសំខាន់ដល់សង្គមក្តី យុវជនក៏ត្រៀមខ្លួនលះបង់សុចរិតភាព ដើម្បីទាញផលចំណេញ សម្រាប់ខ្លួនគេ គ្រួសារ និង មិត្តរបស់គេដែរ។ យុវជនក៏បានរាយការណ៍ឲ្យដឹងផងដែរអំពីបទពិសោធន៍ផ្ទាល់ ឆ្លងកាត់អំពើពុករលួយ ក្នុងកម្រិតខ្ពស់មួយ។ យ៉ាងណាក្តី ពួកគេក៏បង្ហាញចេតនា ខ្លាំងដែរក្នុងការចូលរួមប្រឆាំងអំពើពុករលួយនោះ។ ខាងក្រោមនេះយើងសូមសង្ខេបរបកគំហើញសំខាន់ៗ មួយចំនួនដែលជាលទ្ធផលនៃការស្ទង់មតិនេះ ជាប្រាំពីរផ្នែកទៅតាមលំហូរ របស់ការស្ទង់មតិ៖ ការយល់ជាទ្រឹស្តី, ឥរិយាបថអំពីអាកប្បកិរិយាជាក់លាក់មួយចំនួន, ការយល់ដឹងជាទូទៅអំពីបញ្ហាពុករលួយ, ទស្សនៈអំពីស្ថាប័នសាធារណៈ, បទពិសោធន៍ឆ្លងកាត់អំពើពុករលួយ, ឥទ្ធិពលមកលើការយល់ដឹងអំពីសុចរិតភាព, និងការប្តេជ្ញាចិត្ត ប្រឆាំងអំពើពុករលួយ។

## ការយល់ជាទ្រឹស្តីអំពីសុចរិតភាព និង ជំនឿពាក់ព័ន្ធផ្សេងៗ

ក្នុងកម្រិតជាទ្រឹស្តី "សុចរិតភាព" ត្រូវបានការទទួលស្គាល់ខ្លាំងក្នុងចំណោមអ្នកដែលត្រូវបាន ស្ទង់មតិ ប៉ុន្តែគេអាចកត់សម្គាល់ឃើញ នូវភាពរារែកក្នុងស្មារតីភ្លាមកាលណាពាក្យនេះត្រូវបានគេចាត់ទុកថាវា បញ្ច្រាសទៅនឹងផលប្រយោជន៍បុគ្គលឬគ្រួសាររបស់គេ៖

- ៩៨ ភាគរយនៃអ្នកដែលត្រូវបានអង្កេត ចាត់ទុកថាមនុស្សមានសុចរិតភាពគឺជាអ្នកដែលមិនរំលោភច្បាប់ (ក្នុងកាលៈទេសៈ ណាក៏ដោយ)។
- ប៉ុន្តែ ១៩ ភាគរយនៃអ្នកដែលត្រូវបានអង្កេតចាត់ទុកថាមនុស្សមានសុចរិតភាពក៏នៅតែអាចរំលោភច្បាប់បានដែរ បើសិនជាការធ្វើ ដូច្នោះនាំមកនូវផលចំណេញដល់គ្រួសារឬមិត្តភ័ក្តិរបស់គេ។ កម្រិតនៃអំពើពុករលួយក៏ជះឥទ្ធិពលទៅលើជំនឿអំពីសុចរិតភាព ដែរ៖ ៣៤ ភាគរយនៃអ្នកដែល ត្រូវបានអង្កេតជឿថា មនុស្សសុចរិតម្នាក់អាចចូលរួមក្នុងអំពើពុករលួយ កាលណាទឹកប្រាក់ដែល ពាក់ព័ន្ធមានចំនួនស្តួចស្តើង។ ការពិចារណាអំពីផលប៉ះពាល់ដោយផ្ទាល់របស់អំពើពុករលួយក៏ជា កត្តាមួយដែរ៖ ៤០ ភាគរយ នៃអ្នកដែលត្រូវបានអង្កេតបានរាយការណ៍ឲ្យដឹងថា មនុស្សសុចរិត ម្នាក់អាចចូលរួមប្រព្រឹត្តអំពើពុករលួយក្នុងទម្រង់ផ្សេងៗ ដែលត្រូវបានគេប្រើប្រាស់ទូលំទូលាយ សម្រាប់ដោះស្រាយការលំបាករបស់បុគ្គល។
- មួយភាគបួននៃអ្នកដែលត្រូវបានអង្កេតមើលឃើញភាពប្រទាក់ប្រទងគ្នារវាងអំពើពុករលួយ និងភាពជោគជ័យបុគ្គល ដោយយល់ស្រប ថាអ្នកទាំងឡាយដែលមានចេតនាចូលរួមប្រព្រឹត្តអំពើពុករលួយ ទំនងជានឹងមានជោគជ័យជាងអ្នកដែលមិនប្រព្រឹត្តដូច្នោះ។

1 "សុចរិតភាព" ត្រូវបានឲ្យនិយមន័យថាជាភាពស្មោះត្រង់។ សម្រាប់សេចក្តីពន្យល់ សូមមើលទំព័រ ២១

## ប្រាក់សគុណ និង ទម្រង់ផ្សេងៗនៃអំពើពុករលួយដែល "អាចទទួលយកបាន"

យុវជនយល់ឃើញថា ទង្វើពុករលួយខ្លះ រួមទាំងប្រាក់សគុណដើម្បីបានការងារ ជាទង្វើអាចទទួលយកបាន ហើយពួកគេក៏ត្រៀមខ្លួននឹងចូលរួមប្រព្រឹត្តដូច្នោះដែរ៖

- ជិត ៦០ ភាគរយនៃយុវជនសុខចិត្តបង់ប្រាក់សគុណពី ១០ ទៅ ២០ ភាគរយនៃបៀវត្សរ៍របស់ខ្លួន ទៅឲ្យអ្នកដែលអាចជួយរកការងារឲ្យរូបគេបាន។
- ពាក់កណ្តាលនៃអ្នកដែលត្រូវបានអង្កេតជឿថា ការបង់លុយថែមក្រៅផ្លូវការទៅឲ្យវេជ្ជបណ្ឌិត ឬ គិលានុបដ្ឋាកយិកាដើម្បីទទួលបានការព្យាបាលថៃទាំល្អ ជាទង្វើអាចទទួលយកបាន។
- ៣១ ភាគរយ យល់ស្របថាវាជាប្រការអាចទទួលយកបានក្នុងការឲ្យសាច់ញាតិជួយ ជាជាងឆ្លងកាត់ដំណើរការជ្រើសរើសជាផ្លូវការ ដើម្បីចូលរៀននៅសាលាល្អមួយ ឬ បានចូលធ្វើការនៅក្រុមហ៊ុនល្អមួយ។
- ២៤ ភាគរយនៃអ្នកដែលត្រូវបានស្ទង់មតិគិតថា ការឲ្យលុយបន្ថែមក្រៅផ្លូវការទៅឲ្យមន្ត្រីសាធារណៈ ដើម្បីពន្លឿនការចុះបញ្ជីយានយន្ត ជារឿងមួយអាចទទួលយកបាន។

## យល់ដឹងអំពីបញ្ហា តែអត់ដឹងអំពីដំណោះស្រាយ

យុវជនយល់ថាអំពើពុករលួយជាមេរោគស៊ីរូងសង្គមមួយ ប៉ុន្តែពួកគេដឹងតិចតួចណាស់អំពីអង្គភាពប្រឆាំងអំពើពុករលួយ និងកិច្ចផ្តួចផ្តើមនានាដើម្បីលើកស្ទួយសុចរិតភាព៖

- ៩៩ ភាគរយនៃអ្នកដែលត្រូវបានអង្កេតឯកភាពថា អំពើពុករលួយជាឧបសគ្គដ៏ធំមួយដល់ការអភិវឌ្ឍជាតិ។
- ៧១ ភាគរយរាយការណ៍ឲ្យដឹងថាពួកគេមិនទទួលបាន ឬទទួលបានតិចតួចមែនទែននូវព័ត៌មានអំពីវិធាន និងបញ្ញត្តិរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់អំពើពុករលួយ និងលើកកម្ពស់សុចរិតភាព។
- មានតែ ៣២ ភាគរយប៉ុណ្ណោះនិយាយថាពួកគេទទួលបានចំណេះដឹងអំពីសុចរិតភាព និងអំពើពុករលួយតាមរយៈសាលារៀនសាធារណៈ (នៅគ្រប់កម្រិត)។

## យោបល់អំពីកម្រិតសុចរិតភាពរបស់ស្ថាប័នសាធារណៈ

ទំនុកចិត្តរបស់យុវជនទៅលើសេវាកម្មសាធារណៈ និងស្ថាប័នរដ្ឋ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានកម្រិតទាបគួរសម៖

- ៤៦ ភាគរយនៃអ្នកដែលត្រូវបានស្ទង់មតិជឿថា នគរបាលនិងកងកម្លាំងសន្តិសុខពុករលួយណាស់ ឬក៏ពុករលួយគួរសមដែរ។
- ៣៨ ភាគរយគិតថារដ្ឋបាលថ្នាក់ជាតិពុករលួយណាស់ ឬក៏ពុករលួយគួរសមដែរ។
- ៣៧ ភាគរយនិយាយថារដ្ឋបាលថ្នាក់មូលដ្ឋានរបស់គេពុករលួយណាស់ ឬក៏ពុករលួយគួរសមដែរ។

## ធ្លាប់ឆ្លងកាត់បទពិសោធន៍អំពើពុករលួយ

យុវជនមួយភាគធំធ្លាប់ពើបប្រទះអំពើពុករលួយ ក្នុងពេលស្វែងរកប្រើប្រាស់សេវាសាធារណៈ។

- ជិត ៧០ ភាគរយនៃយុវជនដែលធ្លាប់ពើបប្រទះជាមួយនគរបាល ១២ ខែមុននឹងមានការអង្កេតនេះ បានឆ្លងកាត់បទពិសោធន៍អំពើពុករលួយ។
- យុវជនម្នាក់ក្នុងចំណោមពីរនាក់ធ្លាប់ឆ្លងកាត់អំពើពុករលួយក្នុងការសុំឯកសារ ឬ ប័ណ្ណអនុញ្ញាត និងក្នុងពេលប្រលងនានានៅសាលារៀន។
- ជិត ៣០ ភាគរយនៃយុវជនធ្លាប់ឆ្លងកាត់អំពើពុករលួយក្នុងពេលទទួលការថែទាំសុខភាព។

## ឥទ្ធិពលលើសុចរិតភាព

គ្រួសារនិងប្រព័ន្ធផ្សព្វផ្សាយជាប្រភពចម្បងដែលយុវជនទទួលបានព័ត៌មានអំពីសុចរិតភាព និងកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយ។ ក្នុងចំណោមប្រភពប្រព័ន្ធផ្សព្វផ្សាយ វិទ្យុនិងទូរទស្សន៍មានឥទ្ធិពលជាងគេ។

- គ្រួសារជំៗ សាលារៀន និងប្រព័ន្ធផ្សព្វផ្សាយជាមូលដ្ឋានចម្បងនៃប្រភពព័ត៌មាន និងមាន ឥទ្ធិពលខ្លាំងខាងផ្នែកសុចរិតភាពមកលើយុវជន។
- ១៤ ភាគរយនៃយុវជនដែលត្រូវបានធ្វើអង្កេតនិយាយថា អាកប្បកិរិយារបស់មេដឹកនាំ - រួមមានមេដឹកនាំនយោបាយ មេដឹកនាំផ្នែកស្មារតី និងមេដឹកនាំសាសនា - មិនបានផ្តល់គំរូល្អអំពីសុចរិតភាពទេ។

## ការប្តេជ្ញាចិត្តប្រឆាំងអំពើពុករលួយ

អ្នកឆ្លើយបានបង្ហាញនូវចេតនាខ្លាំងក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ  សម្តែងឲ្យឃើញនូវភាពជឿជាក់ថាពួកគេមានអំណាចដើរតួនាទីសំខាន់មួយ ជាបុគ្គលក្តី និងជាក្រុមក្តី។

- យុវជនក្នុងចំនួនច្រើនលើសលុបជឿថាពួកគេអាចដើរតួសំខាន់មួយក្នុងការប្រយុទ្ធប្រឆាំងអំពើ ពុករលួយ។
- លើសពីនេះទៅទៀត ៦៧ ភាគរយនិយាយថាពួកគេមានចេតនានឹងរាយការណ៍ពីអំពើពុករលួយ។

# អនុសាសន៍គន្លឹះ

## សម្រាប់រដ្ឋាភិបាល៖

### ក្របខណ្ឌច្បាប់៖

- បង្កើតបរិយាកាសអំណោយផលមួយសម្រាប់យុវជនរាយការណ៍អំពីអំពើពុករលួយ ដោយកែលំអ យន្តការ ឧបករណ៍ និងធនធាននានាដែលអនុញ្ញាតពួកគេចូលរួមបានក្នុងការប្រឆាំងអំពើពុករលួយ។ ក្នុងនោះគួរមានការអនុម័តច្បាប់ស្តីពី"ការការពារអ្នករាយការណ៍" អំពីអំពើពុករលួយ។

### ការអប់រំ ការទប់ស្កាត់ និងការលើកកម្ពស់ការយល់ដឹង និងប្រយុទ្ធប្រឆាំងអំពើពុករលួយ៖

- ក្រសួងអប់រំ យុវជន និងកីឡា គួររៀបចំឲ្យមានកម្មវិធីសិក្សាជាក់លាក់ស្តីពីការប្រឆាំងអំពើពុករលួយ ហើយបញ្ជ្រាបកម្មវិធីទាំងនេះទៅក្នុងគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធអប់រំ ពីបឋមសិក្សា រហូតដល់សាកលវិទ្យាល័យ។
- ធានាឲ្យបានថាប្រព័ន្ធអប់រំជាតិ(ដែលជាកត្តាមួយក្នុងចំណោមកត្តាមានឥទ្ធិពលខ្លាំងជាងគេលើ សុចរិតភាពដូចដែលអ្នកឆ្លើយបានលើកឡើង) គ្មានភាពពុករលួយ ដោយតម្លើងបៀវត្សរ៍ជូនគ្រូបង្រៀន កែលំអដំណើរការជ្រើសរើសបុគ្គលិក និងកែទម្រង់ប្រព័ន្ធគ្រប់គ្រងសាលារៀន។
- ធ្វើអាទិភាពកិច្ចខិតខំកែលំអវិស័យសាធារណៈសំខាន់ៗមួយចំនួនដែលយុវជនអាចនឹងប្រឈម មុខនឹងអំពើពុករលួយ ជាពិសេសផ្នែកអនុវត្តន៍ច្បាប់ (ពិសេសនគរបាលចរាចរ) ផ្នែកសុខាភិបាល និងភ្នាក់ងាររដ្ឋផ្សេងៗទៀតដែលទទួលខុសត្រូវក្នុងការផ្តល់ឯកសារ ដូចជាសំបុត្រកំណើត អត្តសញ្ញាណបណ្ណ និងបណ្ណបើកបរ។
- បង្កើតកម្មវិធីជាតិមួយដើម្បីលើកកម្ពស់គំរូសុចរិតភាពសម្រាប់យុវជន ឧទាហរណ៍ តាមរយៈកម្មវិធីរង្វាន់សុចរិតសាធារណៈ និងកិច្ចផ្តួចផ្តើមបណ្តុះបណ្តាលយុវជនជាមេដឹកនាំ។
- កែលំអយុទ្ធសាស្ត្រនានាដើម្បីឲ្យយុវជនបានជ្រាបអំពីច្បាប់ប្រឆាំងអំពើពុករលួយ និងបញ្ញត្តិពាក់ព័ន្ធនានា។ ជាពិសេស គួរបង្កើនធនធានបន្ថែមទៀតសម្រាប់ការធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ពិសេសវិទ្យុនិងទូរទស្សន៍ និងតាមបណ្តាញប្រព័ន្ធ ផ្សព្វផ្សាយសង្គមផងដែរ។
- លើកទឹកចិត្ត បង្កើត និងលើកស្ទួយបណ្តាញយុវជន និងផ្តល់អំណាចទៅដល់ពួកគេ ក្នុងការលើកកម្ពស់សុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។

## សម្រាប់ស្ថាប័នអប់រំជាន់ខ្ពស់ វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍

- បន្ថែមលើការផ្តល់ជំនាញនិងចំណេះដឹងចាំបាច់ដល់និស្សិត ស្ថាប័នអប់រំជាន់ខ្ពស់ និងសាលាអាជីពឯទៀតគួរផ្តោតផងដែរទៅលើការបង្រៀនហ្វឹកហាត់និស្សិតអំពីភាពចាំបាច់ក្នុងការលើកស្ទួយសុចរិតភាព និង ក្រមសីលធម៌ក្នុងអាជីពរបស់គេទៅថ្ងៃអនាគត។
- សមាជិកវិស័យឯកជន និងសង្គមស៊ីវិល គួរធានាឲ្យបានថា ដំណើរការជ្រើសរើសបុគ្គលិកទាំងអស់ ត្រូវមានតម្លាភាព គ្មានការសូកប៉ាន់ គ្មានការបង់ប្រាក់សគុណ ឬក៏ក្នុងទម្រង់ផ្សេងទៀតនៃអំពើពុករលួយទេ។
- អង្គការយុវជន ទាំងថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន គួរពិចារណាផ្តួចផ្តើមយុទ្ធនាការសំដៅផ្លាស់ប្តូរ ផ្នត់គំនិតដែលកំពុងមានក្នុងចំណោមយុវជនអំពីអំពើពុករលួយ ឲ្យចាត់ទុកការប្រព្រឹត្តពុករលួយ គ្រប់បែប ក្នុងទិដ្ឋភាពតូចក្តីធំក្តី ថាជាការអនុវត្តខុសច្បាប់ដែលត្រូវតែចៀសវាងឲ្យខានតែបាន។
- អ្នកផ្តល់ជំនួយ ទាំងទ្វេភាគីនិងពហុភាគី គួរធ្វើអាទិភាពវិធានការប្រឆាំងអំពើពុករលួយ និងការប្រឡូកយុវជនក្នុងកម្មវិធីយុទ្ធសាស្ត្ររបស់គេ ហើយផ្តល់ធនធានបន្ថែមទៀតសម្រាប់អង្គការ សង្គមស៊ីវិលក្នុងការបង្កើនការទាមទារពីសំណាក់ប្រជាពលរដ្ឋនិងយុវជន ឲ្យបានសង្គមមួយគ្មានអំពើពុករលួយ។

# ការស្ទង់មតិ
# យុវជនស្តីពីសុចរិតភាព

## តំបន់សិក្សា



# សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលកម្ពុជា មិនត្រឹមតែបានចាត់ទុកថាអំពើពុករលួយជាឧបសគ្គមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងស្ថិរភាពសង្គមនោះទេ ប៉ុន្តែក៏បានទទួលស្គាល់ថាវាជាមូលហេតុចម្បងមួយនៃភាពក្រីក្រផងដែរ[1] ។ ប៉ុន្តែរបាយការណ៍ ករណីសិក្សា និងសូចនាករអន្តរជាតិនានា នៅតែបង្ហាញជាបន្តបន្ទាប់ពីកម្រិតដ៏ខ្ពស់នៃអំពើពុករលួយទ្រង់ទ្រាយធំ អំពើពុករលួយទ្រង់ទ្រាយតូច ក៏ដូចជាអំពើពុករលួយផ្នែកនយោបាយ នៅក្នុងប្រទេសកម្ពុជា។ សន្ទស្សន៍ការយល់ឃើញអំពើពុករលួយរបស់ អង្គការតម្លាភាពអន្តរជាតិ (CPI) បានចាត់ថ្នាក់ប្រទេសកម្ពុជានៅលេខរៀងទី១៥៦ ក្នុងចំណោមរបស់ប្រទេស១៧៥ នៅឆ្នាំ២០១៤[2] ។ ប្រទេសកម្ពុជា និងប្រទេសភូមា ត្រូវបានគេយល់ឃើញថា ជាប្រទេសដែលមានអំពើពុករលួយកម្រិតខ្ពស់បំផុតក្នុងចំណោម១១ប្រទេសសមាជិកនៃសមាគម ប្រជាជាតិអាស៊ីអាគ្នេយ៍ក្នុងឆ្នាំ២០១៤ ខណៈដែលប្រទេសកម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេសមួយក្នុងចំណោមប្រទេសពុករលួយបំផុតទាំង២០នៅលើពិភពលោក[3] ។

រាជរដ្ឋាភិបាលកម្ពុជា បន្តផ្តល់អាទិភាពដល់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅក្នុងដំណាក់កាលទីបីនៃ យុទ្ធសាស្រ្តចតុកោណរបស់ខ្លួន[4] ។ សម្រាប់ប៉ុន្មានឆ្នាំចុងក្រោយនេះរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវសកម្មភាពប្រឆាំងនឹងអំពើពុករលួយជាច្រើន ដោយបានបង្ហាញពីការវិវត្តឆ្ពោះទៅរកការលើកកម្ពស់ការផ្សព្វផ្សាយសុចរិតភាពនៅក្នុងប្រទេស។ ក៏ប៉ុន្តែដោយសារប្រជាជនប្រមាណជាង ៦៥ភាគរយ មានអាយុក្រោម៣០ឆ្នាំ[5] យុវជនត្រូវតែជាអាទិភាពចម្បងក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើពុករលួយ។ យុវជនអាចប្រឈមមុខនឹងអំពើពុករលួយច្រើន ដោយសារពួកគេមានចំនួនច្រើន មានតួនាទីសម្បូរបែប និងមានការទាក់ទងជាប្រចាំជាមួយនឹងរដ្ឋ និងសង្គម[6] ។

ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ទទួលស្គាល់ចំណុចនេះ ដោយបានលើកឡើងថាការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ប្រឆាំងអំពើពុករលួយ និងផលវិបាកនៃអំពើពុករលួយ នឹងត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា និងកម្មវិធីផ្សេងៗរបស់សាលាគ្រប់កម្រិតទាំងអស់។ គោលបំណងរបស់ផែនការនេះបញ្ជាក់យ៉ាងច្បាស់ ពោលគឺ "ចង់ឲ្យយុវជនដែលជាទំពាំងស្នងឬស្សី ប្រកាន់ខ្ជាប់នូវគំនិតមិនចង់ប្រព្រឹត្ត និងស្អប់ខ្ពើមអំពើពុករលួយ"[7] ។

សកម្មភាពទាំងអស់នេះ ជាទង្វើគួរឲ្យស្វាគមន៍ និងកោតសរសើរ។ ការផ្តល់ការអប់រំដល់យុវជន និងការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់ពួកគាត់ ជាការចាំបាច់ដើម្បីធានាថាគោលដៅនៃការលុបបំបាត់អំពើពុករលួយនឹងត្រូវសម្រេចបាន និងទទួលបានការពង្រឹងទៅមុខទៀត ។ យ៉ាងណាក៏ដោយ កិច្ចផ្តួចផ្តើមរយៈពេលខ្លី ត្រូវធ្វើឡើងបន្ថែមទៀតដើម្បីជួយដល់យុវជនដែលកំពុងព្យាយាមប្រកាន់យកនូវសុចរិតភាពក្នុងប្រព័ន្ធបច្ចុប្បន្ន បន្ថែមពីលើការធ្វើការជាមួយយុវជន ដើម្បីធានាបាននូវការផ្លាស់ប្តូរឥរិយាបទក្នុងរយៈពេលវែង។ ការបោះឆ្នោតឆ្នាំ២០១៣ បានបង្ហាញយ៉ាងច្បាស់ថា យើងមិនអាចមើលស្រាលសមត្ថភាពរបស់យុវជនក្នុងការដើរតួនាទីជាភ្នាក់ងារនៃបម្លាស់ ប្តូរសង្គមឡើយ៖ យុវជន មានចំនួនមួយភាគបីនៃអ្នកដែលមានសិទ្ធិបោះឆ្នោត[8] ។

មានអង្គការសង្គមស៊ីវិលជាច្រើនដែលអនុវត្តកម្មវិធីទាក់ទងនឹងផ្តល់ការអប់រំ និងផ្តល់អំណាចដល់យុវជន ធ្វើយ៉ាងណាឲ្យពួកគេចូលរួមក្នុងដំណើរការនយោបាយកាន់តែច្រើនជាងមុន។ អង្គការតម្លាភាពកម្ពុជា បានរៀបចំការបោះជំរុំយុវជនប្រចាំឆ្នាំ ដើម្បីអប់រំយុវជនអំពីសុចរិតភាព និងផលខូចខាតនៃអំពើពុករលួយមកលើសង្គម[9] ។ ការបោះជំរុំយុវជនត្រូវបានប្រារព្ធធ្វើឡើងជាទៀងទាត់នៅតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា ដែលក្នុងនោះ អ្នកដឹកនាំវ័យក្មេងៗទទួលបានបណ្តុះបណ្តាល ក្នុងការដឹកនាំកិច្ចផ្តួចផ្តើមទាក់ទងនឹងយុវជននានា ដើម្បីអប់រំបន្តដល់យុវជនផ្សេងទៀតអំពីសុចរិតភាព តម្លាភាព និងការប្រឆាំងអំពើពុករលួយនេះ។ ជាលទ្ធផលនៃការបោះជំរុំយុវជនទាំងនេះ គម្រោងដែលដឹកនាំដោយយុវជនចំនួន២៦ត្រូវបានអនុវត្ត ដោយមានការគាំទ្រហិរញ្ញវត្ថុពី អង្គការ

---

1 ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ "ផែនការយុទ្ធសាស្រ្ត៥ឆ្នាំ ២០១១-២០១៥"
2 អង្គការតម្លាភាពអន្តរជាតិ, សន្ទស្សន៍ការយល់ឃើញអំពើពុករលួយឆ្នាំ ២០១៤
3 Ibid.
4 សម្តេចហ៊ុនសែននាយករដ្ឋមន្ត្រី យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី III បាន នៅខែកញ្ញាឆ្នាំ២០១៣
5 វិទ្យាស្ថានជាតិស្ថិតិ, អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនិងការវាស់ស្ទង់មតិប្រជាសាស្រ្តនិងសុខភាព, ការស្ទង់មតិប្រជាសាស្រ្តនិងសុខភាពកម្ពុជា២០១០, ខែកញ្ញាឆ្នាំ២០១១, ទំព័រទី១០
6 អង្គការតម្លាភាពអន្តរជាតិ,យុវជននិងអំពើពុករលួយ, ឯកសារ៦, ២០០៩, ទំព័រទី២
7 ក្រសួងផែនការ, ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨, ខែកញ្ញាឆ្នាំ ២០១៤ ទំព័រទី១៨០
8 http://www.necelect.org.kh/nec_khmer/
9 http://ticambodia.org/index.php/whatwedo/event/international-youth-camp-2015

តម្លាភាពកម្ពុជា[10] ។ អង្គការតម្លាភាពកម្ពុជា ក៏បានផ្ដល់នូវការបណ្ដុះបណ្ដាលដល់អ្នកកាសែតវ័យក្មេង និងអង្គការដៃគូមិនមែនរដ្ឋាភិបាលដទៃទៀតដើម្បីបន្តផ្ដល់ការបណ្ដុះបណ្ដាលដល់សហគមន៍ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ។

ការស្ទង់មតិសុចរិតភាពយុវជនកម្ពុជា នឹងជួយដល់អង្គការតម្លាភាពកម្ពុជាធ្វើឲ្យកាន់តែប្រសើរឡើងនូវអភិក្រមក្នុងការធ្វើការជាមួយយុវជន។ ការស្ទង់មតិនេះក៏អាចយកទៅប្រើប្រាស់ផងដែរ ដើម្បីគាំទ្រដល់អង្គការ និងស្ថាប័នរដ្ឋាភិបាលនានា ក្នុងការស្វែងយល់ឲ្យកាន់តែស៊ីជម្រៅអំពីការយល់ដឹងរបស់យុវជន ដើម្បីកំណត់ឲ្យបានច្បាស់នូវ កិច្ចផ្តួចផ្តើមប្រយុទ្ធប្រឆាំងអំពើពុករលួយ។

# វិធីសាស្រ្ត

គោលគំនិតនៃការស្ទង់មតិយុវជនស្តីពីសុចរិតភាពនេះ គឺផ្អែកលើនិយមន័យនៃពាក្យសុចរិតភាពរបស់អង្គការតម្លាភាពអន្តរជាតិ។ សុចរិតភាពត្រូវបានកំណត់ថាជា "អាកប្បកិរិយានិងសកម្មភាព ស្របជាមួយនឹងគោលការណ៍និងបទដ្ឋានសីលធម៌និងក្រមសីលធម៌... ដែលបង្កើតជាឧបសគ្គរាំង អំពើពុករលួយ"។ ការស្ទង់មតិយុវជនស្តីពីសុចរិតភាពនេះ គឺជាឧបករណ៍វិនិច្ឆ័យមួយ ដែលមានគោលបំណងប្រមូលព័ត៌មានស្តីពីទស្សនៈមតិយោបល់បទពិសោធន៍និងអាកប្បកិរិយារបស់យុវជននៅពេលប្រឈមមុខនឹងអំពើពុករលួយ។ ការស្ទង់មតិបែបនេះ ត្រូវបានអនុវត្តលើកដំបូងដោយអង្គការតម្លាភាពអន្តរជាតិនៅប្រទេសវៀតណាម ("ឆ្ពោះទៅរកតម្លាភាព") នៅឆ្នាំ២០១១។ ចាប់តាំងពីពេលនោះមកការស្ទង់មតិបែបនេះត្រូវបានធ្វើឡើង នៅក្នុងបណ្ដាប្រទេសផ្សេងៗជាច្រើនទៀតក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

ការស្ទង់មតិនេះត្រូវបានរៀបចំឡើង ដើម្បីស្វែងយល់អំពីគោលគំនិត និងជំនឿរបស់យុវជនអំពី អំពើពុករលួយ តម្លៃ និងឥរិយាបថ ក៏ដូចជាការយល់ដឹង បទពិសោធន៍ផ្ទាល់ខ្លួន និងឥរិយាបថរបស់ពួកគេនៅពេលប្រឈមមុខនឹងអំពើពុករលួយ។ ការស្ទង់មតិនេះមានបំណងកំណត់ផងដែរនូវគន្លឹះសំខាន់ៗ ដែលអាចជះឥទ្ធិពលលើគុណតម្លៃនិងឥរិយាបថរបស់យុវជន និងដើម្បីវាស់ស្ទង់កម្រិតនៃការប្តេជ្ញាចិត្តរបស់ពួកគេ ក្នុងការតតាំង និងរាយការណ៍អំពើពុករលួយ។

## សំណាក

ការស្ទង់មតិរបស់យុវជនស្តីពីសុចរិតភាពនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើសំណាកតំណាងថ្នាក់ជាតិ។ ការសិក្សានេះបានស្ទង់មតិយុវជន ដែលមានអាយុចាប់ពី ១៥ដល់៣០ឆ្នាំ ចំនួន១២០០នាក់ ក្នុងខេត្តចំនួនប្រាំបី។ វិធីសាស្រ្តជ្រើសរើសសំណាកបួនដំណាក់កាលត្រូវបានប្រើប្រាស់ដើម្បីធានាថា សំណាកនៃការសិក្សានេះអាចតំណាងថ្នាក់ជាតិបាន។ ជាលទ្ធផលនៃការប្រើប្រាស់វិធីសាស្រ្តទាញយកសំណាកបែបនេះ ខេត្តចំនួនប្រាំបីត្រូវបានជ្រើសរើសជាសំណាកបឋម ភូមិ១៥០ត្រូវបានជ្រើសរើសជាសំណាកបន្ទាប់ ហើយគ្រួសារ៨នៅក្នុងភូមិនីមួយៗត្រូវបានជ្រើសរើសជាសំណាកនៃដំណាក់កាលទីបី និងយុវជនម្នាក់មានអាយុ ពី១៥ ទៅ៣០ឆ្នាំ នៅក្នុងគ្រួសារនីមួយៗត្រូវបានជ្រើសរើសជាសំណាកដំណាក់កាលទីបួន។

នៅដំណាក់កាលដំបូងនៃការធ្វើសំណាក អ្នកសិក្សាធ្វើការពិចារណាទៅលើខេត្តទាំង២៥។ ខេត្តនីមួយៗត្រូវបានដាក់លេខកូដទៅតាមទីតាំងភូមិសាស្រ្ត ហើយចំនួនយុវជនត្រូវបានប្រមូលមកតម្រៀបគ្នាដោយផ្អែកទៅលើជំរឿនចន្លោះប្រជាជនម្ពុជាឆ្នាំ២០១៣។ វិធីសាស្រ្តប្រូបាបបីលីតេសមាមាត្រទៅនឹងទំហំ និងវិធីសាស្រ្តចាប់ផ្ដើមដោយចៃដន្យត្រូវបានប្រើប្រាស់ ដើម្បីជ្រើសខេត្តទាំងប្រាំបីនោះ។

ដំណាក់កាលទីពីរនៃសំណាកត្រូវបានធ្វើឡើងនៅតាមភូមិ។ ដោយប្រើវិធីសាស្រ្តប្រូបាបបីលីតេសមាមាត្រទៅនឹងទំហំ ភូមិចំនួន១៨ត្រូវបានជ្រើសរើសដោយចៃដន្យពីក្នុងខេត្តដែលបានជ្រើសយកក្នុងតំបន់៤ផ្សេងគ្នា ក៏ដូចជារាជធានីភ្នំពេញ។ ភូមិចំនួន១៥០ត្រូវបានជ្រើសរើសពីខេត្តទាំងប្រាំបី។

សំណាកនៅដំណាក់កាលទីបី ធ្វើឡើងនៅកម្រិតគ្រួសារ[11]។ ដើម្បីធ្វើការសម្ភាស ៨គ្រួសារ ក្នុងរាល់ ១ភូមិ សំណាកគ្រួសារមួយក្រុម

10 TI Cambodia Annual Report 2013, Section 4.3, pg.28

11 គ្រួសារ ត្រូវបានគេឲ្យនិយមន័យថា ជាមនុស្សមួយក្រុមដែលបច្ចុប្បន្នញុំាបាយជាមួយគ្នាក្រោមដំបូលផ្ទះតែមួយ។ យោងតាមនិយមន័យនេះ គ្រួសារមិនរួមបញ្ចូលបុគ្គលទាំងឡាយណា ដែលរស់នៅកន្លែងផ្សេងយូរជាង៦ខែនោះទេ។ នៅក្នុងគ្រួសារដែលមានពហុរចនាសម្ព័ន្ធ គ្រួសារនោះត្រូវបានបែងចែកជាសំណាកដោយឡែក។

ត្រូវបានជ្រើសរើសឡើងតាមរយៈ វិធីសាស្ត្រធ្វើសំណាកជាប្រព័ន្ធបែបលីនីអ៊ែរ (Linear, systematic sampling methodology)។ ដំណាក់កាលចុងក្រោយ ធ្វើឡើងនៅកម្រិតអ្នកឆ្លើយតប។ អ្នកឆ្លើយតប ត្រូវតែមានអាយុចន្លោះពី ១៥ ដល់ ៣០ឆ្នាំ ហើយចំនួនអ្នកឆ្លើយតបភេទប្រុស និងភេទស្រី ដែលត្រូវជ្រើសរើសធ្វើសម្ភាសន៍ មានចំនួនស្មើៗគ្នាពីភូមិនីមួយៗ។

## កម្រងសំណួរ

ដូចនៅក្នុងការស្ទង់មតិសាកល្បងនៅប្រទេសវៀតណាម កម្រងសំណួរផ្តោតទៅលើទិដ្ឋភាពបួននៃសុចរិតភាពៈ

- សីលធម៌និងក្រមសីលធម៌៖ គោលគំនិតនៃការយល់ដឹងអំពីបទដ្ឋាននៃឥរិយាបថ
- គោលការណ៍៖ សមត្ថភាពក្នុងការបែងចែករវាងខុសនិងត្រូវ
- ការគោរពច្បាប់៖ កម្រិតនៃការអនុលោមតាមក្របខ័ណ្ឌច្បាប់
- ការតតាំងនឹងអំពើពុករលួយ៖ ឆន្ទៈក្នុងការប្រឆាំងនឹងអំពើពុករលួយ

ការស្ទង់មតិនេះរួមបញ្ចូលសំណួរ ដែលសួរអំពីគុណតម្លៃ និងការយល់ឃើញក៏ដូចជាបទពិសោធន៍ និងឥរិយាបទរបស់យុវជន។ សំណួរលើគុណតម្លៃ និងការយល់ឃើញ ចង់ពិនិត្យទៅលើការយល់ដឹងទូទៅពីគោលគំនិតនៃសុចរិតភាព។ សំណួរស្តីពីបទពិសោធន៍ និងឥរិយាបថមានបំណងវាស់ពីកម្រិតនៃការអនុវត្តគោលគំនិតនេះដាក់ស្តែងនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកឆ្លើយសំនួរ។
បើទោះបីជាផ្នែកលើកម្រងសំណួរដែលត្រូវបានប្រើប្រាស់នៅក្នុងការស្ទង់មតិនៅប្រទេសវៀតណាមក្តី មានការកែប្រែខ្លះចំពោះកម្រងសំនួរដែលធ្វើឡើងនៅក្នុងប្រទេសកម្ពុជា។ ការកែប្រែនេះធ្វើឡើង បន្ទាប់ពីមានការធ្វើតេស្តសាកល្បងមួយ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤។ លទ្ធផលនៃការធ្វើតេស្តនេះត្រូវបានប្រើប្រាស់ ដើម្បីកែលម្អកម្រងសំណួរឲ្យសមស្របទៅនឹងបរិបទវប្បធម៌កម្ពុជា។ ភាគច្រើននៃការផ្លាស់ប្តូរនេះ គឺជាលទ្ធផលនៃការបកប្រែពីភាសាអង់គ្លេសមកភាសាខ្មែរមួយចំនួន ដើម្បីចាប់យកអត្ថន័យឲ្យល្អបំផុតឲ្យត្រូវនឹងទស្សនៈ និងបរិបទខ្មែរ។ លើសពីនេះទៀតដោយសារការស្ទង់មតិនេះធ្វើឡើងតាមរយៈការសួរដោយផ្ទាល់មាត់ (ដូចដែលបានធ្វើនៅក្នុងប្រទេសវៀតណាម) ដូច្នេះប្រយោគវែងៗ និងឃ្លាស្មុគស្មាញមួយចំនួនត្រូវបានបង្រួមឲ្យខ្លី និងសាមញ្ញដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការសន្ទនា។ បន្ទាប់ពីការពិភាក្សា និងពិគ្រោះយោបល់ជាបន្តបន្ទាប់មកនិយមន័យនៃពាក្យ "សុចរិតភាព" ដែលយកមកប្រើនៅក្នុងការស្ទង់មតិនៅក្នុងប្រទេសកម្ពុជាត្រូវបានប្តូរទៅជា "ភាពស្មោះត្រង់" ពីព្រោះវាមានអត្ថន័យច្បាស់លាស់ជាង និងអាចចាប់យកនូវខ្លឹមសារនៃគំនិតបានល្អបំផុតទាំងនៅក្នុងទីក្រុង និងទីជនបទក្នុងបរិបទនៃជីវភាពប្រចាំថ្ងៃ។

ការប្រមូល និងការបញ្ចូលទិន្នន័យ៖ ការស្ទង់មតិនេះត្រូវបានធ្វើឡើងជាង ២០ថ្ងៃ ក្នុងខែឧសភា និងខែមិថុនា ឆ្នាំ ២០១៤ ដោយអ្នកប្រមូលទិន្នន័យមានបទពិសោធន៍ចំនួន២០នាក់ និងប្រធានក្រុមប្រាំនាក់ ដែលជ្រើសរើសដោយអង្គការតម្លាភាពកម្ពុជា។ មុនពេលចុះប្រមូលទិន្នន័យពួកគាត់បានទទួលការបណ្តុះបណ្តាលរយៈពេលបីថ្ងៃពីទីប្រឹក្សាស្រាវជ្រាវដែលមកពី មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ និងបុគ្គលិករបស់អង្គការតម្លាភាពកម្ពុជា។ អ្នកប្រមូលទិន្នន័យត្រូវបានបែងចែកជាប្រាំក្រុម ដែលមួយក្រុមមានសមាជិកបួននាក់ និងប្រធានម្នាក់។ ក្រុមនីមួយៗបានធ្វើការស្ទង់មតិនៅតាមខេត្តផ្សេងៗគ្នា ក៏ដូចជារាជធានីភ្នំពេញផងដែរ។ កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងនៅក្នុងផ្ទះរបស់យុវជនផ្ទាល់។ ប្រធានក្រុមបានពិនិត្យសារឡើងវិញនូវកម្រងសំណួរដែលបានសាកសួររួច ដើម្បីធានាថាចម្លើយដែលទទួលបាន មានលក្ខណៈពេញលេញ និងស៊ីសង្វាក់គ្នា ហើយបន្ទាប់មកចុះលេខរៀងកម្រងសំនួរទាំងនេះ ដើម្បីមានភាពងាយស្រួលក្នុងការស្វែងរក និងទាញយកនៅពេលដែលត្រូវការ។ ការបញ្ចូលទិន្នន័យ និងការវិភាគបឋមត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ ក្នុងខែកក្កដា និងខែសីហា ដោយប្រើប្រាស់កម្មវិធីប្រព័ន្ធជំរឿន និងអង្កេតដំណើរការ (CSPro) និងប្រព័ន្ធកម្មវិធីកញ្ចប់ស្ថិតិសម្រាប់វិទ្យាសាស្ត្រសង្គម (SPSS)។

ករណីសិក្សា៖ របាយការណ៍នេះ ក៏មានរួមបញ្ចូលផងដែរនូវករណីសិក្សាសង្ខេបចំនួនបីដែលផ្តល់នូវការយល់ដឹងកាន់តែស៊ីជម្រៅអំពីបញ្ហាពុករលួយចម្បងៗ ដែលយុវជនជួបប្រទះក្នុងជីវិតប្រចាំថ្ងៃ ដូចដែលលទ្ធផលនៃការស្ទង់មតិបានបង្ហាញមក។ ករណីសិក្សាទាំងនេះត្រូវបានធ្វើឡើងនៅក្នុងខែកញ្ញា និងខែតុលា ឆ្នាំ២០១៤ ក្រោយពីការវិភាគទិន្នន័យបរិមាណត្រូវបានបញ្ចប់ ហើយលទ្ធផលសំខាន់ៗនៃការសិក្សាបានលេចរូបរាងឡើង។ បុគ្គលដែលជាប្រធានបទនៃករណីសិក្សាទាំងនេះបានយល់ព្រមចូលរួមនៅក្នុងករណីសិក្សា ក្នុងលក្ខខណ្ឌដែលអត្តសញ្ញាណរបស់ពួកគាត់មិនត្រូវបានបញ្ចេញ។ ដោយហេតុនេះឈ្មោះរបស់ពួកគាត់ត្រូវបានប្តូរ។

ព្រំដែននៃការស្ទង់មតិ៖ កិច្ចខិតខំគ្រប់បែបយ៉ាងបានធ្វើឡើងដើម្បីធានាថាទិន្នន័យដែលត្រូវបានប្រមូលមកនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ តែទោះជាយ៉ាងណាក្តី មានបញ្ហាពីរដែលជះឥទ្ធិពលទៅលើការសិក្សានេះ គឺពេលវេលានៃថ្ងៃដែល ទិន្នន័យត្រូវបានប្រមូល និងចំណង់ចិត្តរបស់អ្នកឆ្លើយទៅនឹងសំណួរទៅតាមរបៀបមួយដែលស្តាប់ទៅល្អ។ បញ្ហាទាំងពីរនេះឆ្លុះបញ្ចាំងឲ្យឃើញនូវការដែលថាទិន្នន័យត្រូវបានប្រមូលក្នុងពេលសម្ភាសន៍ទល់មុខ ដូច្នេះវាកំហិតព្រំដែនពេលវេលានៃថ្ងៃដែល គេអាចធ្វើសម្ភាសន៍បាន និងឥទ្ធិពលដែលអ្នកធ្វើសម្ភាសន៍អាចមានទៅលើអ្នកឆ្លើយ។

ក្រៅពីការព្យាយាមប្រមូលទិន្នន័យឲ្យចំថ្ងៃឈប់សម្រាកជាតិ នៅមានការលំបាកមួយទៀត ដែលត្រូវយកមកគិតគូរ ដោយសារថាមានចំនួនយុវជនច្រើនលើសលុបដែលធ្វើចំណាកស្រុកទៅរកការងារធ្វើ ដែលធ្វើឲ្យពួកគេអវត្តមានមិននៅក្នុងគ្រួសារពេញមួយឆ្នាំ។ មួយចំនួនចាកចោលលំនៅដ្ឋាន មកភ្នំពេញឬទីប្រជុំជននានាដើម្បីប្រកបរបរចិញ្ចឹមជីវិត រីឯមួយចំនួនទៀតចាកចេញពីប្រទេសទៅធ្វើការនៅ ប្រទេសថៃ ឬប្រទេសផ្សេងៗទៀត។ លើសពីនេះ កម្មករកាត់ដេរច្រើនតែធ្វើការយូរម៉ោងក្នុងរោងចក្រ កម្រត្រឡប់ទៅផ្ទះរបស់ខ្លួនពេលថ្ងៃណាស់។ ដោយហេតុនេះ ចំនួនអ្នកឆ្លើយដែលធ្វើការក្នុងវិស័យសេដ្ឋកិច្ចផ្លូវការ អាចខ្វះលក្ខណៈតំណាងឲ្យបានគ្រប់គ្រាន់។

វាជារឿងមួយពិបាកនឹងជំនះដែរការដែលអ្នកត្រូវបានសម្ភាសន៍ទល់មុខ មានទំនោរផ្តល់ចម្លើយ ធ្វើយ៉ាងណាស្តាប់ទៅល្អ ពិសេសពេលណាសំណួរឈ្លេចចំបញ្ហារសើបៗ ដូចជាអំពើពុករលួយ និងសុចរិតភាពបុគ្គល ជាដើម។ យ៉ាងណាក៏ដោយ ក្រុមសម្ភាសន៍បានខិតខំគ្រប់បែបយ៉ាងធ្វើយ៉ាងណាឲ្យ អ្នកឆ្លើយស្ងប់និងធូរស្រាលក្នុងអារម្មណ៍ក្នុងពេលសម្ភាសន៍។ លក្ខណៈវិនិច្ឆ័យមួយសម្រាប់អ្នកប្រមូលទិន្នន័យ គឺនៅត្រង់ថា ពួកគេត្រូវមានវ័យប្រហែលនឹងអ្នកឆ្លើយដែរ (ពួកគេស្ថិតក្នុងចន្លោះអាយុ ពី ២១ ដល់ ៣៤ឆ្នាំ)។ អ្នកប្រមូលទិន្នន័យទាំងអស់បានទទួលការបណ្តុះបណ្តាលពីសំណាក់មជ្ឈមណ្ឌលសិក្សាជាន់ខ្ពស់ (Centre for Advanced Study) និងអង្គការតម្លាភាពអន្តរជាតិប្រចាំកម្ពុជា (TI Cambodia) ហើយប្រធានក្រុមជាអ្នក តាមដានការងាររបស់ពួកគេ។ អ្នកដែលជាកម្មវត្ថុនៃការធ្វើអង្កេត ត្រូវបានទទួលការធានាអះអាងថា ចម្លើយរបស់ពួកគេនឹងត្រូវបានទុកជាលាក់ការណ៍សម្ងាត់ទាំងអស់។

លក្ខណៈប្រជាសាស្ត្រ៖ ក្នុងចំណោមយុវជន ១២០០ នាក់ដែលត្រូវបានធ្វើអង្កេតលើនេះ ចំណែកតំណាងយេនឌ័រសឹងតែមានភាពស្មើគ្នា គឺក្នុងនោះមានស្រ្តីចំនួន ៦០៣ នាក់ និងបុរស ៥៩៧ នាក់។ ជិតមួយភាគបី ឬ ៣២ ភាគរយ មានអាយុរវាង ១៥ និង ១៩ ឆ្នាំ, ៣២ ភាគរយ រវាង ២០ និង ២៤ ឆ្នាំ និង ៣៦ ភាគរយទៀត រវាង ២៥ និង ៣០ ឆ្នាំ។ សំណាកចម្លើយសម្រាប់វិភាគមានយុវជនជិតប្រាំបីនាក់ សម្រាប់មួយភូមិនៃ ១៥០ ភូមិក្នុងខេត្ត ចំនួនប្រាំបី៖ បាត់ដំបង កំពង់ចាម កំពត ភ្នំពេញ រតនៈគីរី សៀមរាប ស្វាយរៀង និង តាកែវ។

ភាសា៖ ការអង្កេតនេះត្រូវបានធ្វើជាភាសាខ្មែរ។ ការបកប្រែការអង្កេតនេះទៅជាភាសារបស់ជនជាតិដើម ភាគតិចមិនអាចធ្វើទៅរួចទេដោយសារថវិកាមានកំហិត។ បើទោះជាយុវជនជនជាតិដើមភាគតិចមួយចំនួន នៅខេត្តរតនៈគីរីជួបការលំបាកក្នុងការយល់សំណួរទាំងអស់ក្តី មានតែប្រាំនាក់ប៉ុណ្ណោះដែលគេមិនអាចធ្វើអង្កេតជាមួយបានដោយសារតែឧបសគ្គផ្នែកភាសា[12]។

សាសនា និង ជាតិពន្ធ៖ ភាគច្រើនលើសលុបនៃយុវជន គឺ ៩២ ភាគរយ មានជាតិពន្ធជាខ្មែរ និងជាអ្នកប្រណិប័តន៍តាមព្រះពុទ្ធសាសនា។ ប្រហែលបួនភាគរយ ជាជនជាតិដើមភាគតិច។ មានប្រហែលជាបួនភាគរយ ដែលផ្តល់អត្តសញ្ញាណខ្លួនគេថាមិនមែនជាអ្នកមានជំនឿសាសនាអ្វីទាំងអស់។

ស្ថានភាពការងារ៖ មួយភាគធំនៃសំណាកអង្កេតនេះគឺជាមនុស្សគ្មានអាជីពឬកំពុងសិក្សា។ នេះមកពីការ អង្កេតនេះត្រូវបានធ្វើឡើងក្នុងអំឡុងពេលថ្ងៃដែលជាពេលយុវជនកំពុងជាប់រវល់ការងារ។ ចំនួន ១០ ភាគរយ នៃអ្នកដែលត្រូវបានអង្កេតនិយាយថាពួកគេគ្មានការងារធ្វើ ជាមួយនឹង ១១ ភាគរយទៀតដែលនិយាយថា ជាមនុស្ស "អសកម្ម" (ជាមេផ្ទះ ឬ ជាមនុស្សក្នុងបន្ទុក)។ ច្រើនជាងមួយភាគប្រាំ ឬ ២២ ភាគរយ ជាសិស្ស ហើយ ៥៧ ភាគរយ បង្ហាញខ្លួនថាជាមនុស្សគ្មានអាជីព។ យ៉ាងណាក្តី ៧៨ ភាគរយនៃពួកគេនិយាយថាពួកគេ ធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ។ ក្នុងនោះមានយុវជនដែលកំពុងធ្វើការក្នុង ចំការរបស់គ្រួសារ ពលករ ប្រចាំថ្ងៃនៅតាមការដ្ឋានសំណង់និងចំការធំៗ អ្នកលក់ដូរតូចតាច ដាងតាមចិញ្ចើមផ្លូវ និងស្ត្រីបម្រើតាមផ្ទះ។

12 សំណាកជួសត្រូវបានជ្រើសរើសតាមវិធីសាស្ត្រដដែល

# របកគំហើញគន្លឹះ និង ការពិភាក្សា

## គោលគំនិត និង ជំនឿ

ចំណុចចាប់ផ្ដើមនៃការស្ទង់មតិនេះគឺកំណត់គោលគំនិត និងជំនឿអំពីអំពើពុករលួយ។ សំណួរនៅក្នុងផ្នែកនេះមានគោលបំណងស្វាបស្ទង់ការយល់ដឹង អំពីសុចរិតភាពបុគ្គល។ បន្ថែមលើនោះ សំណួរអំពីជំនឿរបស់យុវជនអំពីប្រាក់ចំណូល និងសុចរិតភាពរបស់គ្រួសារព្រមគ្នាជាមួយនឹងទំនាក់ទំនងរវាងភាពជោគជ័យនិងអំពើពុករលួយ ក៏ត្រូវបានចោទសួរដែរ។

បើទោះជាយុវជនមានគោលគំនិតសីលធម៌ខ្ពស់អំពីសុចរិតភាពក្ដី ជំហរនេះមានភាពរង្គោះរង្គើភ្លាម មួយរំពេចកាលណាសុចរិតភាពត្រូវបានគេមើលឃើញថាវាផ្ទុយទៅនឹងភក្ដីភាពជាមួយគ្រួសារ។ លើសពីនេះ គោលគំនិតសុចរិតភាពហាក់ដូចជាត្រូវអស់ខ្លឹមសារ កាលណាការប្រព្រឹត្តអំពើពុករលួយត្រូវបានគេចាត់ទុកថាជា "ទង្វើជាទូទៅ" ឬមួយនៅពេលដែលទឹកប្រាក់ដែលពាក់ព័ន្ធមានចំនួន "តិចតួច"។ របកគំហើញទាំងនេះសបញ្ជាក់ថា គោលគំនិតអំពីសុចរិតភាពបុគ្គល រងឥទ្ធិពលពីការទទួលយកយ៉ាងទូលំទូលាយរបស់សង្គមនូវការប្រព្រឹត្តបែបពុករលួយមួយចំនួន។

តាមរយៈរបកគំហើញទាំងនេះ បើទោះជា ៩៨ ភាគរយនៃយុវជនដែលបានអង្កេតចាត់ទុកថា មនុស្សមានសុចរិតភាពជាបុគ្គលដែលមិនដែលបំពានច្បាប់ទោះក្នុងទេសកាលណាក៏ដោយ ក៏ក្នុងនោះ ១៩ ភាគរយ ចាត់ទុកថាមនុស្សសុចរិតគឺជាមនុស្សដែលមានសាមគ្គីភាពនិងការគាំទ្រដល់គ្រួសារ និងមិត្តភ័ក្រ្តក្នុងគ្រប់កាលៈទេសៈ ទោះជាមានន័យថាត្រូវបំពានច្បាប់ក៏ដោយ។

សាមសិបបួន (៣៤) ភាគរយនៃយុវជនដែលត្រូវបានអង្កេត និយាយថាពួកគេចាត់ទុកថាមនុស្សមានសុចរិតភាពគឺជាបុគ្គលដែលមិនចូលរួមក្នុងអំពើពុករលួយ លើកលែងទំហំដែលពាក់ព័ន្ធវាតិចតួច។ នេះអាចរាប់បញ្ចូលទឹកប្រាក់ ឬអំណោយដែលមានចំនួនតិចតួច។ បន្ថែមលើនោះ ៤០ ភាគរយនៃអ្នកឆ្លើយនិយាយថា មនុស្សមានសុចរិតភាពបដិសេធមិនចូលរួមក្នុងអំពើពុករលួយ លើកលែងវាជាទង្វើជាទូទៅសម្រាប់ដោះស្រាយបញ្ហា ឬ ស្ថានភាពលំបាកនានា។



តារាងទី១

## ជំនឿ

សំណួរដែលមានគោលបំណងស្ទាបស្ទង់ជំនឿរបស់យុវជនអំពីអំពើពុករលួយ បានស្នើឲ្យពួកគេដាក់ពិន្ទុអំណះអំណាងមួយចំនួនតាមលំដាប់កម្រិតដែលពួកគេឯកភាពជាមួយនឹងចម្លើយទាំងនោះ។ ភាគច្រើននៃអ្នកផ្តល់ចម្លើយ បានបង្ហាញនូវជំនឿមុតមាំទៅលើភាពទៀងត្រង់ និងសុចរិតភាព។

តារាងទី ២ បានបង្ហាញឲ្យឃើញថា ៨៤ ភាគរយនៃយុវជនដែលត្រូវបានធ្វើអង្កេតបានយល់ស្របជាមួយ នឹងអំណះអំណាងដែលថា " សេចក្តីស្មោះត្រង់ និងការគោរពច្បាប់និងបទបញ្ញត្តិនានា មានសារៈសំខាន់ខ្លាំងណាស់ ធៀបនឹងការបង្កើនប្រាក់ចំណូលគ្រួសារ"។ ត្រង់នេះមានន័យថា យុវជនឲ្យតម្លៃសុចរិតភាពបុគ្គល លើសពីផលប្រយោជន៍ហិរញ្ញវត្ថុនៃគ្រួសាររបស់គេទៅទៀត។

សេចក្តីស្មោះត្រង់ និងការគោរពច្បាប់បញ្ញត្តិមានសារៈសំខាន់
ជាងការបង្កើនប្រាក់ចំណូលគ្រួសារ




តារាងទី២

ដូចតារាងទី៣ បានបង្ហាញ ៧៥ ភាគរយនៃអ្នកដែលត្រូវបានស្ទង់មតិ មិនយល់ស្របជាមួយនឹង អំណះអំណាងដែលថា៖ "មនុស្សដែលសុខចិត្តនិយាយកុហក បោកប្រាស់ ប្រព្រឹត្តបទល្មើស និងប្រព្រឹត្ត អំពើពុករលួយ មានឱកាសជោគជ័យច្រើនជាងមនុស្សដែលមិនប្រព្រឹត្តទង្វើទាំងអស់នេះ"។ ប៉ុន្តែអ្វីដែល គួរឲ្យកត់សម្គាល់នោះគឺថាអ្នកដទៃពីនេះយល់ស្របថា មនុស្សដែលចូលរួមប្រព្រឹត្តអំពើពុករលួយ មានជោគជ័យក្នុងជីវិតជាងអ្នកដែលមិនប្រព្រឹត្តទង្វើនេះ។

មនុស្សដែលសុខចិត្តនិយាយកុហក បោកប្រាស់ ប្រព្រឹត្តបទល្មើស
និងប្រព្រឹត្តអំពើពុករលួយមានឱកាសជោគជ័យច្រើនជាងមនុស្ស
ដែលមិនបានប្រព្រឹត្តទង្វើទាំងអស់នេះ




តារាងទី៣

# គុណតម្លៃ និងឥរិយាបថ

ផ្នែកនៃការសិក្សានេះមានគោលបំណងសិក្សាស៊ីជម្រៅថែមទៀតទៅក្នុងគោលគំនិត និងជំនឿជារួមរបស់យុវជន ដូចដែលបានបង្ហាញរួចមកហើយនៅក្នុងផ្នែកមុននេះ។ ក្នុងនោះមានសំណួរសំដៅស្ទាបស្ទង់មើល ឥរិយាបថចំពោះភាព "ត្រូវ" និង "ខុស" ដែលមិនសូវជាខុសស្រឡះពីគ្នាប៉ុន្មានទេ។ អ្នកឆ្លើយតបត្រូវបានបង្ហាញនូវអាកប្បកិរិយាជាក់លាក់មួយចំនួន ហើយស្នើឲ្យជ្រើសរើសថាតើអាកប្បកិរិយាទាំងនោះខុស ឬមិនខុស ហើយថាតើវាអាចទទួលយកបានឬទេ។ ចេតនានៃសំណួរទាំងនោះគឺដើម្បីសិក្សាអំពីភាពខុសគ្នារវាងការយល់ដឹងអំពីភាពត្រូវនិងខុសក្នុងន័យច្បាប់ និងការអនុវត្តល្អ និងការទទួលយកអាកប្បកិរិយាទាំងនោះក្នុងជីវភាពរស់ប្រចាំថ្ងៃ។

ដូចបានបង្ហាញជូនខាងក្រោម លទ្ធផលបានបង្ហាញថាការប្រព្រឹត្តពុករលួយជាច្រើនត្រូវបានយុវជន ចាត់ទុកថាអាចទទួលយកបាន បើទោះជាពួកគេជឿថាអាកប្បកិរិយាទាំងនោះវាខុសក៏ដោយ។ ក្នុងសំណួរនីមួយៗ ចំនួនអ្នកនិយាយថាអាកប្បកិរិយាបែបនោះអាចទទួលយកបាន មានចំនួនខ្ពស់ជាងអ្នកដែលនិយាយថា អាកប្បកិរិយាទាំងនេះវាខុស។ ត្រង់នេះទំនងជាសបញ្ជាក់ថា បើទោះជាយុវជនឲ្យតម្លៃសុចរិតភាពក្តី ឥរិយាបថរបស់ពួកគេចំពោះទង្វើពុករលួយក្នុងជីវភាពប្រចាំថ្ងៃក៏កាន់តែចុះសម្រុងជាមួយវាដែរ។

## គុណតម្លៃ

សំណួរទាក់ទងនឹងគុណតម្លៃចោទសួរដោយជាក់លាក់ថាតើអាកប្បកិរិយាបែបណាខ្លះដែលខុសឬត្រូវ។ សំណួរទាំងនេះរួមបញ្ចូលទិដ្ឋភាពផ្សេងៗគ្នានៃអាកប្បកិរិយា រួមទាំងសំណួរដែលលើកឡើងដោយចំៗ ថាទង្វើនោះវាខុសច្បាប់។ បើទោះជាភាគច្រើននៃចម្លើយតប គឺស្របគ្នាទៅនឹងទស្សនៈទូទៅរបស់សង្គមអំពីភាពខុស និងត្រូវក្តី អាកប្បកិរិយាមួយចំនួនទាក់ទិននឹងបណ្តាទង្វើដែលគេតែងឃើញក្នុងសង្គមកម្ពុជា បាននាំឲ្យមានប្រតិកម្មចម្រុះ។

ទាក់ទងទៅនឹងការយល់ច្បាស់អំពីភាពត្រូវ និងខុស ចម្លើយលេចធ្លោជាងគេច្រើនតែមានទំនោរ ពាក់ព័ន្ធជាមួយនឹងអាកប្បកិរិយាខុសច្បាប់។ ឧទាហរណ៍ ៩០ ភាគរយនៃអ្នកឆ្លើយយល់ស្របថាវាជាទង្វើខុស កាលណាជនណាម្នាក់ប្រព្រឹត្តអំពើខុសច្បាប់ ដើម្បីចិញ្ចឹមជីវិតគ្រួសាររបស់ខ្លួន ហើយជាមួយគ្នានោះដែរ ៩១ ភាគរយនៃអ្នកឆ្លើយតបយល់ស្របថាវាជាទង្វើខុសកាលណាមន្ត្រីរដ្ឋម្នាក់ទាមទារបង់ប្រាក់បន្ថែមក្រៅផ្លូវការសម្រាប់ការផ្តល់សេវា ឬនីតិវិធីរដ្ឋបាលណាមួយដែលជាផ្នែកនៃការងាររបស់មន្ត្រីរូបនោះ។

មិនមែនសំណួរផ្អែកលើគុណតម្លៃទាំងអស់សុទ្ធតែទទួលចម្លើយខ្លាំងដូចខាងលើនោះទេ ពីព្រោះថា ១៧ ភាគរយនៃអ្នកដែលត្រូវបានអង្កេត មិនឯកភាពទេជាមួយការដែលថាវាជាទង្វើខុសក្នុងការផ្តល់ប្រាក់ក្រៅផ្លូវការបន្ថែម (ឬអំណោយ) ទៅឲ្យមន្ត្រីរដ្ឋ ដើម្បីពន្លឿន ឬសម្របសម្រួលនីតិវិធីក្នុងការចុះបញ្ជីថយន្ត ឬទោចក្រយានយន្តជាដើម។ មូលហេតុដែលនាំឲ្យពិន្ទុទាបអំពីអំណះអំណាងនេះ ប្រហែលការអនុវត្តទង្វើបែបនេះមានភាពទូលំទូលាយ ឬមួយមកពីគេចាត់ទុកថាវាមិនជារឿងធំដុំអ្វីទេ។ ចំណុចចុងក្រោយនេះប្រហែលអាចពន្យល់បានថាហេតុអ្វីបានជាមានតែ ៤០ ភាគរយនៃអ្នកឆ្លើយប៉ុណ្ណោះដែលមិនឯកភាពជាមួយនឹងការដែលថា វាខុសក្នុងការផ្តល់ប្រាក់បន្ថែមក្រៅផ្លូវការ (ឬឲ្យអំណោយ) ដល់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកយិកាជាថ្នូរទៅនឹងការទទួលបានសេវាព្យាបាលល្អប្រសើរ។ ការឲ្យ "អំណោយ" ឬការបង់ថ្លៃក្រៅផ្លូវការបន្ថែមដល់អ្នកផ្តល់សេវាសុខាភិបាល ជាទម្លាប់អនុវត្តន៍ទូទៅនៅប្រទេសកម្ពុជា។ ក្នុងប្រទេសមួយដែលប្រាក់ឈ្នួលរបស់អ្នកផ្តល់សេវាសុខាភិបាលនៅទាបជាងកម្រិតបៀវត្សសមរម្យមួយដែលអាចរស់បាន ការឲ្យអំណោយឬបង់ប្រាក់បន្ថែមក្រៅផ្លូវការដល់អ្នកទាំងនោះ តែងត្រូវបានគេចាត់ទុកថាជាកាយវិការដឹងគុណជាជាងការសូកប៉ាន់ទៅវិញ។

តារាង៩២



## ករណីសិក្សាទី ១: ការផ្តល់អំណោយក្នុងវិស័យថែទាំសុខាភិបាល "រឿងអាយុជីវិត"

សម្រាប់ មករា ដែលមានអាយុ២៨ឆ្នាំ ការផ្តល់ប្រាក់ទៅឲ្យបុគ្គលិកមន្ទីរពេទ្យ ជួយនាងឲ្យទទួលបានសេវាប្រសើរ និងឆាប់រហ័ស។ នៅឆ្នាំ ២០១៣ នាងបានសម្រាលកូននៅមន្ទីរពេទ្យរដ្ឋមួយក្នុងទីក្រុងភ្នំពេញ។

មករានិយាយថាសមាជិកគ្រួសារនាងបានឲ្យលុយទៅបុគ្គលិកមន្ទីរពេទ្យមួយចំនួនរួមមានវេជ្ជបណ្ឌិត គិលានុបដ្ឋាកយិកា បេឡាការិនី និងអ្នកបោសជូតក្នុងអំឡុងពេលដែលនាងស្នាក់នៅក្នុងមន្ទីរពេទ្យអស់មួយសប្តាហ៍។

នាងបាននិយាយពន្យល់ដូច្នេះថា"គេអត់បានសុំអំណោយអ្វីទេ។ យើងគ្រាន់តែឲ្យគេទៅ ដើម្បីឲ្យគេយកចិត្តទុកដាក់។ យើងធ្លាប់លឺថាសេវាយឺតសម្រាប់អ្នកមិនឲ្យលុយគេ"។

នាងពិពណ៌នាអំពីការបង់លុយបែបនោះថាជា"រឿងអាយុជីវិតសម្រាប់ខ្ញុំ និងកូនរបស់ខ្ញុំ"។ ពួកយើងមិនគិតថាវាជាបញ្ហាធំដុំទេ"។

នាងពន្យល់ថែមទៀតថា បើទោះជាបុគ្គលិកមន្ទីរពេទ្យមិនបានទាមទារលុយក្តី គ្មាននរណាម្នាក់ក្នុង ចំណោមនោះបដិសេធ ឬក៏សម្តែងការភ្ញាក់ផ្អើលនឹងទទួលលុយដែលឲ្យនោះដែរ។

## ឥរិយាបថ

ដោយប្រើប្រាស់សេណារីយោដូចគ្នាទៅនឹងសំណួរអំពីគុណតម្លៃ សំណួរទាក់ទិននឹងឥរិយាបថបានចោទសួរយុវជនថាតើអាកប្បកិរិយាទាំងនោះអាចទទួលយកបានឬអត់។ ចម្លើយទៅនឹងសំណួរផ្អែកលើឥរិយាបថ បង្ហាញឲ្យឃើញនូវការទទួលយកកាន់តែទូលំទូលាយជាងមុននូវអាកប្បកិរិយាដែលពួកយុវជនជឿថា ជាទង្វើខុស។ ក្នុងសំណួរទាំងអស់ អត្រានៃអ្នកយល់ថាអាកប្បកិរិយាទាំងនោះទទួលយកបាន មានខ្ពស់ជាងអត្រានៃអ្នកដែលនិយាយថាអាកប្បកិរិយាទាំងនោះវាខុស។

ខណៈដែល៩០ ភាគរយនៃអ្នកឆ្លើយឯកភាពថាវាខុសកាលណាបុគ្គលម្នាក់ប្រព្រឹត្តខុសច្បាប់ដើម្បីជីវភាពប្រចាំថ្ងៃរបស់ក្រុមគ្រួសារ មានជិតមួយក្នុងចំណោមប្រាំនាក់ដែលនិយាយថាទង្វើបែបនោះអាចទទួលយកបាន។ ជាងនេះនៅទៀត បើទោះជា ៩២ ភាគរយឯកភាពថាវាខុសកាលណាមន្ត្រីរដ្ឋម្នាក់ទារប្រាក់ថែមក្រៅផ្លូវការសម្រាប់សេវា ឬនីតិវិធីរដ្ឋបាលដែលជាផ្នែកនៃការងាររបស់ពួកគេ មាន ១៦ ភាគរយដែលនិយាយថាអាកប្បកិរិយារបស់មន្ត្រីរដ្ឋនោះ អាចទទួលយកបាន។ សំណួរតែមួយគត់ដែលមានភាពគួទឹមខ្លះៗ រវាងកម្រិតនៃការយល់ស្រប និងថាតើអាកប្បកិរិយាបែបនោះវាខុសឬត្រូវយ៉ាងណានោះគឺៈ "ឪពុកម្តាយសិស្សម្នាក់ផ្តល់ប្រាក់បន្ថែមក្រៅផ្លូវការ (ឬឲ្យអំណោយ) ដល់គ្រូម្នាក់ដើម្បីជួយឲ្យកូនទទួលបានពិន្ទុល្អប្រសើរ"។ ក្នុងករណីបែបនេះ ៩៧ ភាគរយនៃអ្នកឆ្លើយនិយាយថាអាកប្បកិរិយាបែបនេះវាខុស ជាមួយគ្នានោះ ៩៥ ភាគរយ និយាយថាអាកប្បកិរិយាបែបនេះមិនអាចទទួលយកបានទេ។ វាជាការមួយគួរឲ្យភ្ញាក់ផ្អើលដែរនៅពេលដែលឃើញថាមានតែ ៣ ភាគរយនៃយុវជនដែលបានអង្កេតប៉ុណ្ណោះដែលនិយាយថាវាជារឿងមួយដែលអាចទទួលយកបាន កាលណាអាណាព្យាបាលឲ្យអំណោយទៅគ្រូដើម្បីបានប្រយោជន៍ដល់កូនរបស់ខ្លួន។ វាជារឿងទូទៅហើយសម្រាប់គ្រូៗ បើកថ្នាក់បង្រៀនបន្ថែមក្រៅម៉ោងដល់សិស្សដើម្បីយកសោហ៊ុយ ដែលគេច្រើនហៅថារៀនគួរ ហើយគេតែងតែសន្មតថាសិស្សទាំងឡាយណាដែលរៀនបន្ថែមក្រៅម៉ោងបែបនេះ ច្រើនតែទទួលបានពិន្ទុខ្ពស់ពីគ្រូជាស្វ័យប្រវត្តិ។

កម្រិតខ្ពស់បំផុតនៃការទទួលយកបាននេះ មានសង្គតិភាពជាមួយនឹងអាកប្បកិរិយា ដែលមានចំនួនយុវជនច្រើនលើសលុបនិយាយថា អាកប្បកិរិយាបែបនេះមិនខុសទេ។ ជិតមួយភាគប្រាំ ឬ ២៤ ភាគរយ និយាយថាវាអាចទទួលយកបានចំពោះការផ្តល់ប្រាក់បន្ថែម (ឬឲ្យអំណោយ) ដល់មន្ត្រីរដ្ឋដើម្បីឲ្យគេពន្លឿន និង សម្រួលដំណើរការចុះបញ្ជីការរថយន្ត ឬទោចក្រយានយន្ត គឺ៧ភាគរយ ខ្ពស់ជាងចំនួនអ្នកដែលនិយាយថាអាកប្បកិរិយាបែបនេះមិនខុសទេ។ លទ្ធផលនេះ មិនគួរឲ្យភ្ញាក់ផ្អើលទេ ដោយសារថាការបង់លុយថែមឲ្យទៅបណ្តាមន្ត្រីរដ្ឋដើម្បីទទួលបានឯកសារនានាបានឆាប់រហ័ស មិនមែនជារឿងចម្លែកនោះឡើយ។




តារាងទី៦

## ការយល់ដឹងពីអំពើពុករលួយ

ផ្នែកនៃការសិក្សានេះមានគោលដៅស្ទាបស្ទង់ការយល់ដឹងរបស់យុវជនអំពីអំពើពុករលួយ ទាំងក្នុងផ្នែកម៉ាក្រូ និងក្នុងស្ថាប័នជាក់លាក់មួយចំនួន។ ដោយធ្វើការប៉ាន់ប្រមាណការយល់ដឹងរបស់ពួកគេអំពី អំពើពុករលួយ ការស្រាវជ្រាវនេះអាចផ្ដល់បរិបទទូលំទូលាយមួយស្ដីពីទំនាក់ទំនងពួកគេជាមួយអំពើពុករលួយនៅក្នុងសង្គម។

លទ្ធផលបង្ហាញនូវគម្លាតដ៏ធំមួយរវាងការយល់ឃើញអំពីអំពើពុករលួយកម្រិតម៉ាក្រូ និងការយល់ដឹងពីអំពើពុករលួយនៅតាមស្ថាប័នជាក់លាក់មួយចំនួន។ បើទោះជាយុវជនច្រើនលើសលុបនិយាយថា កង្វះសុចរិតភាពនិងអំពើពុករលួយជាបញ្ហាដល់ការអភិវឌ្ឍប្រទេសសេដ្ឋកិច្ច និងដល់បុគ្គលក្ដី តែនៅពេលដែលគេចោទសួរពីអំពើពុករលួយនៅតាមស្ថាប័នជាក់លាក់មួយចំនួន យុវជនទាំងនោះមិនសូវជាមានលទ្ធភាពចង្អុលបង្ហាញថាកន្លែងណាពិតប្រាកដទេដែលអំពើពុករលួយបង្កបញ្ហា។ ត្រង់នេះ ប្រហែលជាឆ្លុះបញ្ចាំងឲ្យឃើញនូវកង្វះចំណេះដឹងអំពីស្ថាប័នជាក់លាក់មួយចំនួនហើយ។ ដូចបានលើកឡើង មុននេះ មានតែ ៣៦ ភាគរយនៃយុវជនប៉ុណ្ណោះដែលនិយាយថាពួកគេដឹងថាអ្វីទៅជាប្រជាធិបតេយ្យឬសភាជាតិ ហើយ ៤០ ភាគរយប៉ុណ្ណោះដឹងថាក្រុមប្រឹក្សាឃុំជាអ្វី[1] ។

លើសពីនេះ ទិន្នន័យពីការស្ទង់មតិយុវជនស្ដីពីសុចរិតភាពបានបង្ហាញថា មានតែ ២៩ ភាគរយ នៃយុវជនដែលបានស្ទង់មតិប៉ុណ្ណោះដែលនិយាយថា ពួកគេទទួលបានព័ត៌មានខ្លះៗ ឬច្រើនអំពីច្បាប់និងបទបញ្ញត្តិរដ្ឋាភិបាលដើម្បីទប់ស្កាត់អំពើពុករលួយនិងលើកស្ទួយសុចរិតភាព។ កាលណាមិនមានព័ត៌មានឬចំណេះដឹង ចាំបាច់មួយចំនួន វាពិបាកណាស់សម្រាប់ពួកគេក្នុងការចង្អុលបង្ហាញឲ្យចំនូវអំពើពុករលួយក្នុងរង្វង់ស្ថាប័នរដ្ឋ និងសង្គម។ គួរកត់សម្គាល់ដែរថា កម្មវិធីសិក្សាតាមសាលារៀនមិនមានបញ្ចូលការពន្យល់អំពីលទ្ធិប្រជាធិបតេយ្យ ឬលើកឡើងអំពីសភាជាតិឡើយ។

ដូចតារាងទី ៦ បានបង្ហាញ ៩៧ ភាគរយនៃអ្នកឆ្លើយនិយាយថា កង្វះសុចរិតភាពជាបញ្ហាធំមួយក្នុងគ្រប់កំរិតនៃសង្គម។ ក្នុងចំណោមយុវជនដែលឆ្លើយ "បាទ/ចាស" ឬ "ទេ" ទៅនឹងសំណួរ មាន ៩៩ ភាគរយ ដែល និយាយថាកង្វះសុចរិតភាពគឺជាបញ្ហាចម្បងមួយរារាំងដល់ដល់ការអភិវឌ្ឍប្រទេស។ នេះបង្ហាញថា ក្នុងកម្រិតជាទ្រឹស្ដីទូលំទូលាយ យុវជនដឹងថាអំពើពុករលួយជាបញ្ហាសង្គមមួយ។ វាសបញ្ជាក់ថាមនុស្សជំនាន់ថ្មីមានការយល់ដឹងអំពីផលវិបាកនានានៃកង្វះសុចរិតភាពក្នុងសង្គម បើទោះជាវាមិនមានន័យថាពួកគេប្រាថ្នាប្រកាន់យកផ្លូវជីវិតប្រកបដោយសុចរិត បើទោះជាវាអាចនឹងមានផលប៉ះពាល់មកលើស្ដង់ដាររស់នៅរបស់ពួកគេ និងអ្នកនៅជុំវិញខ្លួនគេក្ដី។

1 BBC Media Action and UNDP, *Reaching and Engaging the Cambodian Youth on Issues of Civic Participation*, February 2014, pg.20

តារាងទី៦

តើអ្នកគិតថាកង្វះសុចរិតភាព (រួមទាំងអំពើពុករលួយ)គឺជាបញ្ហាធំ (ផ្តល់ផលប៉ះពាល់ខ្លាំង)ចំពោះ.... ឬទេ??




ពេលដែលត្រូវបានគេសួរឲ្យចង្អុលបង្ហាញអំពើពុករលួយក្នុងរង្វង់ស្ថាប័នជាក់លាក់មួយចំនួន យុវជនមិនសូវជាមានភាពជឿជាក់ចង្អុលឲ្យចំស្ថាប័នមួយណាណាស់។ យ៉ាងណាក្តី ដូចយើងនឹងឃើញក្នុងតារាងទី៧ ចំនួនភាគរយនៃយុវជនដែលនិយាយថាកម្រិតសុចរិតភាពក្នុងស្ថាប័ននានា"មិនល្អទាល់តែសោះ" ឬ "មិនសូវល្អ" គឺមានក្រាស់ក្រែលគួរសម[2] ។

ក្នុងចំណោមអ្នកដែលត្រូវបានអង្កេត ៤៦ ភាគរយ និយាយថាកម្រិតសុចរិតភាពក្នុងជួរនគរបាលនិងកម្លាំងសន្តិសុខ មិនល្អទាល់តែសោះ" ឬ "មិនសូវល្អ"។ សាមសិបប្រាំបីភាគរយ និយាយថាកម្រិតសុចរិតភាព ក្នុងរង្វង់រដ្ឋបាលជាតិក៏ "មិនល្អទាល់តែសោះ" ឬ "មិនសូវល្អ" រីឯ ១៦ ភាគរយទៀតនិយាយថាមិនដឹង។ សាមសិបប្រាំពីរភាគរយនិយាយថាកម្រិតសុចរិតភាពក្នុងរង្វង់រដ្ឋបាលថ្នាក់ក្រោម "មិនល្អទាល់តែសោះ" ឬ "មិនសូវល្អ"។

របកគំហើញទាំងនេះមានសង្គតិភាពជាមួយនឹងរង្វាស់អំពើពុករលួយសកលឆ្នាំ ២០១៣ (Global Corruption Barometer 2013) ដែលបានឲ្យដឹងថាប្រព័ន្ធតុលាការ នគរបាល និងវិស័យសាធារណៈ ជាស្ថាប័នពុករលួយជាងគេនៅប្រទេសកម្ពុជា[3] ។ យុវជនហាក់បីដូចជាគិតថា ផ្នែកអប់រំសិក្សារបស់រដ្ឋមានសុចរិតភាពខ្ពស់ជាងស្ថាប័នរបស់រដ្ឋដទៃទៀត ដោយក្នុងនោះ ៧០ ភាគរយនិយាយថាកម្រិតសុចរិតភាពក្នុងផ្នែកអប់រំ សិក្សារបស់រដ្ឋគឺ "ល្អគួរសម" ឬ "ល្អ"។ ត្រង់នេះវាហាក់ដូចជាផ្ទុយទៅនឹងអាកប្បកិរិយារបស់ពួកគេ ត្រង់ថាការស្ទង់មតិមួយនៅឆ្នាំ ២០១២ រកឃើញថា ៩៣,២ ភាគរយនៃសិស្សដែលបានអង្កេតបាននិយាយថាពួកគេធ្លាប់លបមើលចម្លើយ ឬសូកគ្រូក្នុងអំឡុងពេលប្រឡងនៅវិទ្យាល័យ[4] ។

2 ការដាក់ពិន្ទុ "មិនល្អទាល់តែសោះ" និង"មិនសូវល្អ" ត្រូវបានពន្យល់ក្នុងកម្រងសំណួរថាវាមានន័យថា ឬមួយអំពើពុករលួយមានលក្ខណៈសាយភាយ ឬមួយអំពើពុករលួយមានច្រើនករណី។ រីឯចម្លើយ "ល្អគួរសម" ឬ "ល្អណាស់" មានន័យថាមានអំពើពុករលួយ តិចតួច ឬគ្មានសោះតែម្តង។

3 http://www.transparency.org/gcb2013/report

4 Art and Youth Employment Support, *Turning a Blind Eye*, 2012, pg.2or http://blog.seuksa.com/2012/08/cambodia-2012-bacii-exam-survey/

## ការវាយតម្លៃរបស់យុវជនលើសុចរិតភាពក្នុងវិស័យសាធារណៈនិងឯកជន




តារាងទី៧

ការវិភាគបន្ថែមទៀតបង្ហាញថា យុវជននៅតាមទីប្រជុំជនមានទំនោរខ្លាំងជាងយុវជនរស់នៅតាមទីជនបទ ក្នុងការយល់ឃើញថាសេវាសាធារណៈ "ពុករលួយ" ឬ "ពុករលួយខ្លាំង"។ ភាពខុសគ្នានេះមានជាពិសេសនៅត្រង់ការវាយតម្លៃអំពីសេវាថែទាំសុខាភិបាលសាធារណៈ (៤៧ ភាគរយនៃយុវជននៅទីប្រជុំជនគិតថាវា "មិនល្អ" ឬ "មិនសូវល្អ" ធៀបទៅនឹង ២៣ ភាគរយដែលជាចម្លើយរបស់យុវជននៅជនបទ), វិស័យអប់រំសាធារណៈ (៤៤ ភាគរយ ធៀបទៅនឹង ២៤ ភាគរយ) ហើយនិងនគរបាលនិងកម្លាំងសន្តិសុខ (៥៩ ភាគរយ ធៀបទៅនឹង ៤៥ ភាគរយ)។

## យុវជនដាក់ពិន្ទុសេវាសាធារណៈថា "មិនល្អទាល់តែសោះ" ឬ "មិនសូវល្អ"៖ បែងចែកតាមទីតាំងភូមិសាស្ត្រ




តារាងទី៨

## ជួបប្រទះអំពើពុករលួយ

ក្នុងផ្នែកនេះ ការស្រាវជ្រាវមានគោលដៅប៉ាន់ប្រមាណបទពិសោធន៍ជួបប្រទះអំពើពុករលួយ។ យុវជនត្រូវបានចោទសួរថាតើពួកគេធ្លាប់ឆ្លងកាត់បទពិសោធន៍នៃអំពើពុករលួយបែបណាខ្លះ ក្នុងរយៈពេល ១២ ខែមុនការធ្វើអង្កេត តាមសេណារីយោប្រាំមួយខុសៗគ្នា៖ ១) ដើម្បីទទួលបានឯកសារ; ២) ដើម្បីប្រឡងនៅសាលា; ៣) ដើម្បីទទួលបានសេវាសុខាភិបាល; ៤) ដើម្បីបញ្ចៀសបញ្ហាជាមួយនគរបាល; ៥) ដើម្បីទទួលបានការងារធ្វើ; និង ៦) ដើម្បីបង្កើនអតិថិជនរបស់ក្រុមហ៊ុន/សហគ្រាស។ ក្នុងសេណារីយោ នីមួយៗ អ្នកឆ្លើយមានជម្រើសបី៖ ១) ពួកគេធ្លាប់ជួបប្រទះអំពើពុករលួយ; ២) ពួកគេមិនធ្លាប់ជួបប្រទះអំពើពុករលួយ; ឬ ៣) ពួកគេមិនដែលមានទំនាក់ទំនងជាមួយសេវានោះក្នុងរយៈពេល ១២ ខែកន្លងទៅ។ ទិន្នន័យដែលបានមកពីផ្នែកនៃការស្រាវជ្រាវនេះ ផ្តល់នូវការប្រៀបធៀបមានប្រយោជន៍មួយ ធៀបជាមួយនឹងការដាក់ពិន្ទុសុចរិតភាពអំពីស្ថាប័នជាក់លាក់មួយចំនួនដូចដែលបានលើកឡើងរួចមកហើយ។

តារាង ៩

ឆ្លងកាត់អំពើពុករលួយ *




*ក្នុងចំណោមអ្នកទាំងឡាយដែលមានការទាក់ទងជាមួយទីភ្នាក់ងារ/សេវាកម្មនានាក្នុងអំឡុងពេល ១២ ខែកន្លងទៅនេះ

ដូចបានបង្ហាញក្នុងតារាង ៩ កំរិតខ្ពស់បំផុតនៃការជួបប្រទះអំពើពុករលួយ គឺបានមកពីយុវជន ដែលព្យាយាមចៀសវាងបញ្ហាជាមួយនគរបាល។ សឹងតែប្រាំពីរក្នុងចំណោមដប់នាក់ដែលធ្លាប់មានបញ្ហា ជាមួយនគរបាលក្នុងរយៈពេល ១២ ខែមុនការធ្វើអង្កេត ធ្លាប់ពើបប្រទះជាមួយអំពើពុករលួយ។ តួលេខនេះ ចង្អុលបង្ហាញថា អំពើពុករលួយជាបញ្ហាធ្ងន់ធ្ងរមែនទែនក្នុងរង្វង់កងកម្លាំងនគរបាល។

ជិតពាក់កណ្តាលនៃយុវជនទាំងឡាយដែលបានព្យាយាមសុំឯកសារ ឬ បណ្ណអនុញ្ញាតបានជួបប្រទះអំពើពុករលួយ ហើយយុវជនក្នុងភាគរយប្រហាក់ប្រហែលគ្នានេះបានពើបប្រទះអំពើពុករលួយក្នុងការប្រលង (ឬក្នុងការបានទទួលឲ្យចូលរៀន)។ បើទោះជាការស្ទង់មតិមិនព្យាយាមកំណត់នូវភាពញឹកញាប់ក្នុងការជួបប្រទះអំពើពុករលួយក្តី ទិន្នន័យដែលប្រមូលបានចង្អុលប្រាប់ថា អំពើពុករលួយជាបញ្ហាធ្ងន់ធ្ងរមួយដែលយុវជន កម្ពុជាជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃរបស់គេ។

ការស្ទង់មតិនេះក៏ចង្អុលបង្ហាញដែរថា យុវជននៅទីប្រជុំជនជារឿយៗជួបប្រទះអំពើពុករលួយច្រើនជាងយុវជន នៅជនបទក្នុងសេណារីយោប្រាំក្នុងចំណោមសេណារីយោទាំងប្រាំមួយ។ ភាពខុសគ្នាគួរឲ្យកត់សម្គាល់នោះ គឺនៅត្រង់ការប្រឡង (២១ ភាគរយនៃយុវជននៅទីប្រជុំជនធៀបទៅនឹង ១៣ ភាគរយនៃយុវជន នៅជនបទ), ការទទួលបានសេវាសុខាភិបាល(១៨ ភាគរយធៀបនឹង ១២ ភាគរយ), និងក្នុងការដោះស្រាយបញ្ហាជាមួយនគរបាល(២៨ ភាគរយធៀបនឹង ២០ ភាគរយ)។ និយាយពីផ្នែកយេនឌ័រវិញ មានយុវជនច្រើនជាងយុវនារី ដែលបានរាយការណ៍ថាខ្លួនបានពើបប្រទះអំពើពុករលួយក្នុងរយៈពេល ១២ ខែមុនការធ្វើអង្កេត លើកលែងតែក្នុងសេណារីយោមួយ នោះគឺសេណារីយោស្តីពីការបង្កើនរបរសម្រាប់ ក្រុមហ៊ុនឬសហគ្រាស។

## សុចរិតភាពផ្អែកលើអាកប្បកិរិយា

បន្ថែមលើការព្យាយាមស្វែងយល់អំពីបទពិសោធន៍ឆ្លងកាត់អំពើពុករលួយ ការសិក្សានេះមាន គោលបំណងស្វែងយល់ផងដែរនូវការប្តេជ្ញាចិត្តរបស់យុវជន ក្នុងការប្រកាន់យកនូវសុចរិតភាព ពេលណាខ្លួនពើបប្រទះជាមួយ ស្ថានភាពបែបសម្មតិកម្មមួយចំនួន។ អំពើពុករលួយមិនមែនសុទ្ធតែជាដំណើរទង្វើពីលើចុះក្រោមរហូតនោះទេ។ ដូចយើងនឹងបង្ហាញបន្តិចទៀតក្នុងរបាយការណ៍នេះ ការទទួលយកអំពើពុករលួយ ហើយនិងការចូលរួមក្នុងការប្រព្រឹត្តពុករលួយនេះ ទំនងជាបញ្ហាទម្លាប់សង្គមកម្ពុជាតែម្តង។ បើទោះជាថាយុវជនប្រហែលជាយល់ដឹងអំពីពុករលួយក្តី ហើយមានទស្សនទានសីលធម៌រឹងមាំអំពីសុចរិតភាពក្តី ចេតនារបស់ពួកគេចូលរួមក្នុងអំពើពុករលួយក៏ជាចំណុចមួយសំខាន់គួរឲ្យកត់សម្គាល់ដែរ។ សំណួរថាតើពួកគេយល់ថាមានជម្រើសណាផ្សេង មកជំនួសការប្រព្រឹត្តបែបពុករលួយ បានឬយ៉ាងណានោះ វាជារឿងមួយទៀតដែលទាមទារឲ្យមានការស្រាវជ្រាវបន្ថែម។ ផ្នែកនេះនៃទិន្នន័យមានគោលបំណងគ្រាន់តែធ្វើបរិមាណកម្មចំនួនយុវជនដែលបានទទួលស្គាល់ថា ខ្លួនមានចេតនាបំពានសុចរិតភាពក្នុងសេណារីយោជាក់លាក់ណាមួយតែប៉ុណ្ណោះ។ សេណារីយោបួនផ្សេងៗគ្នាត្រូវបានបង្ហាញដល់អ្នកឆ្លើយសំណួរ ហើយពួកគេត្រូវបានអនុញ្ញាតឲ្យជ្រើសយកចម្លើយតែមួយទេ។ កម្រងចម្លើយមានចាប់ពីមានសីលធម៌ខ្ពស់ រហូតដល់អាកប្បកិរិយាពុករលួយ។

## ទទួលបានពិន្ទុល្អក្នុងថ្នាក់

សេណារីយោទីមួយផ្តោតលើការត្រៀមខ្លួនរបស់យុវជនក្នុងការលួចចម្លងក្នុងពេលប្រឡង។ ដូចដែលនឹងពិភាក្សាបន្តិចទៀតនេះក្នុងរបាយការណ៍នេះ បញ្ហានេះធ្លាប់ជាចំណុចចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយច្រើនសន្ធឹកសន្ធាប់ណាស់ដែរមកហើយនៅឆ្នាំ ២០១៤ ហើយវាក៏ជាកម្មវត្ថុមួយនៃចំណាត់ការដោយផ្ទាល់ ពីសំណាក់អង្គភាពប្រឆាំងពុករលួយដែរ។ លទ្ធផលពីការស្ទង់មតិនេះរកឃើញថាមានតែ ១៤ ភាគរយនៃអ្នក ឆ្លើយប៉ុណ្ណោះដែលនិយាយថាពួកគេមានចេតនាលួចចម្លងក្នុងពេលប្រឡង។ តួលេខនេះទាបបើធៀបទៅនឹងចំណាប់អារម្មណ៍ប្រព័ន្ធផ្សព្វផ្សាយមកលើប្រធានបទនេះ និងការយល់ឃើញជាទូទៅថា ការលួចចម្លងមានលក្ខណៈសុះសាយក្នុងពេលប្រឡង។ ការសិក្សាមួយកាលពីឆ្នាំ ២០១២ លើសិស្សនៅភ្នំពេញដែលត្រូវ ប្រឡងបញ្ចប់ថ្នាក់ទី ១២ បានរកឃើញថា ៧០ ភាគរយនៃអ្នកឆ្លើយបានរាយការណ៍ឲ្យដឹងថា ពួកគេបានបង់លុយឲ្យមេប្រយោគដើម្បីមានលទ្ធភាពលួចចម្លងចម្លើយវិញ្ញាសារប្រឡង[5] ។




តារាងទី១០

5 http://blog.seuksa.com/2012/08/cambodia-2012-bacii-exam-survey/

ពិន្ទុទាបក្នុងការស្ទង់មតិយុវជនស្តីពីសុចរិតភាពបានបង្ហាញថា បើទោះជាការលួចចម្លងជា បាតុភូតសុះសាយមួយមែនក្នុងពេលប្រឡង យុវជនមិនសូវជាស្រួលចិត្តប៉ុន្មានទេក្នុងការសារភាពថាបាន ប្រព្រឹត្តបែបនោះ។ ចំណុចនេះអាចយកទៅបកស្រាយបានថា បើទោះជាវាសុះសាយមែន ការលួចចម្លង នៅសាលាមិនត្រូវបានគេមើលឃើញថាជាទង្វើទទួលយកបាននោះទេ។ ការលួចចម្លង និងការសូកប៉ាន់ បានក្លាយទៅជាមធ្យោបាយមួយដើម្បីធានាភាពជឿជាក់ក្នុងខ្លួនរបស់សិស្សឆ្ពោះទៅប្រលងជាប់ មកទល់នឹង ឆ្នាំ ២០១៣។ នៅឆ្នាំ ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា (ដោយរួមសហការជាមួយអង្គភាពប្រឆាំងពុករលួយ) បានផ្តួចផ្តើមនិងដាក់ឲ្យអនុវត្តន៍នូវកម្មវិធីត្រួតពិនិត្យតាមដានការប្រឡងទូទាំងប្រទេសមួយ ដើម្បីលប់បំបាត់ ការលួចចម្លង និងការសូកប៉ាន់ក្នុងពេលប្រឡងវិញ្ញាសារបញ្ចប់វិទ្យាល័យ ដែលលទ្ធផលរបស់វាជាកត្តាកំណត់ ថាតើអ្នកដែលចូលប្រឡងអាចនឹងចូលទៅបន្តការសិក្សានៅតាមសាកលវិទ្យាល័យឬអត់។ ជាលទ្ធផលនៃគំនិត ផ្តួចផ្តើមនេះ មានតែ ២៥,៧៣ ភាគរយប៉ុណ្ណោះនៃសិស្ស ២៣.១២៦ នាក់ ដែលចូលប្រឡង បានប្រឡងជាប់[6] ។

## ការសុំឯកសារ

សេណារីយោបន្ទាប់ផ្តោតលើការសុំឯកសារ។ យុវជនត្រូវបានគេសួរថា ក្នុងករណីដែលអ្នកត្រូវធ្វើឯកសារ ដូចជាបណ្ណបើកបរជាដើម ហើយអ្នកទទួលបន្ទុករឿងនេះនិយាយថាវាស៊ីពេលយូរទម្រាំធ្វើបណ្ណនោះបាន តើពួកគេនឹងឆ្លើយយ៉ាងម៉េចត្រឡប់ទៅវិញ។ អំពើពុករលួយក្នុងការផ្តល់សេវាកម្មសាធារណៈជាបញ្ហាមួយនៅ ប្រទេសកម្ពុជា ដែលត្រូវបានសិក្សាមើលដែរនៅកន្លែងផ្សេងទៀតនៃរបាយការណ៍នេះ ហើយការធ្វើបណ្ណបើកបរក៏ជាបញ្ហាមួយដែលគេចមិនផុតពីរឿងអំពើពុករលួយដែរ។ ជប់មួយភាគរយនៃអ្នកឆ្លើយបានរាយការណ៍ឲ្យដឹងថា ពួកគេនឹងបង់ដោយផ្ទាល់តែម្តងនូវប្រាក់បន្ថែមក្រៅផ្លូវការដើម្បីពន្លឿនដំណើរការទទួលបានឯកសារមួយ។ បន្ថែមលើនោះ ១៦ ភាគរយនិយាយថា ពួកគេនឹងហៅមិត្តភ័ក្រ្ត ឬសាច់ញាតិ ឲ្យជួយអន្តរាគមន៍ក្នុងដំណើរការនេះ។ មានតែ ២២ ភាគរយទេដែលនិយាយថាពួកគេនឹងរង់ចាំ។ អ្នកដែលចាត់ទុកខ្លួនឯងថាមានគ្រាន់បើរដែរនោះ មានទំនោរឆាប់ចូលប្រឡូកក្នុងសកម្មពុករលួយដើម្បីពន្លឿន ដំណើរការចុះបញ្ជី ច្រើនជាងអ្នកដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ។

តើអ្នកនឹងធ្វើដូចម្តេចបើសិនអ្នកត្រូវការធ្វើឯកសារ ហើយអ្នកទទួលបន្ទុកប្រាប់ថាពិបាកធ្វើឯកសារ ហើយត្រូវការរយៈពេលច្រើនសប្តាហ៍?




តារាងទី១១

6 http://www.moeys.gov.kh/kh/press-releases.html

### ករណីសិក្សាទី ២៖ រំលងច្បាប់ដើម្បីបានប័ណ្ណបើកបរ "បើមិនសូកលុយគេ ប្រឡងប៉ុន្មានដងក៏ប្រហែលជាមិនជាប់ដែរ"

នៅកម្ពុជា មុនដំបូងគេត្រូវឆ្លងកាត់វគ្គរៀនបើកបរ ហើយបន្ទាប់មកគេត្រូវប្រលងតេស្តឲ្យជាប់សិន ដើម្បីទទួលបានប័ណ្ណបើកបរទោចក្រយានយន្ត ឬរថយន្ត។ ប៉ុន្តែជាក់ស្តែង មិនមែនអ្នកបើកបរទាំងអស់សុទ្ធតែឆ្លងកាត់ដំណើរការបែបនេះទេ។ អ្នកខ្លះគ្រាន់តែទិញប័ណ្ណបើកបរនោះតែម្តង។

បញ្ហានេះ ត្រូវបានលើកយកចុះផ្សាយយ៉ាងសុះសាយដោយប្រព័ន្ធផ្សព្វផ្សាយនានា។ យោងតាមកាសែត Phnom Penh Post គេអាចទិញប័ណ្ណបើកបររថយន្តមួយពីមន្ត្រីទទួលបន្ទុករឿងនេះក្នុងតម្លៃពី ២២០ ដុល្លារ ទៅ ២៥០ ដុល្លារ អាមេរិក ក្នុងឆ្នាំ ២០០៧។ សំណូកបែបនេះធ្វើឲ្យអ្នកទិញអាចរំលងសាលារៀនបើកបរ និងការធ្វើតេស្ត[1] ។ "សុំតែរូបថតមួយសន្លឹក និងលុយមកបានហើយ។ យើងនឹងរៀបចំឲ្យមួយចប់តែម្តង" មន្ត្រីម្នាក់នៅអគ្គនាយកដ្ឋាន ដឹកជញ្ជូននៃក្រសួងសាធារណៈការ និងដឹកជញ្ជូន ត្រូវបានកាសែតដកស្រង់សម្តីនិយាយដូច្នេះ[2] ។

ការអនុវត្តបែបនេះទំនងជាមិនបានផ្លាស់ប្តូរប៉ុន្មានទេតាំងពីពេលនោះមក។ នៅឆ្នាំ ២០១១កាសែតដដែលនេះបានសម្ភាសន៍យុវជនមួយចំនួនដែលនិយាយថាពួកគេបាន "ទិញ" ប័ណ្ណបើកបររបស់ពួកគេ។ សិស្សម្នាក់អាយុ ២១ ឆ្នាំ បានសារភាពថា គាត់មិនសូវដឹងច្បាប់ចរាចរណ៍ទេ ជាមួយនឹងហេតុផលថា "ខ្ញុំមិនមែនជាមនុស្សតែម្នាក់ទេ (ដែលទិញប័ណ្ណបើកបរនោះ)"។ គាត់និយាយថា មិត្តរបស់គាត់ក៏ទិញដែរ[3] ។

នៅឆ្នាំ ២០១៤ ក្រុមស្រាវជ្រាវមួយរបស់តម្លាភាពកម្ពុជាបានរកឃើញថាការទិញប័ណ្ណបើកបរនៅតែកើតមានដដែល។ ច្រើននាក់នៃអ្នកដែលត្រូវបានសម្ភាសន៍ និយាយថាពួកគេដឹងថាការធ្វើបែបនេះវាខុស ហើយថាប្រព័ន្ធធ្វើប័ណ្ណ នេះវាពុករលួយ ដូច្នេះដែលពួកគេគ្មានជម្រើសទេ។ យុវនារីម្នាក់និយាយថា "ខ្ញុំទិញប័ណ្ណបើកបរកាលពីប៉ុន្មានខែមុន ហើយប្តីខ្ញុំទិញកាលពីប៉ុន្មានឆ្នាំមុន។ បើមិនសូកលុយគេ ប្រឡងប៉ុន្មានដងក៏ប្រហែលជាមិនជាប់ដែរ ឬបើមិនអញ្ចឹងទេប្រហែលជាត្រូវរង់ចាំរាប់ឆ្នាំទើបបាន"។

1 Cheang Sokha. "Express service' skirts new driving license law". *The Phnom Penh Post*. 1 November 2007. http://www.phnompenhpost.com/national/express-service-skirts-new-driving-license-law
2 Ibid
3 Kim Samath and Ngor Menghourng."Driving school difficulties". *The Phnom Penh Post*. 11 May 2011. http://www.phnompenhpost.com/lift/driving-school-difficulties

## ចូលរៀននៅសាលាឬសាកលវិទ្យាល័យល្អ ឬធ្វើការនៅក្រុមហ៊ុនល្អ

យុវជនត្រូវបានគេបង្ហាញនូវសេណារីយោដូចតទៅ៖ "ពូរបស់អ្នកប្រាប់ថាគាត់មានមិត្តល្អម្នាក់ដែលអាចជួយឲ្យអ្នកចូលរៀននៅសាលា/សាកលវិទ្យាល័យ ឬចូលធ្វើការក្នុងក្រុមហ៊ុនដ៏ល្អមួយយ៉ាងងាយស្រួល ដោយមិនចាំបាច់ឆ្លងកាត់ដំណាក់ជ្រើសរើស"។ តារាងទី ៧ បង្ហាញថា ២១ ភាគរយនៃអ្នកឆ្លើយនិយាយថាពួកគេនឹង និយាយថា "ទេ" តែម្តងនៅពេលដែល ៣១ ភាគរយនៃអ្នកឆ្លើយនិយាយថា ពួកគេនឹងទទួលយកសំណើរនោះ។ ការសិក្សាបន្ថែមទៀតអាចមានប្រយោជន៍ដើម្បីឲ្យយល់ថា ហេតុអ្វីបានជាមានយុវជនច្រើននាក់ម្ល៉េះដែលសុខចិត្តលះបង់សុចរិតភាពរបស់ខ្លួនក្នុងសេណារីយោបែបនេះ។ មូលហេតុគឺអាចមកពីភាពគ្មានការងារធ្វើច្រើនពេក និងការនិយមសន្តានសែស្រឡាយដែលសាយភាយគ្រប់ទីកន្លែងនោះ។ ដូចបានលើកឡើងមុននេះ ភាពគ្មានការងារធ្វើសម្រាប់យុវជនវ័យ ១៥-២០ ឆ្នាំ គឺមានរហូតទៅដល់ ២០ ភាគរយនៅទីក្រុងភ្នំពេញ[7] ។

7 Ibid pg.2

តារាងទី១២

ពូរបស់អ្នកប្រាប់អ្នកថាគាត់មានមិត្តល្អដែលអាចជួយឲ្យអ្នកចូលរៀននៅសាលា/សាកលវិទ្យាល័យ/ក្រុមហ៊ុនដោយងាយស្រួល ដោយមិនបាច់ឆ្លងកាត់ដំណាក់កាលជ្រើសរើស




## ដាក់ពាក្យរកការងារធ្វើ

ជាចុងក្រោយ យុវជនត្រូវបានសួរថាពួកសុខចិត្តកាត់ ១០-២០ ភាគរយនៃប្រាក់ខែរបស់គេទៅឲ្យអ្នកសម្ភាសន៍ការងារទេ បើសិនជាជននោះទារដូច្នេះ។ ក្នុងស្ថានភាពបែបនេះ សឹងតែជិតប្រាំមួយនាក់ក្នុងចំណោម យុវជន ១០ នាក់ និយាយថាពួកគេនឹងយល់ស្របទៅតាមលក្ខខណ្ឌនេះ។ ការកាត់ប្រាក់ខែមួយដុំឲ្យគេជាថ្នូរ ទទួលបានការងារ ជារឿងទូទៅៗហើយនៅប្រទេសកម្ពុជា ជាពិសេសក្នុងវិស័យការងារបែបប្រពលវប្បកម្ម ដូចយ៉ាងរោងចក្រកាត់ដេរជាដើម។ ភាគច្រើននៃកម្មករនៅទីនោះទទួលបានការងារដំបូងតាមរយៈអន្តរការី ឬអ្នករត់ការ ដែលសន្យារកការងារឲ្យពួកគេជាថ្នូរលុយខ្លះ ឬភាគណាមួយនៃប្រាក់ខែរបស់ពួកគេ ហើយមានពេលខ្លះគឺប្រាក់បៀវត្សមួយខែដំបូងរបស់កម្មករតែម្តង បើសិនជាកម្មករទាំងនោះមិនមានលុយបង់ឲ្យ អ្នករត់ការមុនបានការងារ។

តារាងទី១៣

អ្នកនឹងធ្វើដូចម្តេចប្រសិនបើអ្នកដែលសម្ភាសអ្នកទាមទារ១០–២០% នៃប្រាក់ខែអនាគតរបស់អ្នក ?




ដូចបានពិភាក្សាក្នុងករណីសិក្សាខាងក្រោម ការស្រាវជ្រាវនេះបង្ហើបឲ្យដឹងអំពីបញ្ហាធំពីរ៖ ការកេងប្រវ័ញ្ចលើយុវជនពីសំណាក់និយោជក និងការទទួលយករបស់សង្គមនូវទង្វើពុករលួយ។ ការស្រាវជ្រាវបន្ថែម អាចនឹងជួយស្រាយបំភ្លឺថាតើនេះជាបញ្ហាជាមួយយុវជនតែមួយមុខ ឬក៏ជាទម្លាប់អនុវត្តន៍ទូទៅ។ ប្រការដែលថា ជិត ៦០ ភាគរយនៃយុវជននិយាយថាពួកគេសុខចិត្តយល់ស្របបំពេញលក្ខខណ្ឌបែបនោះ ជារឿងមួយគួរឲ្យបារម្ភមែនទែន។

## ករណីសិក្សាទី ៣: ទិញការងារ "បើខ្ញុំមិនធ្វើអញ្ចឹង អ្នកឯទៀតគេធ្វើ"។

សុភាព អាយុ ២៣ ឆ្នាំ ដែលជាអ្នករត់តុនៅភោជនីយដ្ឋានមួយនៅភ្នំពេញ សុខចិត្តកាត់ ១០-២០ ភាគរយ នៃបៀវត្សដែលនាងនឹងទទួលបានដើម្បីឲ្យបានការងារប្រាក់ខែល្អជាងការងារនេះ។ ភាពក្រីក្រ កម្រិតសិក្សាតិចតួចរបស់នាង និងកង្វះជម្រើសការងារ ជាមូលហេតុនៅពីក្រោយចេតនារបស់នាងក្នុងការចូលរួមប្រព្រឹត្តទង្វើបែបនេះ។

នាងពន្យល់ថា "ប្រសិនបើខ្ញុំបានការងារផ្សេងទៀតដែលមានប្រាក់ខែគ្រាន់បើជាងនេះ ខ្ញុំនឹងមិនរួញរានឹងកាត់ឲ្យគេ ១០ ឬ ២០ ភាគរយនៃប្រាក់ខែខ្ញុំទេ។ ខ្ញុំមិនដឹងថាអានឹងគេចាត់ទុកថាជាការសូកប៉ាន់ឬពុករលួយទេ ប៉ុន្តែអ្នកណាក៏ដោយក្នុងស្ថានភាពដូចខ្ញុំនឹងពេញចិត្តនឹងធ្វើដូចតែគ្នាហ្នឹង" ។ នាងបានធ្វើការជាអ្នករត់តុអស់បីឆ្នាំ ហើយនិយាយថាបៀវត្សទាបណាស់ ហើយថាលទ្ធភាពរបស់នាងក្នុងការបានការងារ គ្រាន់បើជាងនេះវាមានកម្រិតណាស់ដោយសារថា នាងអត់មានសញ្ញាបត្រមធ្យមសិក្សាផង កុំថាឡើយ សញ្ញាបត្រសាកលវិទ្យាល័យ។

ភារ៉ា អាយុ ៣០ ឆ្នាំ ដែលបានបញ្ចប់ការសិក្សាកម្រិតសាកលវិទ្យាល័យ និយាយថាគាត់ធ្លាប់សូកគេដើម្បីបានការងារធ្វើ។ "ពិតហើយខ្ញុំដឹងថាវាខុសក្រមសីលធម៌ ប៉ុន្តែការងារនោះបានប្រាក់ខែច្រើនមែនទែន ហើយបើខ្ញុំមិនធ្វើអញ្ចឹង អ្នកឯទៀតគេធ្វើ"។

សម្រាប់សុភាពនិងភារ៉ា វាមិនសំខាន់ទេថាតើទង្វើបែបនេះគួរចាត់ទុកថាជាការសូកប៉ាន់ ឬក៏អត់ សីលធម៌ ឬអសីលធម៌នោះ។ ផ្ទុយទៅវិញ អ្វីដែលសំខាន់សម្រាប់ពួកគេគឺនៅត្រង់ថា វាជាទម្លាប់សង្គម ទទួលយកបាន ហើយអ្នកប្រព្រឹត្តរួចខ្លួនរហូត។

## ឥទ្ធិពលលើយុវជន

ការស្ទង់មតិនេះសួរអ្នកឆ្លើយថាតើនរណាមានឥទ្ធិពលលើទស្សនៈរបស់ពួកគេអំពីសុចរិតភាព។ សំណួរត្រូវបានបំបែកជាផ្នែក ថាតើមានអ្នកណាផ្តល់ព័ត៌មាននិងសារដើម្បីលើកស្ទួយសុចរិតភាព អ្នកណាដែលជាគំរូល្អៗស្តីពីសុចរិតភាព និងអ្នកណាជាទូទៅដែលមានឥទ្ធិពលមកលើទស្សនៈរបស់គេស្តីពីសុចរិតភាព។ សំណួរតាមដានបន្តមកទៀតសួរពួកគេថាតើពួកគេធ្លាប់ទទួលបានការអប់រំស្តីពីសុចរិតភាពទេ ឬស្តីពីកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយនៅសាលា ឬនៅកន្លែងណាមួយទេ។

ក្រុមគ្រួសារត្រូវបានគេមើលឃើញថាជាឧទាហរណ៍ល្អមួយនៃសុចរិតភាព និងមានឥទ្ធិពលខ្លាំងបំផុតមកលើយុវជន។ សឹងតែទាំងអស់គឺ ៩៩ ភាគរយនៃយុវជននិយាយថាក្រុមគ្រួសាររបស់គេជាអ្នកផ្តល់គំរូល្អៗ ស្តីពីសុចរិតភាព ហើយ ៩៤ ភាគរយនិយាយថាក្រុមគ្រួសាររបស់គេផ្តល់ព័ត៌មាន និងសារដែលលើកស្ទួយសុចរិតភាព។ ក្រុមគ្រួសារនៅកម្ពុជាមានលក្ខណៈចាក់ស្រេះខ្លាំងណាស់ ហើយការទុកចិត្តក្នុងរង្វង់គ្រួសារ ក៏ខ្លាំងណាស់ដែរ។

តារាងទី១៨



យុវជនក៏និយាយដែរថា ប្រព័ន្ធផ្សព្វផ្សាយមានឥទ្ធិពលខ្លាំងមកលើពួកគេ៖ ក្នុងន័យនេះទិន្នន័យបានបង្ហាញថា ៩៤ ភាគរយនៃអ្នកដែលត្រូវបានអង្កេតយល់ស្របថា ប្រព័ន្ធផ្សព្វផ្សាយបានផ្តល់ព័ត៌មាននិងបញ្ជូនសារដើម្បីលើកស្ទួយសុចរិតភាព។ ចំនួនដូចគ្នានេះក៏បានរាយការណ៍ឲ្យដឹងដែរថា ប្រព័ន្ធផ្សព្វផ្សាយបានផ្តល់ នូវគំរូល្អៗស្តីពីសុចរិតភាព។ ទោះជាដូច្នោះមែន ១៦ ភាគរយនិយាយថាប្រព័ន្ធផ្សព្វផ្សាយមិនបានមានឥទ្ធិពល អ្វីមកលើទស្សនៈរបស់ពួកគេអំពីសុចរិតភាពឡើយ។ កាលណាយើងបំបែកប្រព័ន្ធផ្សព្វផ្សាយទៅជា សមាសភាគរៀងៗខ្លួន វិទ្យុនិងទូរទស្សន៍គឺមានឥទ្ធិពលជាងគេ។ សឹងតែ ៥០ ភាគរយនៃយុវជនទាំងអស់ដែលត្រូវបានស្ទង់មតិនិយាយថាពួកគេមិនដែលអានកាសែតទេ ស្របជាមួយនោះ ៧០ ភាគរយមិនដែលប្រើប្រាស់អ៊ីនធឺណិតទេ។ ការប្រើប្រាស់អ៊ីនធឺណិតនៅមានកំហិតណាស់ក្នុងប្រទេស ជាពិសេសនៅតាមតំបន់ជនបទ។

មេដឹកនាំកាន់តែមានឥទ្ធិពលតិចទៅទៀតមកលើយុវជន គឺតិចជាងពីសំណាក់ក្រុមគ្រួសារធំៗរបស់គេ ឬក៏ប្រព័ន្ធផ្សព្វផ្សាយទៅទៀត។ ក្នុងន័យនេះ ១៤ ភាគរយនៃយុវជនដែលត្រូវបានអង្កេតនិយាយថា អាកប្បកិរិយារបស់មេដឹកនាំ រួមមានទាំងឥស្សរជននយោបាយ និងសាសនា មិនបានផ្តល់គំរូល្អអំពីសុចរិតភាពទេ។ បន្ថែមលើនោះ ១៩ ភាគរយនៃអ្នកដែលបានអង្កេត និយាយថាបណ្តាមេដឹកនាំមិនបានជះឥទ្ធិពលមកលើ ទស្សនៈរបស់គេស្តីពីសុចរិតភាពទេ។

## ការអប់រំអំពីសុចរិតភាព

យុវជនត្រូវបានចោទសួរអំពីឥទ្ធិពលនៃប្រព័ន្ធអប់រំ។ សំណួរដោយឡែកមួយបានសួរថាតើអ្នកឆ្លើយ ធ្លាប់បានទទួលការអប់រំអ្វីទេ ឬក៏ធ្លាប់បានចូលរួមក្នុងកម្មវិធីជាក់លាក់អ្វីមួយស្តីពីសុចរិតភាព ឬកិច្ចខិតខំប្រឆាំងពុករលួយនៅតាមសាលារៀន ឬស្ថាប័នណាមួយ ឬអត់។ ភាគច្រើនលើសលុប គឺ ៩២ ភាគរយ និយាយថាប្រព័ន្ធអប់រំបានផ្តល់ព័ត៌មាននិងបញ្ជូនសារដែលលើកស្ទួយសុចរិតភាព។ ប៉ុន្តែកាលណាត្រូវបានគេឈ្លេចសួរឲ្យបានជាក់លាក់បន្តិចជាងនេះ មានតែ ៣២ ភាគរយនៃអ្នកឆ្លើយប៉ុណ្ណោះដែលនិយាយថា ពួកគេបានទទួលការអប់រំក្នុងកម្រិតណាមួយ ឬក៏តាមដានត្រងត្រាប់ពីកម្មវិធីណាមួយស្តីពីសុចរិតភាព ឬកិច្ចប្រឹងប្រែងប្រឆាំងពុករលួយនៅសាលារៀន។ បើទោះជាលទ្ធផលទាំងនេះទំនងជាបញ្ហាសគ្នាក្តី នេះប្រហែលមកពីការប្រែជាភាសាខ្មែរនៃពាក្យ "សុចរិតភាព" ក្នុងការស្ទង់មតិ ដែលពាក្យនេះអាចត្រូវគេបកស្រាយទៅជាមានន័យថា យុវជនកំពុងទទួលបានព័ត៌មានអំពីសីលធម៌ក្នុងសាលារៀនទៅវិញ ពោលគឺមិនមែនអំពីការធ្វើទង្វើប្រកបដោយសុចរិតភាព ក្នុងន័យប្រឆាំងអំពើពុករលួយទេ។

ក្នុងសំណួរបន្ទាប់មកទៀត យុវជនក៏ត្រូវបានសួរដែរថា តើព័ត៌មានប៉ុន្មានដែលពួកគេបានទទួលអំពី ច្បាប់និងបទប្បញ្ញត្តិនានារបស់រដ្ឋាភិបាលដើម្បីលើកស្ទួយសុចរិតភាពនិងទប់ស្កាត់អំពើពុករលួយ។ ក្នុងន័យនេះ ៧១ ភាគរយរាយការណ៍ឲ្យដឹងថាពួកគេមិនទទួលបាន ឬទទួលបានតិចតួចបំផុតព័ត៌មានអំពីចំណុចទាំងនេះ។

តារាងទី១៩

ចំណេះដឹងអំពីច្បាប់និងបទបញ្ញត្តិរបស់រដ្ឋាភិបាលក្នុងការ លើកស្ទួយសុចរិតភាព និងបង្ការអំពើពុករលួយ



លើសពីនេះ ដូចបានបង្ហាញក្នុងតារាង ១៥ ជិតពាក់កណ្ដាលនៃអ្នកដែលនិយាយថាមិនទទួលបាន ឬក៏ទទួលបានតិចតួចបំផុតព័ត៌មានស្ដីពីពុករលួយ មិនបានរៀនចប់កម្រិតបឋមសិក្សាទេ។ បើពិចារណាទៅលើសំណាកដើមដែលក្នុងនោះ ៤១ ភាគរយនៃយុវជនមិនបានរៀនហួសកម្រិតបឋមសិក្សា វាជារឿងមួយគួរឲ្យព្រួយបារម្ភការដែលយុវជនជាច្រើនមិនបានដឹងអំពីកិច្ចខិតខំរបស់រដ្ឋាភិបាលដើម្បីលើកកម្ពស់សុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។

តារាងទី១៦

កម្រិតនៃព័ត៌មានពីច្បាប់និងបទបញ្ញត្តិរបស់រដ្ឋាភិបាលក្នុងការលើកស្ទួយ និងបង្ការអំពើពុករលួយ




## កម្រិតការប្តេជ្ញាចិត្តប្រឆាំងអំពើពុករលួយ

សម្រាប់ការងារតស៊ូមតិជាមួយយុវជនទៅថ្ងៃមុខ វាមានសារៈសំខាន់ជាសារវន្តក្នុងការស្វែងយល់នូវចេតនានិងការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការប្រឆាំងពុករលួយ។ មុនដំបូង យុវជនត្រូវបានចោទសួរថាតើពួកគេមានចេតនារាយកាណ៍ពីអំពើពុករលួយឬទេ។ បន្ទាប់មក ពួកគេត្រូវបានស្នើឲ្យរើសយកថាតើតួនាទី ណាមួយដែលពួកគេជឿថាយុវជនអាចធ្វើបានក្នុងសកម្មភាពកសាងសុចរិតភាព។ ជាចម្លើយ ៦៧ ភាគរយនៃ អ្នកដែលត្រូវបានអង្កេតបានរាយការណ៍ថាពួកគេមានចេតនារាយការណ៍ពីអំពើពុករលួយ។ ក្នុងចំណោមនេះប្រាំបីភាគរយនិយាយថា ពួកគេមិនត្រឹមតែនឹងរាយការណ៍អំពើពុករលួយទេ តែពួកគេបានចាប់ផ្ដើមធ្វើរួចមកហើយ។ កម្រិតប្តេជ្ញាចិត្តខ្ពស់បែបនេះក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយជាសញ្ញាមួយគួរឲ្យលើកទឹកចិត្ត។ បន្ថែមលើនោះ ៩០ ភាគរយនៃអ្នកដែលត្រូវបានស្ទង់មតិនិយាយថាពួកគេជឿថា យុវជនអាចដើរតួយ៉ាងសំខាន់ក្នុងការកសាងសុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។

តារាងទី១៧

ការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ



សម្រាប់ ៣៣ ភាគរយនៃយុវជនដែលនិយាយថាពួកគេច្បាស់ជានឹង ឬប្រហែលជានឹងមិនរាយការណ៍ អំពីអំពើពុករលួយទេនោះ ហេតុផលមានផ្សេងៗគ្នា។ ការភ័យខ្លាចថាមានការធ្វើទុកបុកម្នេញជាមូលហេតុចម្បងមួយ ដោយក្នុងនោះ ៣០ ភាគរយនិយាយថា ពួកគេខ្លាចអត់មានអ្វីការពារខ្លួនគេ។ ម្ភៃប្រាំភាគរយទៀតនិយាយ ថាពួកគេនឹងមិនរាយការណ៍អំពីពុករលួយទេដោយសារថា រាយការណ៍ទៅអត់បានប្រសិទ្ធភាពអ្វីទេ ជាមួយនោះភាគរយប្រហាក់ប្រហែលគ្នានេះដែរ (២៤ ភាគរយ) និយាយថាកង្វះចំណេះដឹងអំពីនីតិវិធីធ្វើសេចក្ដីរាយការណ៍ជាមូលហេតុចម្បង។ ម្ភៃមួយភាគរយផ្សេងទៀតនិយាយថា វាមិនមែនជាកាតព្វកិច្ចរបស់ពួកគេទេដែលត្រូវរាយការណ៍ពីអំពើពុករលួយនោះ។ ទំនុកចិត្តទាបទៅលើរដ្ឋាភិបាល និងអវត្តមានច្បាប់ សម្រាប់ការពារអ្នករាយការណ៍អំពីអំពើពុករលួយ អាចជាមូលហេតុមួយក្នុងចំណោម មូលហេតុនានានៅពីក្រោយការភ័យខ្លាចរបស់យុវជនក្នុងការរាយការណ៍ពីអំពើពុករលួយ ឬក៏ធ្វើជាសាក្សី ក្នុងករណីអំពើពុករលួយណាមួយ។




តារាងទី១៨

# ការពិភាក្សា៖ ការប្រៀបធៀបជាលក្ខណៈតំបន់

ការស្ទង់មតិយុវជនស្តីពីសុចរិតភាពត្រូវបានធ្វើឡើងនៅ១០ ប្រទេសផ្សេងទៀតជុំវិញពិភពលោក។ ថ្មីៗនេះ លេខាធិការដ្ឋានអង្គការតម្លាភាពអន្តរជាតិបានបញ្ចេញរបាយការណ៍តំបន់ស្តីពីការស្ទង់មតិយុវជនស្តីពីសុចរិតភាពយុវជនសម្រាប់ប្រទេស ហ្វីជី ឥណ្ឌូនេស៊ី កូរ៉េខាងត្បូង និងស្រីលង្កា។ បើទោះជាប្រទេសទាំងនេះមានវប្បធម៌ដោយឡែកពីគ្នាក្នុងគ្រប់កម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមយ៉ាងណាក៏ដោយ ក៏ប្រទេសទាំងនេះមានទិដ្ឋភាពរួមមួយ នោះគឺក្រុមប្រជាជនដែលជាយុវជនមានចំនួនច្រើន ហើយកើនឡើងជាលំដាប់ (លើកលែងតែកូរ៉េខាងត្បូងចេញដែលមានចំនួនប្រជាជនជាយុវវ័យច្រើន តែចំនួននោះមិនមែនកំពុងតែកើនទេ)។ ជាលទ្ធផលគេអាចធ្វើការប្រៀបធៀបទិន្នន័យនៅកម្ពុជាជាមួយបណ្តាប្រទេសទាំងនេះបាន។ វាមានសារៈសំខាន់ផងដែរក្នុងការកត់សម្គាល់ថាទម្រង់សំណួរដែលប្រើនៅកម្ពុជាខុសគ្នាទៅនឹងទម្រង់ដែលប្រើនៅប្រទេសផ្សេងទៀត មានន័យថាលទ្ធផលមិនអាចធៀបគ្នាតាមសំណួរនីមួយៗបានទេ។ ក៏ប៉ុន្តែ គេអាចទាញយកបាននូវការប្រៀបធៀបជាទូទៅមួយដែលមានតម្លៃសម្រាប់ស្វែងយល់បន្តទៀតដែរ។

កម្ពុជាមានប្រជាជនវ័យក្មេងច្រើនជាងគេ ដោយក្នុងនោះ ៣៣ ភាគរយនៃប្រជាជនមានអាយុរវាង ១៥ និង ៣០ ឆ្នាំ។ ប្រទេសហ្វីជីនៅលេខរៀងទីពីរ ដោយក្នុងនោះ ២៨ ភាគរយនៃប្រជាជន របស់ខ្លួនមានអាយុក្នុងចន្លោះដូចគ្នានេះ។ ប្រទេសឥណ្ឌូនេស៊ីមានយុវជន ២៥ ភាគរយ នៅស្រីលង្កា ២៣ ភាគរយ ហើយនៅកូរ៉េខាងត្បូង ១៩ ភាគរយ។ លទ្ធផលពីទូទាំងតំបន់ចង្អុលថា បើទោះជាយុវជនកម្ពុជាពើបប្រទះ អំពើពុករលួយច្រើនជាងក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេមែន ពួកគេក៏មានសុទិដ្ឋិនិយមច្រើនជាងទៅលើសមត្ថភាពរបស់ពួកគេក្នុងការនាំមកនូវការផ្លាស់ប្តូរ ហើយក៏មិនសូវជាឲ្យពិន្ទុ "មិនល្អ" ឬ "មិនសូវល្អ" ប៉ុន្មានទេ ទៅលើសសរស្តម្ភនៃសង្គមនានា ទាក់ទិនទៅនឹងបញ្ហាអំពីអំពើពុករលួយនៅក្នុងស្ថាប័នទាំងនោះ ។

នៅឥណ្ឌូនេស៊ី ៥៧ ភាគរយនៃប្រជាជនវ័យក្មេងធ្លាប់ជួបប្រទះអំពើពុករលួយដើម្បីបញ្ចៀសបញ្ហា ជាមួយនគរបាល ហើយច្រើនជាងមួយក្នុងចំណោមប្រាំនាក់នៅប្រទេសហ្វីជី កូរ៉េខាងត្បូង និងស្រីលង្កា ក៏ធ្លាប់ឆ្លងបទពិសោធន៍អំពើពុករលួយក្នុងការដោះស្រាយបញ្ហាជាមួយនគរបាល។ នៅកម្ពុជា ក្នុងចំណោមអ្នកដែលធ្លាប់មានបញ្ហាជាមួយនគរបាលក្នុងអំឡុង ១២ ខែមុនពេលធ្វើស្ទង់មតិនេះ ចំនួនលេចធ្លោ៦៩ភាគរយបាននិយាយថាពួកគេធ្លាប់ឆ្លងកាត់អំពើពុករលួយដើម្បីចៀសវាងបញ្ហា។លើសពីនោះបើទោះជាភាគរយនៃប្រជាជនវ័យក្មេងដែលធ្លាប់ឆ្លងកាត់អំពើពុករលួយជាមួយនគរបាលនៅកូរ៉េខាងត្បូង និងស្រីលង្កា មានតិចជាង នៅកម្ពុជាក្តី ៦០ ភាគរយនៃយុវជននៅប្រទេសទាំងពីរនេះជឿថា នគរបាលនិងកងកម្លាំងសន្តិសុខ "ល្អ" ឬ "មិនសូវល្អ" បើគិតអំពីបញ្ហាពុករលួយ បើធៀបទៅនឹង ៤៨ ភាគរយនៅប្រទេសកម្ពុជា។ បើទោះជាមានយុវជនកម្ពុជាច្រើននាក់ជាងដែលធ្លាប់ឆ្លងកាត់អំពើពុករលួយក្នុងដោះស្រាយបញ្ហាជាមួយនគរបាលក្តី ពួកគេហាក់បីដូចជាមិនសូវមានទំនោរពិពណ៌នាពួកនគរបាលថាពុករលួយដូចយុវជននៅប្រទេសដទៃទៀតទេ។ មូលហេតុមួយប្រហែលជាមកពីថា យុវជនខ្លះនៅកម្ពុជាគិតថា ទម្រង់ខ្លះនៃអំពើពុករលួយក្នុងជួរនគរបាល ជាមធ្យោបាយមានប្រយោជន៍មួយសម្រាប់ដោះស្រាយបញ្ហា ជាជាងគិតថាការអនុវត្តបែបនេះវាជាបញ្ហាទៅវិញ។

យុវជនកម្ពុជាមានសុទិដ្ឋិខ្លាំងអំពីលទ្ធភាពរបស់ពួកគេក្នុងការនាំមកនូវការប្រែប្រួល ហើយនិយាយថា ពួកគេមានចេតនានឹងរាយការណ៍ពីអំពើពុករលួយ។ ក្នុងនោះ ៩០ ភាគរយនៃអ្នកដែលត្រូវបានអង្កេតនិយាយថា យុវជនអាចដើរតួសំខាន់មួយក្នុងការកសាងសុចរិតភាព និងប្រឆាំងអំពើពុករលួយ។ តួលេខនេះមានសង្គតិភាព ជាមួយនឹងតួលេខនៅប្រទេសដទៃក្នុងតំបន់ដែរ៖ ៩២ ភាគរយនៃយុវជនស្រីលង្កាយល់ស្របថាពួកគេអាចដើរតួសំខាន់មួយក្នុងការលើកកម្ពស់សុចរិតភាព ហើយនៅប្រទេសហ្វីជីមាន ៨៩ ភាគរយ ឥណ្ឌូនេស៊ី ៨៩ ភាគរយ និងកូរ៉េខាងត្បូង ៨១ ភាគរយ។ មានតែប្រទេសហ្វីជីទេដែលឲ្យដឹងថាមានភាគរយខ្ពស់នៃយុវជនដែលនឹងមាន ចេតនារាយការណ៍ពីអំពើពុករលួយ (៧៥ភាគរយ) ច្រើនជាងនៅកម្ពុជា (៦៩ ភាគរយ)។ នៅកូរ៉េខាងត្បូង មាន ៥៩ ភាគរយ ហើយស្រីលង្កាមានតែ ៣៩ ភាគរយតែប៉ុណ្ណោះ។

ទោះជាយុវជនកម្ពុជាមានសុទិដ្ឋិនិងរីករាយសាទរអំពីការកសាងសុចរិតភាពក្តី ៧១ ភាគរយនៃអ្នកដែល ត្រូវបានអង្កេតនិយាយថាពួកគេមិនទទួលបានព័ត៌មាន ឬទទួលបានព័ត៌មានតិចតួចមែនទែនអំពីច្បាប់និងបទប្បញ្ញត្តិនានារបស់ រដ្ឋាភិបាលដើម្បីលើកកម្ពស់សុចរិតភាពនិងប្រយុទ្ធប្រឆាំងអំពើពុករលួយ។ នេះជាបាតុភូតមួយទូទាំងតំបន់តែម្តង ដោយក្នុងនោះ ៧៤ ភាគរយនៃយុវជនកូរ៉េខាងត្បូងនិយាយថាពួកគេមិនមានព័ត៌មាន ឬមានព័ត៌មានតិចតួចមែនទែន បន្ទាប់មក ៦៦ ភាគរយនៅហ្វីជី ៥៥ ភាគរយនៅស្រីលង្កា និង ៥០ ភាគរយនៅឥណ្ឌូនេស៊ី។ បើចង់ឲ្យយុវជនក្លាយខ្លួនជាភ្នាក់ងារសម្រាប់ការផ្លាស់ប្តូរក្នុងសង្គមបាន ពួកគេចាំបាច់ត្រូវតែទទួលព័ត៌មានអំពីវិធាន និងបញ្ញត្តិនានាដែលកំពុងមានអត្ថិភាពឲ្យបានគ្រប់គ្រាន់។

# សេចក្តីសន្និដ្ឋាន

មានសេចក្តីសន្និដ្ឋានមួយចំនួនដែលអាចទាញចេញបានពីការស្ទង់មតិនេះ។

ទីមួយ បើទោះជាយុវជនហាក់ដូចជាយល់ច្បាស់ថាទម្លាប់ពុករលួយជាច្រើនជាទង្វើខុសក៏ដោយ ពួកគេនៅតែចាត់ទុកថាអាកប្បកិរិយាបែបនោះអាចទទួលយកបាន ហើយពួកគេក៏ត្រៀមខ្លួនជាស្រេចដែរ ថានឹងចូលប្រឡូកពាក់ព័ន្ធក្នុងទង្វើទាំងនោះ។ យុវជនមានទំនោរទៅរកការលះបង់សុចរិតភាពរបស់ខ្លួន និង ប្រឡូកក្នុងការអនុវត្តបែបពុករលួយដែរ នៅពេលណាគេចាត់ទុកថាទង្វើទាំងនោះវាតូចតាច ឬជាទម្លាប់ទូទៅ។ ការត្រៀមខ្លួនជាស្រេចរបស់ពួកគេក្នុងការបំពានសុចរិតភាពដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ប្រហែលជាទទួលឥទ្ធិពលពីសង្គមកម្ពុជាដែលទទួលយកយ៉ាងសាយភាយនូវអំពើពុករលួយ។

ទីពីរ យុវជនចាត់ទុកថាអំពើពុករលួយជាបញ្ហាធំមួយសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ ពួកគេក៏គិតដែរថា អំពើពុករលួយកើតមាននៅក្នុងស្ថាប័ននានារបស់រដ្ឋ ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ មួយភាគធំនៃយុវជនបានរាយការណ៍ឲ្យដឹងថាធ្លាប់បានឆ្លងកាត់អំពើពុករលួយក្នុងអំឡុងឆ្នាំមុននឹងមាន ការអង្កេតនេះ ជាពិសេសញឹកញាប់នៅពេលដែលត្រូវដោះស្រាយបញ្ហាជាមួយនគរបាល សុំឯកសារ ឬបណ្ណអនុញ្ញាត ឬមួយក្នុងពេលប្រលងនៅសាលា។

ទីបី ក្រុមគ្រួសារ ប្រព័ន្ធអប់រំ និងប្រព័ន្ធផ្សព្វផ្សាយ ជាប្រភពចម្បងនៃព័ត៌មានស្តីពីសុចរិតភាពសម្រាប់យុវជន និងមានឥទ្ធិពលធំជាងគេទៅលើពួកគេ។ តែយ៉ាងណាក្តី ភាគច្រើននៃយុវជនទទួលបានព័ត៌មានតិចតួច ឬមិនទទួលបានព័ត៌មានទាល់តែសោះអំពីវិធាន និងបញ្ញត្តិនានារបស់រដ្ឋាភិបាលសម្រាប់លើកកម្ពស់សុចរិតភាព និងទប់ស្កាត់អំពើពុករលួយ។ មានប្រហែលតែមួយភាគបីនៃយុវជនប៉ុណ្ណោះដែលនិយាយថា ពួកគទទួលបានការអប់រំ ជាក់លាក់អំពីសុចរិតភាព ឬ អំពីកិច្ចខិតខំប្រឆាំងពុករលួយ នៅតាមសាលារៀន។

ចុងក្រោយបង្អស់ យុវជនជឿថាពួកគេអាចដើរតួនាទីសំខាន់មួយក្នុងការកសាងសុចរិតភាព និង ប្រយុទ្ធប្រឆាំងអំពើពុករលួយតាមរយៈការតស៊ូមតិ និងការផ្លាស់ប្តូរឥរិយាបថ។ ភាគច្រើននៃពួកគេមានចេតនាត្រៀម ខ្លួនជាស្រេចនឹងរាយការណ៍ពីអំពើពុករលួយកាលណាពួកគេជួបប្រទះនឹងទង្វើបែបនោះ។ ទោះជាយ៉ាងណា មានមួយភាគតូចក្រៃលែងដែរដែលបានបង្ហាញនូវភាពអល់អែកនឹងរាយការណ៍ពីអំពើពុករលួយ។ ការភ័យខ្លាចថា អត់មានអ្វីការពារខ្លួន ទស្សនៈថារាយការណ៍ពីអំពើពុករលួយនឹងមិននាំផលអ្វីទេ និងកង្វះចំណេះដឹងអំពីនីតិវិធីរាយការណ៍ ទាំងអស់នេះសុទ្ធតែជារបាំងរារាំងយុវជនមិនឲ្យរាយការណ៍ពីអំពើពុករលួយបាន។

# អនុសាសន៍

លទ្ធផលនៃការស្ទង់មតិនេះចង្អុលប្រាប់ថា អំពើពុករលួយដ៏សាយភាយនៅប្រទេសកម្ពុជាបានប៉ះពាល់មកលើជីវិតប្រចាំថ្ងៃរបស់យុវជន។ អ្វីដែលគួរឲ្យកាន់តែបារម្ភថែមទៀតនោះគឺថា វាកំពុងតែបំផ្លាញការយល់ឃើញរបស់ពួកគេអំពីសុចរិតភាព ដែលធ្វើឲ្យពួកគេក្លាយខ្លួនជាជនរងគ្រោះផង និងជាអ្នកចូលរួមប្រព្រឹត្តពុករលួយផងដែរ។ យ៉ាងណាក្តី យុវជនក៏បានបង្ហាញច្បាស់ដែរនូវបំណងចង់ឲ្យឃើញស្ថានភាពនេះមានការផ្លាស់ប្តូរ។ ពួកគេប្រាថ្នាចង់បាននូវសង្គមមួយដែលមានតម្លាភាពនិងគ្មានអំពើពុករលួយ ហើយត្រៀមខ្លួនជាស្រេចដើម្បីចូលរួមក្នុងដំណើរការឆ្ពោះទៅរកគោលដៅនេះ។ ក៏ប៉ុន្តែ ការផ្លាស់ប្តូរស្ថានភាពនេះមិនអាចចាប់ផ្តើមពីយុវជនតែមួយមុខបានទេ។ វាទាមទារឲ្យមានកិច្ចខិតខំធំធេងនិងជាប្រកបដោយចីរភាព ពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសពីសំណាក់រដ្ឋាភិបាល ស្ថាប័នអប់រំ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានារបស់រដ្ឋាភិបាល។ ផ្អែកលើរបកគំហើញនេះ អង្គការតម្លាភាពកម្ពុជាបានបង្ហាញជូននូវអនុសាសន៍ទូលំទូលាយ និងជាក់លាក់មួយចំនួនដើម្បីជួយភាគីពាក់ព័ន្ធទាំងអស់ ក្នុងការតាក់តែងគោលនយោបាយ កម្មវិធី និងយុទ្ធសាស្ត្រ នានាដើម្បីលើកកម្ពស់សុចរិតភាពរបស់យុវជន និងគាំទ្រកិច្ចប្រឹងប្រែងរបស់ពួកគេក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

# អនុសាសន៍គន្លឹះ

## សម្រាប់រដ្ឋាភិបាល៖

### ក្របខណ្ឌច្បាប់៖

- បង្កើតបរិយាកាសអំណោយផលមួយសម្រាប់ឲ្យយុវជនរាយការណ៍ពីអំពើពុករលួយ ដោយកែលំអ យន្តការ ឧបករណ៍និងធនធាននានា ដែលធ្វើឲ្យពួកគេអាចចូលរួមបានក្នុងការប្រឆាំងអំពើពុករលួយ។ ក្នុងនោះគួរមានការអ នុម័តច្បាប់សម្រាប់ ″ការពារអ្នករាយការណ៍អំពីអំពើពុករលួយ″។
- លើកកម្ពស់អភិបាលកិច្ចដែលបើកចំហ និងមានតម្លាភាពតាមរយៈការទទួលបានព័ត៌មានរដ្ឋដោយប្រសិទ្ធភាព។ ចំណុចនេះរួមមានការបង្កើតច្បាប់សិទ្ធិទទួលបានព័ត៌មាន ដែលស្របទៅនឹងស្តង់ដារអន្តរជាតិ។
- លើកកម្ពស់ និងពង្រឹងសេរីភាពបញ្ចេញមតិ ជាពិសេសក្នុងចំណោមយុវជន ដោយធានាថាច្បាប់ឧក្រិដ្ឋកម្មអ៊ិនធើណិត អនុលោមទៅតាមស្តង់ដារអន្តរជាតិ ហើយមិនប៉ះពាល់ដល់សេរីភាពបញ្ចេញមតិដែលការពារដោយរដ្ឋធម្មនុញ្ញ។

### ការអប់រំ ការទប់ស្កាត់ និងការលើកកម្ពស់ការយល់ដឹងស្តីពីអំពើពុករលួយ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ៖

- ក្រសួងអប់រំ យុវជន និងកីឡា គួររៀបចំឲ្យមានកម្មវិធីសិក្សាជាក់លាក់ស្តីពីការប្រឆាំងអំពើពុករលួយ ហើយបញ្ជ្រាបកម្មវិធីទាំងនេះទៅក្នុងគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធអប់រំ ពីបឋមសិក្សា រហូតដល់សាកលវិទ្យាល័យ។
- ធានាឲ្យបានថាប្រព័ន្ធអប់រំជាតិ (ដែលជាកត្តាមួយក្នុងចំណោមកត្តាមានឥទ្ធិពលខ្លាំងជាងគេលើ សុចរិតភាពដូចដែលអ្នកឆ្លើយបានលើកឡើង) គ្មានភាពពុករលួយ ដោយតម្លើងបៀវត្សរ៍គ្រូ កែលំអ ដំណើរការជ្រើសរើសបុគ្គលិក និងកែទម្រង់ប្រព័ន្ធគ្រប់គ្រងសាលារៀន។
- ធ្វើអាទិភាពកិច្ចខិតខំកែលំអវិស័យសាធារណៈសំខាន់ៗមួយចំនួនដែលយុវជនអាចនឹងប្រឈមមុខនឹងអំពើពុករលួយ ដូចជាផ្នែកអនុវត្តន៍ច្បាប់ (ពិសេសនគរបាលចរាចរ) ផ្នែកសុខាភិបាល និង ភ្នាក់ងាររដ្ឋផ្សេងៗទៀតដែលទទួលខុសត្រូវក្នុងការផ្តល់ឯកសារ ដូចជា សំបុត្រកំណើត អត្តសញ្ញាណបណ្ណ និងបណ្ណបើកបរ។
- បង្កើតកម្មវិធីជាតិមួយដើម្បីលើកកម្ពស់គំរូសុចរិតភាពសម្រាប់យុវជន ឧទាហរណ៍ តាមរយៈ កម្មវិធីរង្វាន់សុចរិតសាធារណៈ និងកិច្ចផ្តួចផ្តើមបណ្តុះបណ្តាលយុវជនជាមេដឹកនាំ។
- បង្កើនយុទ្ធនាការប្រឆាំងអំពើពុករលួយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយអប់រំពលរដ្ឋ និងយុវជនអំពីមូលហេតុ និងផលប៉ះពាល់នៃអំពើពុករលួយមកលើសង្គម។ ហើយបង្ហាញប្រាប់ពួកគេនូវការប្តេជ្ញាចិត្ត និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយអំពើពុករលួយ។
- កែលំអយុទ្ធសាស្ត្រនានាដើម្បីឲ្យយុវជនបានជ្រួតជ្រាបអំពីច្បាប់ប្រឆាំងអំពើពុករលួយ និងបញ្ញត្តិ ពាក់ព័ន្ធនានា។ ជាពិសេស គួរបង្កើនធនធានសម្រាប់ការធ្វើយុទ្ធនាការលើក កម្ពស់ការយល់ដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ពិសេសវិទ្យុនិងទូរទស្សន៍ និងតាមបណ្តាញប្រព័ន្ធ ផ្សព្វផ្សាយសង្គមផងដែរ។
- លើកទឹកចិត្ត បង្កើត និងលើកស្ទួយបណ្តាញយុវជន និងផ្តល់អំណាចទៅដល់ពួកគេក្នុងការលើកកម្ពស់ សុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។

## សម្រាប់ស្ថាប័នអប់រំជាន់ខ្ពស់ វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍

- បន្ថែមលើការផ្តល់ជំនាញនិងចំណេះដឹងចាំបាច់ដល់និស្សិត ស្ថាប័នអប់រំជាន់ខ្ពស់ និង សាលា អាជីពឯទៀតគួរផ្តោតផងដែរទៅលើការបង្រៀនហ្វឹកហាត់និស្សិតអំពីភាពចាំបាច់ក្នុងការលើកស្ទួយ សុចរិតភាព និង ក្រមសីលធម៌ក្នុងអាជីពរបស់គេទៅថ្ងៃអនាគត។
- សមាជិកវិស័យឯកជន និង សង្គមស៊ីវិល គួរធានាឲ្យបានថា ដំណើរការជ្រើសរើសបុគ្គលិកទាំងអស់ ត្រូវមានតម្លាភាព គ្មានការសូកប៉ាន់ គ្មានការបង់ប្រាក់សគុណ ឬក៏ក្នុងទម្រង់ផ្សេងទៀតនៃអំពើពុករលួយទេ។
- អង្គការយុវជន ទាំងថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន គួរពិចារណាផ្តួចផ្តើមយុទ្ធនាការសំដៅផ្លាស់ប្តូរ ផ្នត់គំនិតដែលកំពុងមានក្នុងចំណោមយុវជនអំពីអំពើពុករលួយ ឲ្យចាត់ទុកការប្រព្រឹត្តអំពើពុករលួយគ្រប់បែប ក្នុងទិដ្ឋភាពតូចក្តីធំក្តី ថាជាការអនុវត្តខុសច្បាប់ដែលត្រូវតែចៀសវាងឲ្យខានតែបាន។
- សង្គមស៊ីវិលគួរធ្វើការជាមួយយុវជនឲ្យកាន់តែសកម្មថែមទៀត ក្នុងកិច្ចប្រឹងប្រែងដើម្បីលើកកម្ពស់សុចរិតភាព តម្លាភាព និងការប្រឆាំងអំពើពុករលួយ ដោយបញ្ចូលកិច្ចផ្តួចផ្តើមប្រឆាំងអំពើពុករលួយទៅក្នុងកម្មវិធីធ្វើការពាក់ព័ន្ធជាមួយនឹងពលរដ្ឋ និងយុវជនរបស់ខ្លួន។
- អ្នកផ្តល់ជំនួយ ទាំងទ្វេភាគីនិងពហុភាគី គួរធ្វើអាទិភាពវិធានការប្រឆាំងអំពើពុករលួយ និង ការធ្វើការជាមួយយុវជនក្នុងកម្មវិធីយុទ្ធសាស្ត្ររបស់គេ ហើយរម្លែកធនធានបន្ថែមទៀតសម្រាប់អង្គការសង្គមស៊ីវិលយកទៅគាំទ្រដល់ការទាមទារដែលកាន់តែកើនច្រើនឡើង ដើម្បីឲ្យបានសង្គមមួយគ្មានអំពើពុករលួយ។

# ឧបសម្ព័ន្ធ៖
# កម្រងសំណួរ

# កម្រងសំណួរ

## អំពីកម្មវិធីស្ទង់មតិរបស់យុវជនស្តីពីសុចរិតភាព

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ....................................... មកពីអង្គការតម្លាភាពកម្ពុជា។យើងកំពុងធ្វើការស្ទង់មតិរបស់យុវជន ស្តីពីសុចរិតភាពនៅខេត្តក្រុងមួយចំនួននៅក្នុងប្រទេសកម្ពុជា។ ការស្ទង់មតិនេះមានគោលបំណង ស្វែងយល់ឲ្យបានកាន់តែស៊ីជម្រៅ អំពីបទពិសោធន៍និងទស្សនៈរបស់យុវជនស្តីពីបញ្ហា តម្លាភាព និងសុចរិតភាព។ ខ្ញុំបាទ/នាងខ្ញុំ នឹងជជែកអំពីសំណួរមួយចំនួន ហើយសំណួរទាំងអស់នេះមានចម្លើយដែលអាចឲ្យបង/ប្អូនជ្រើសរើសបាន ដោយចម្លើយទាំងនេះពុំមានចម្លើយណាត្រូវ ឬចម្លើយណាខុសទេ។ ការជជែកនេះមានរយៈពេលប្រហែលជា៣០នាទី។

សូមបញ្ជាក់ថារាល់ព័ត៌មានទាំងអស់ដែលបង/ប្អូនបានផ្តល់ជូន នឹងទុកជាការសម្ងាត់។ អត្តសញ្ញាណរបស់បង/ប្អូននឹងមិនត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ឡើយ។ អង្គការតម្លាភាពកម្ពុជានឹងរក្សាសិទ្ធិក្នុងការទុកទិន្នន័យទាំងអស់ជាកម្មសិទ្ធរបស់អង្គការតម្លាភាពកម្ពុជា ក្រោយពេលបញ្ចប់គម្រោងស្ទង់មតិនេះ។

| | |
|---|---|
| ម៉ោងចាប់ផ្តើមសម្ភាសន៍: | ☐☐ ម៉ោង ☐☐ នាទី |
| ម៉ោងបញ្ចប់សម្ភាសន៍: | ☐☐ ម៉ោង ☐☐ នាទី |
| រយៈពេលធ្វើសម្ភាសន៍: | ☐☐ |
| ថ្ងៃខែឆ្នាំ ធ្វើសម្ភាសន៍: | ថ្ងៃទី.............ខែ..............ឆ្នាំ២០១៤ |

### អត្តសញ្ញាណគ្រួសារ

ខេត្ត/ក្រុង: ..........................................................

ស្រុក/ខណ្ឌ: ..........................................................

សង្កាត់/ឃុំ: ..........................................................

ភូមិ: ..........................................................

ទីក្រុង/ជនបទ ( ទីក្រុង = ១; ជនបទ = ២ ): ☐

ឈ្មោះអ្នកសម្ភាសន៍ .................................... ID ....................................

ឈ្មោះ អ្នកត្រួតពិនិត្យ .................................... ហត្ថលេខា ....................................

# ប្រភេទគ្រួសារ

| Household members | |
|---|---|
| ក១. ចំនួនសមាជិកក្នុងគ្រួសារ | ☐☐ |

## កត្តាប្រជាសាស្ត្រ-សង្គមរបស់អ្នកតបសម្ភាសន៍

| | | |
|---|---|---|
| ក២. ភេទ | ១. ប្រុស ☐<br>២. ស្រី ☐<br>៣. ផ្សេងៗ................. ☐ | |
| ក៣. ថ្ងៃខែឆ្នាំកំណើត<br>(អ្នកសម្ភាសន៍បំពេញប្រអប់អាយុនៅពេលក្រោយ) | ខែ ☐☐<br>ឆ្នាំ ☐☐☐☐ អាយុ ☐☐ | |
| ក៤. កំរិតវប្បធម៌ | កំពុងសិក្សា | ឈប់រៀន |
| | ១. ទាបជាងបឋមសិក្សា | ១. មិនបានរៀន/ទាបជាងបឋមសិក្សា |
| | ២. បឋមសិក្សា – (ថ្នាក់ទី ១ – ៦) | ២. បឋមសិក្សា – (ថ្នាក់ទី ១ – ៦) |
| | ៣. អនុវិទ្យាល័យ – (ថ្នាក់ទី ៧-៩) | ៣. អនុវិទ្យាល័យ – (ថ្នាក់ទី ៧-៩) |
| | ៤. វិទ្យាល័យ – (ថ្នាក់ទី ១០ – ១២) | ៤. វិទ្យាល័យ – (ថ្នាក់ទី ១០ – ១២) |
| | ៥. សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥. សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | ៦. សាកលវិទ្យាល័យ និងកម្រិតខ្ពស់ជាងនេះ | ៦. សាកលវិទ្យាល័យ និងកម្រិតខ្ពស់ជាងនេះ |
| ក៥. ជនជាតិ<br>(ចម្លើយមានតែមួយគត់) | ១. ខ្មែរ ២. ចិន ៣. វៀតណាម ៤. ឡាវ<br>៥. ក្អួង ៦. ទំពួន ៧. ចារ៉ាយ ៨. គ្រឹង<br>៩. ស្ទួច ១០. សំរ៉ែ ១១. ព័រ ១២. កាវ៉ែត<br>១៣. កាចក់ ១៤. ស្អួយ ១៥. គួយ ១៦. ស្មៀង<br>១៧. ផ្សេងៗ.................................... | |
| ក៦. សាសនា (បើមាន)<br>(ចម្លើយមានតែមួយគត់) | ១. ព្រះពុទ្ធ ៣. អ៊ីស្លាម<br>២. គ្រឹស្ត ៤. ផ្សេងៗ.............................. | |

## កត្តាប្រជាសាស្ត្រ-សង្គមរបស់អ្នកតបសម្ភាសន៍ (continued)

| | |
|---|---|
| ក៧. ស្ថានភាពការងារ | ☐ ១. មិនមានការងារធ្វើ (សូមរម្លងទៅសំណួរក៩)<br>☐ ២. មានការងារធ្វើ<br>☐ ៣. ជនអសកម្មៈ មេផ្ទះ ឬ អ្នកក្នុងបន្ទុក (រស់នៅក្នុងគ្រួសារហើយពឹងផ្អែកលើចំណូលរបស់ឪពុកម្តាយ)<br>☐ ៤. កំពុងសិក្សា (សូមរម្លងទៅសំណួរក៩) |
| ក៨. បើមានការងារ តើកំពុងធ្វើការក្នុងវិស័យណា? | ☐ ១. វិស័យសាធារណៈ<br>☐ ២. វិស័យឯកជន (សហគ្រាសធន់តូច មធ្យម និងធំ)<br>☐ ៣. វិស័យមិនរកប្រាក់កម្រៃ<br>☐ ៤. វិស័យក្រៅផ្លូវការ<br>☐ ៥.ផ្សេងៗ |
| ក៩. មុខរបររបស់ឪពុក? | ☐ ១. វិស័យសាធារណៈ<br>☐ ២. វិស័យឯកជន (សហគ្រាសធន់តូច មធ្យម និងធំ)<br>☐ ៣. វិស័យមិនរកប្រាក់កម្រៃ<br>☐ ៤. វិស័យក្រៅផ្លូវការ<br>☐ ៥. មិនធ្វើការ<br>☐ ៦. ផ្សេងៗ................................... |

| កត្តាប្រជាសាស្ត្រ-សង្គមរបស់អ្នកតបសម្ភាសន៍ (continued) | |
|---|---|
| ក១០. មុខរបររបស់ម្ដាយ? | ☐ ១. វិស័យសាធារណៈ<br>☐ ២. វិស័យឯកជន (សហគ្រាសធន់តូច មធ្យម និងធំ)<br>☐ ៣. វិស័យមិនរកប្រាក់កម្រៃ<br>☐ ៤. វិស័យក្រៅផ្លូវការ<br>☐ ៥. មិនធ្វើការ<br>☐ ៦. ផ្សេងៗ.................................... |
| ក១១. តើអ្នកជាសកម្មជនក្រុមសង្គមស៊ីវិលឬទេ?<br><br>បើសិនជាសកម្មជន សូមបញ្ជាក់ឈ្មោះក្រុមការងារសង្គមស៊ីវិល (បើសិនជាសកម្មជនរបស់ក្រុមសង្គមស៊ីវិលច្រើន សូមបញ្ជាក់ពីក្រុមសង្គមស៊ីវិលដែលអ្នកឆ្លើយគិតថាជាក្រុមសំខាន់ជាងគេ) | ☐ ១. ជាសកម្មជន<br>☐ ២. មិនមែនជាសកម្មជន<br><br>បើសិនជាសកម្មជន សូមបញ្ជាក់<br><br>.............................................................................................. |

# ទស្សនៈ និងឥរិយាបថ

ខ្ញុំបាទ/នាងខ្ញុំនឹងអានអំណះអំណាងមួយចំនួនដូចខាងក្រោម។ សូមបង/ប្អូនកំណត់ថាតើទង្វើនេះត្រូវឬខុស ហើយទទួលយកបាន ឬមិនទទួលយកបាន តាមយោបល់បង/ប្អូនផ្ទាល់។

| តើអ្នកគិតយ៉ាងដូចម្ដេចចំពោះទង្វើដូចខាងក្រោម? | ខ១. តើទង្វើនេះខុសឬទេ? | ខ២. តើទង្វើនេះអាចទទួលយកបាន ឬទេ? |
|---|---|---|
| ក. បុគ្គលម្នាក់ប្រព្រឹត្តអំពើខុសច្បាប់ដើម្បីជីវភាពប្រចាំថ្ងៃរបស់ក្រុមគ្រួសារ | ១. ទង្វើខុស<br>២. មិនខុសទេ | ១. ទទួលយកបាន<br>២. មិនអាចទទួលយកបានទេ |
| ខ. អ្នកដឹកនាំម្នាក់ប្រព្រឹត្តអំពើខុសច្បាប់ដើម្បីជួយដល់ជីវភាពគ្រួសាររបស់អ្នកឲ្យប្រសើរ | ១. ទង្វើខុស<br>២. មិនខុសទេ | ១. ទទួលយកបាន<br>២. មិនអាចទទួលយកបានទេ |
| គ. មន្ត្រីរដ្ឋម្នាក់ទាមទារប្រាក់ក្រៅផ្លូវការ (បន្ថែម) សម្រាប់ សេវាកម្ម ឬនីតិវិធីរដ្ឋបាលដែលជាការងាររបស់មន្ត្រីរូបនោះ (ឧទាហរណ៍ ការធ្វើលិខិត ឬប័ណ្ណអនុញ្ញាតអ្វីមួយ) | ១. ទង្វើខុស<br>២. មិនខុសទេ | ១. ទទួលយកបាន<br>២. មិនអាចទទួលយកបានទេ |
| ឃ. បុគ្គលិកក្នុងអង្គភាពមួយបានផ្ដល់ការងារទៅឲ្យបងប្អូនរបស់ខ្លួនដែលមិនមានសមត្ថភាពគ្រប់គ្រាន់ (ធ្វើឲ្យអ្នកផ្សេងទៀតដែលមានសមត្ថភាពខ្ពស់ជាងមិនមានឱកាសទទួលបានការងារ) | ១. ទង្វើខុស<br>២. មិនខុសទេ | ១. ទទួលយកបាន<br>២. មិនអាចទទួលយកបានទេ |
| ង. បុគ្គលម្នាក់ផ្ដល់ប្រាក់បន្ថែម(ឬកាដូ)ទៅមន្ត្រីរាជការដើម្បីទទួលបានសេវាកម្មចុះផ្លាកលេខម៉ូតូ ឬឡានរហ័ស | ១. ទង្វើខុស<br>២. មិនខុសទេ | ១. ទទួលយកបាន<br>២. មិនអាចទទួលយកបានទេ |
| ច. បុគ្គលម្នាក់ផ្ដល់ប្រាក់ក្រៅផ្លូវការបន្ថែម(ឬកាដូ)ទៅអោយគ្រូពេទ្យដើម្បីទទួលបានការព្យាបាលល្អប្រសើរ | ១. ទង្វើខុស<br>២. មិនខុសទេ | ១. ទទួលយកបាន<br>២. មិនអាចទទួលយកបានទេ |
| ឆ. ឪពុកម្ដាយសិស្សម្នាក់ផ្ដល់ប្រាក់ក្រៅផ្លូវការ (ឬកាដូ) ទៅគ្រូបង្រៀនដើម្បីឲ្យគ្រូផ្ដល់ពិន្ទុ និងចំណាត់ថ្នាក់ល្អដល់កូនខ្លួន | ១. ទង្វើខុស<br>២. មិនខុសទេ | ១. ទទួលយកបាន<br>២. មិនអាចទទួលយកបានទេ |

ខ្ញុំបាទ/នាងខ្ញុំនឹងអានសំណួរមួយចំនួនដូចខាងក្រោម។ តាមយោបល់បង/ប្អូនផ្ទាល់ តើបង/ប្អូនយល់ស្រប ឬមិនយល់ស្រប?

| ១៣. តើអ្នកគិតថាមនុស្សដែលមានសុចរិតភាពគឺជាមនុស្សបែបណា: | |
|---|---|
| ក. មិនដែលនិយាយកុហក ឬបោកប្រាស់ និងដែលអាចទុកចិត្តបាន | ១.យល់ស្រប ២. មិនយល់ស្រប |
| ខ. មិននិយាយកុហក ឬបោកប្រាស់ លើកលែងតែនៅពេលដែលវាធ្វើឲ្យខាតបង់ប្រយោជន៍ដល់បុគ្គល/គ្រួសារបុគ្គលនោះ | ១.យល់ស្រប ២. មិនយល់ស្រប |
| គ. មិនប្រព្រឹត្តអំពើខុសច្បាប់ (គោរពបទបញ្ញត្តិ) ទោះក្នុងស្ថានភាពណាក៏ដោយ | ១.យល់ស្រប ២. មិនយល់ស្រប |
| ឃ. បង្ហាញពីសាមគ្គីភាព និងជួយគាំទ្រដល់ក្រុមគ្រួសារ និងមិត្តភក្តិគ្រប់ កាលៈទេសៈ ទោះបីជាត្រូវប្រព្រឹត្តអំពើល្មើសច្បាប់ក៏ដោយ | ១.យល់ស្រប ២. មិនយល់ស្រប |
| ង. មិនដែលប្រព្រឹត្តអំពើពុករលួយ (ដូចជាទទួលសំណូក ឬផ្តល់សំណូក) | ១.យល់ស្រប ២. មិនយល់ស្រប |
| ច. បដិសេធមិនចូលរួមប្រព្រឹត្តអំពើពុករលួយគ្រប់រូបភាព លើកលែងតែអំពើពុករលួយដែលមានលក្ខណៈនិងទ្រង់ទ្រាយតូច (ទឹកប្រាក់ ឬកាដូបន្តិចបន្តួច) | ១.យល់ស្រប ២. មិនយល់ស្រប |
| ឆ. បដិសេធមិនចូលរួមប្រព្រឹត្តអំពើពុករលួយ លើកលែងតែអំពើពុករលួយ ដែលមនុស្សគ្រប់គ្នាជាទូទៅប្រព្រឹត្តដើម្បីដោះស្រាយបញ្ហា ឬស្ថានការលំបាក | ១.យល់ស្រប ២. មិនយល់ស្រប |

កំណត់ចំណាំ: ការរស់នៅប្រចាំថ្ងៃសំដៅលើការរស់នៅក្នុងពេលធម្មតា (ដោយមិនគិតពីពេលមានសង្គ្រាមជាដើម) ។សំណួរនេះមានគោលបំណងវាស់ស្ទង់ការយល់ដឹងអំពីសុចរិតភាព ដើម្បីបង្កើតវិធីសាស្ត្រទូលំទូលាយមួយដោយមិនផ្អែកលើស្ថានភាពជាក់លាក់ណាមួយ ។ ស្ថានភាពជាក់លាក់ និងច្បាស់លាស់មានសួរនៅផ្នែកផ្សេងក្នុងកម្រងសំណួរ ។

## ការយល់ដឹង

* កំណត់ចំណាំ: មិនត្រូវអាន ឬផ្តល់ជម្រើសចម្លើយ "៨. មិនដឹង" ទៅអ្នកផ្តល់ចម្លើយឡើយ ។ ជម្រើសមួយនេះគួរជ្រើសយកក្នុងករណីដែលអ្នកផ្តល់ចម្លើយពិបាកឆ្លើយតែប៉ុណ្ណោះ ។

| ១៤. តើអ្នកគិតថាកង្វះសុចរិតភាព (រួមទាំងអំពើពុករលួយ) គឺជាបញ្ហាធំ (ផ្តល់ផលប៉ះពាល់ខ្លាំង) ចំពោះ.... ឬទេ? | |
|---|---|
| ក. យុវជនដូចជារូបអ្នកផ្ទាល់ | ១.បាទ/ចាស ២.អត់ទេ ៨. មិនដឹង* |
| ខ. គ្រួសារ និងមិត្តភក្តិ | ១.បាទ/ចាស ២.អត់ទេ ៨. មិនដឹង* |
| គ. ការអភិវឌ្ឍវិស័យឯកជន/សេដ្ឋកិច្ច | ១.បាទ/ចាស ២.អត់ទេ ៨. មិនដឹង* |
| ឃ.ការអភិវឌ្ឍប្រទេស | ១.បាទ/ចាស ២.អត់ទេ ៨. មិនដឹង* |

## គុណតម្លៃ និង ការយល់ឃើញ

* កំណត់ចំណាំ: អ្នកឆ្លើយសំណួរអាចរើសយកចម្លើយបានតែមួយគត់ ។ មិនត្រូវអាន ឬផ្តល់ជម្រើស "៨.មិនដឹង" ទៅអ្នកឆ្លើយសំណួរឡើយ។ ជម្រើសនេះគួរជ្រើសយកនៅក្នុងករណីដែលអ្នកឆ្លើយសំណួរពិបាកឆ្លើយប៉ុណ្ណោះ ។

ខ្ញុំបាទ/នាងខ្ញុំសូមអានអំណះអំណាងមួយចំនួនដូចខាងក្រោម។ សូមបង/ប្អូនធ្វើការឲ្យតម្លៃពី១ទៅ៤ ដែល ១ មានន័យថា មិនយល់ស្របទាល់តែសោះ, ២ មិនសូវយល់ស្រប, ៣ យល់ស្របខ្លះដែរ, និង ៤ យល់ស្របខ្លាំង។

| ៤៥. តាមយោបល់របស់អ្នក តើអ្នកយល់ស្របនឹងអំណះអំណាងខាងក្រោមនេះកម្រិតណា?<br>* កំណត់ចំណាំ: អ្នកឆ្លើយសំណួរអាចរើសយកចម្លើយបានតែមួយគត់ ។ មិនត្រូវអាន ឬផ្តល់ជម្រើស "៨. មិនដឹង" ទៅអ្នកឆ្លើយសំណួរឡើយ ។ ជម្រើសនេះគួរជ្រើសយកនៅក្នុងករណីដែលអ្នកឆ្លើយសំណួរពិបាកឆ្លើយប៉ុណ្ណោះ ។ | ចម្លើយ *<br>សូមធ្វើការឲ្យតម្លៃ ពី ១ ទៅ ៤ ដែល<br>១ = មិនយល់ស្របទាល់តែសោះ<br>២ = មិនសូវយល់ស្រប<br>៣ = យល់ស្របខ្លះដែរ<br>៤ = យល់ស្របខ្លាំង<br>៨* = មិនដឹង |
|---|---|
| ១. ការបង្កើនប្រាក់ចំណូលគ្រួសារមានសារៈសំខាន់ខ្លាំងណាស់ ហើយវាមិនខុសឆ្គងអ្វីទេបើសិនជាយើងមិនគោរពច្បាប់មួយចំនួន ឬប្រើប្រាស់អំណាចរបស់យើងដើម្បីសម្រេចបាននូវតម្រូវការរបស់ខ្លួន | ១ ២ ៣ ៤ ៨* |
| ២. ការបង្កើនប្រាក់ចំណូលគ្រួសារមានសារៈសំខាន់ជាងបន្តិចធៀបនឹងសេចក្តីស្មោះត្រង់ និងការគោរពច្បាប់ | ១ ២ ៣ ៤ ៨* |
| ៣. សេចក្តីស្មោះត្រង់ និងការគោរពច្បាប់បញ្ញត្តិមានសារៈសំខាន់ជាងការបង្កើនប្រាក់ចំណូលគ្រួសារ | ១ ២ ៣ ៤ ៨* |
| ៤. សេចក្តីស្មោះត្រង់ និងការគោរពច្បាប់បញ្ញត្តិមានសារៈសំខាន់ច្រើនជាងខ្លាំងណាស់ធៀបនឹងការបង្កើនប្រាក់ចំណូលគ្រួសារ | ១ ២ ៣ ៤ ៨* |

| ៤៦. តាមយោបល់អ្នក តើអ្នកយល់ស្រប ឬមិនយល់ស្របជាមួយនឹងអំណះអំណាងខាងក្រោមនេះកម្រិតណាដែរ?<br>* កំណត់ចំណាំ: អ្នកឆ្លើយសំណួរអាចរើសយកចម្លើយបានតែមួយគត់ ។មិនត្រូវអាន ឬផ្តល់ជម្រើស "៨*. មិនដឹង" ទៅអ្នកឆ្លើយសំណួរឡើយ ។ ជម្រើសនេះគួរជ្រើសយកនៅក្នុងករណីដែលអ្នកឆ្លើយសំណួរពិបាកឆ្លើយប៉ុណ្ណោះ ។<br>(អត្ថន័យនៃភាពជោគជ័យគឺអាស្រ័យទៅតាមការយល់ឃើញរបស់អ្នកឆ្លើយនីមួយៗ ដែលវាអាចមានន័យខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ ភាពជោគជ័យអាចមានន័យថា ការមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឬកេរ្តិ៍ឈ្មោះល្បីល្បាញ ឬការទទួលបានការគោរពសរសើរ ជាដើម ។) | ចម្លើយ *<br>សូមធ្វើការឲ្យតម្លៃ ពី ១ ទៅ ៤ ដែល<br>១ = មិនយល់ស្របទាល់តែសោះ<br>២ = មិនសូវយល់ស្រប<br>៣ = យល់ស្របខ្លះដែរ<br>៤ = យល់ស្របខ្លាំង<br>៨* = មិនដឹង |
|---|---|
| ១. មនុស្សដែលសុខចិត្តនិយាយកុហក បោកប្រាស់ ប្រព្រឹត្តបទល្មើស និងប្រព្រឹត្តអំពើពុករលួយ មានឱកាសជោគជ័យ**ច្រើនជាង**មនុស្សដែលមិនប្រព្រឹត្តទង្វើទាំងអស់នេះ | ១ ២ ៣ ៤ ៨* |
| ២. មនុស្សដែលសុខចិត្តនិយាយកុហក បោកប្រាស់ ប្រព្រឹត្តបទល្មើស និងប្រព្រឹត្តអំពើពុករលួយ មានឱកាសជោគជ័យ**ច្រើនជាងបន្តិច** ធៀបនឹងមនុស្សដែលមិនប្រព្រឹត្តទង្វើទាំងនេះ | ១ ២ ៣ ៤ ៨* |
| ៣. មនុស្ស**ដែលមិនសុខចិត្ត**និយាយកុហក បោកប្រាស់ ប្រព្រឹត្តបទល្មើស និងប្រព្រឹត្តអំពើពុករលួយ មានឱកាសជោគជ័យច្រើនជាងបន្តិចធៀបនឹងមនុស្សដែលប្រព្រឹត្តទង្វើទាំងនេះ | ១ ២ ៣ ៤ ៨* |
| ៤. មនុស្ស**ដែលមិនសុខចិត្ត**និយាយកុហក បោកប្រាស់ ប្រព្រឹត្តបទល្មើស និងប្រព្រឹត្តអំពើពុករលួយ មានឱកាសជោគជ័យច្រើនខ្លាំងជាងមនុស្សដែលប្រព្រឹត្តទង្វើទាំងនេះ | ១ ២ ៣ ៤ ៨* |

## បទពិសោធន៍លំបាក(ដែលធ្លាប់ឆ្លងកាត់)ទាក់ទងនឹងសុចរិតភាព

* កំណត់ចំណាំៈ អ្នកឆ្លើយសំណួរត្រូវជ្រើសរើសយកចម្លើយតែមួយគត់ក្នុងចំណោមចម្លើយទាំង ៣ ហើយមិនអាចឆ្លើយថា "មិនដឹង" ទេ

| ២៧. តើអ្នកផ្ទាល់ធ្លាប់ជួបប្រទះអំពើពុករលួយក្នុងអំឡុងពេល ១២ខែកន្លងមកនេះដែរឬទេក្នុងការទទួលបានសេវាខាងក្រោមៈ (សូមឆ្លើយតាមការយល់ឃើញរបស់អ្នកអំពីអំពើពុករលួយ) | |
|---|---|
| ក. ស្នើសុំឯកសារ ឬអាជ្ញាប័ណ្ណ?(ឧទាហរណ៍៖ សំបុត្រកំណើត, អត្តសញ្ញាណបណ្ណ, សំបុត្រអាពាហ៍ពិពាហ៍) | ១.បាទ/ចាស ២.ទេ<br>៣. មិនធ្លាប់បានពាក់ព័ន្ធនឹងរឿងនេះទេ |
| ខ. ប្រឡង (ចូលរៀន) នៅសាលា? | ១.បាទ/ចាស ២.ទេ<br>៣. មិនធ្លាប់បានពាក់ព័ន្ធនឹងរឿងនេះទេ |
| គ. ទទួលបានការព្យាបាលដល់គ្រួសារ ឬខ្លួនអ្នក នៅមណ្ឌលសុខភាព? | ១.បាទ/ចាស ២.ទេ<br>៣. មិនធ្លាប់បានពាក់ព័ន្ធនឹងរឿងនេះទេ |
| ឃ. បញ្ចៀសបញ្ហាជាមួយប៉ូលីស (ដូចជាការផាកពិន័យ) | ១.បាទ/ចាស ២.ទេ<br>៣. មិនធ្លាប់បានពាក់ព័ន្ធនឹងរឿងនេះទេ |
| ង. ទទួលបានការងារ | ១.បាទ/ចាស ២.ទេ<br>៣. មិនធ្លាប់បានពាក់ព័ន្ធនឹងរឿងនេះទេ |
| ច. ទទួលបានអតិថិជនច្រើន ឬ ពង្រីកទីផ្សារ សម្រាប់ក្រុមហ៊ុន/សហគ្រាសរបស់អ្នក | ១.បាទ/ចាស ២.ទេ<br>៣. មិនធ្លាប់បានពាក់ព័ន្ធនឹងរឿងនេះទេ |

## យោបល់ចំពោះកម្រិតសុចរិតភាព

| ២៨. តាមយោបល់អ្នក តើបច្ចុប្បន្នកម្រិតនៃសុចរិតភាពនៅក្នុងសេវាកម្មដែលផ្តល់ដោយស្ថាប័នដូចខាងក្រោមនេះមានលក្ខណៈយ៉ាងដូចម្តេចដែរ?<br>សូមបញ្ចេញយោបល់របស់អ្នកផ្អែកទៅតាមបទពិសោធន៍ ឬទស្សនៈរបស់អ្នកផ្ទាល់។<br><br>* កំណត់ចំណាំៈ ជម្រើស "៨. មិនដឹង" មិនត្រូវអាន ឬផ្តល់ទៅអ្នកឆ្លើយសំណួរឡើយ ។ ជម្រើសនេះគួរជ្រើសយកនៅក្នុងករណីដែលអ្នកឆ្លើយសំណួរពិបាកឆ្លើយតែប៉ុណ្ណោះ ។ | ១. មិនល្អទាល់តែសោះ (អំពើពុករលួយ និងទង្វើមិនត្រឹមត្រូវមានលក្ខណៈសុះសាយ)<br>២. មិនសូវល្អ (មានករណីមិនត្រឹមត្រូវ និងអំពើពុករលួយច្រើន)<br>៣. ល្អគួរសម (មានករណីមិនត្រឹមត្រូវ និងពុករលួយមួយចំនួនខ្លះដែរ)<br>៤. ល្អណាស់ (មានតម្លាភាព, គ្មានអំពើ ពុករលួយ, គ្មានការប្រព្រឹត្តមិនត្រឹមត្រូវ)<br>៨. មិនដឹង* |
|---|---|
| | គូសលេខដែលជាចម្លើយរបស់អ្នកឆ្លើយ |
| ក. រដ្ឋបាលថ្នាក់ជាតិ | ១ ២ ៣ ៤ ៨* |
| ខ. រដ្ឋបាលថ្នាក់មូលដ្ឋាន | ១ ២ ៣ ៤ ៨* |
| គ. ស្ថាប័នប៉ូលីស | ១ ២ ៣ ៤ ៨* |
| ឃ. វិស័យអប់រំរបស់រដ្ឋ (សាលានិងសាកលវិទ្យាល័យ) | ១ ២ ៣ ៤ ៨* |
| ង. វិស័យអប់រំឯកជន (សាលានិងសាកលវិទ្យាល័យ) | ១ ២ ៣ ៤ ៨* |
| ច. ស្ថាប័នសុខភាពរដ្ឋ | ១ ២ ៣ ៤ ៨* |
| ឆ. ស្ថាប័នសុខភាពឯកជន | ១ ២ ៣ ៤ ៨* |
| ជ. អាជីវកម្មរបស់រដ្ឋ | ១ ២ ៣ ៤ ៨* |
| ឈ. អាជីវកម្មឯកជន | ១ ២ ៣ ៤ ៨* |

## អាកប្បកិរិយាដែលបង្ហាញពីសុចរិតភាព

* កំណត់ចំណាំ: អ្នកឆ្លើយសំណួរត្រូវជ្រើសរើសយកចម្លើយតែមួយគត់ក្នុងចំណោមចម្លើយទាំង ៣ ហើយមិនអាចឆ្លើយថា "មិនដឹង" នោះទេ ។ បើសិនជាអ្នកឆ្លើយសំណួរឆ្លើយថា "វាអាស្រ័យ/វាមិនទៀង", អ្នកសួរសំណួរគួរព្យាយាមសួរដេញបន្ថែម (តែមិនត្រូវសួរសំណួរធ្ងន់ធ្ងរពាក់ព័ន្ធនឹងអាយុជីវិត) ដើម្បីស្វែងយល់ពីអាកប្បកិរិយារបស់អ្នកឆ្លើយ ។

ខ្ញុំបាទ/នាងខ្ញុំនឹងអានស្ថានភាពមួយចំនួនដូចខាងក្រោម។ យើងនឹងមានជម្រើសមួយចំនួនដើម្បីឲ្យបង/ប្អូនជ្រើសរើស។ តើបង/ប្អូនជ្រើសរើសយកមួយណា?

| | |
|---|---|
| ខ៩. អ្នកត្រូវប្រឡងឲ្យបានពិន្ទុល្អដើម្បីប្រឡងជាប់និងរកបានការងារល្អ (វាជាដំណាក់កាលដ៏សំខាន់មួយសម្រាប់អនាគតអ្នក និងក្រុមគ្រួសារអ្នក) | ១. អ្នកនឹងព្យាយាមឲ្យអស់ពីសមត្ថភាពខ្លួន ហើយនឹងមិនលួចចម្លងជាដាច់ខាតបើទោះបីជាអ្នកដឹងថានឹងធ្វើមិនបានពិន្ទុល្អក៏ដោយ<br>២. អ្នកនឹងសុំឲ្យមិត្តជិតស្និទ្ធរបស់អ្នកជួយ ហើយមិត្តរបស់អ្នកនឹងយល់ព្រមជួយពីព្រោះវាគឺជារឿងធម្មតា<br>៣. អ្នកនឹងធ្វើអ្វីគ្រប់យ៉ាង រួមទាំងលួចចម្លង និង/ឬសូកសំណូកដល់គ្រូ/អ្នកដែលជួយអ្នក |

* កំណត់ចំណាំ: អ្នកឆ្លើយសំណួរត្រូវជ្រើសរើសយកចម្លើយតែមួយគត់ក្នុងចំណោមចម្លើយទាំង ៤ ហើយមិនអាចឆ្លើយថា "មិនដឹង" នោះទេ ។ បើសិនជាអ្នកឆ្លើយសំណួរឆ្លើយថា "វាអាស្រ័យ/វាមិនទៀង", អ្នកសួរសំណួរគួរព្យាយាមសួរដេញ (តែមិនត្រូវសួរសំណួរធ្ងន់ធ្ងរពាក់ព័ន្ធនឹងអាយុជីវិត) ដើម្បីស្វែងយល់ពីអាកប្បកិរិយារបស់អ្នកឆ្លើយ ។

| | |
|---|---|
| ខ១០. តើអ្នកនឹងធ្វើយ៉ាងម៉េចបើសិនជាអ្នកត្រូវការធ្វើឯកសារ (ឧទាហរណ៍: ប័ណ្ណបើកបរ) ហើយអ្នកដែលទទួលបន្ទុកធ្វើឯកសារនេះប្រាប់ថាពិបាកនឹងធ្វើឯកសារ ហើយត្រូវការរយៈពេលច្រើនសប្តាហ៍ (ច្រើនខែ) | ១. អ្នកនឹងរង់ចាំ<br>២. អ្នកនឹងសួរឲ្យច្បាស់ពីរយៈពេលដែលត្រូវការ ហើយសាកសួរពីដំណើរការធ្វើឯកសារដើម្បីឲ្យដឹងពីមូលហេតុ<br>៣. អ្នកនឹងរកមិត្តភក្តិ/បងប្អូនដែលអាចជួយសម្រួលនិងត់ការដើម្បីឲ្យដំណើរការធ្វើឯកសារលឿន<br>៤. អ្នកនឹងចំណាយប្រាក់បន្ថែម (ក្រៅផ្លូវការ) ដើម្បីទទួលបានឯកសារឆាប់ |

* កំណត់ចំណាំ: អ្នកឆ្លើយសំណួរត្រូវជ្រើសរើសចម្លើយតែមួយគត់ក្នុងចំណោមជម្រើសទាំង ៤ ហើយមិនអាចឆ្លើយថា "មិនដឹង" ឡើយ ។

| | |
|---|---|
| ខ១១. ឧបមាថា ពូរបស់អ្នកប្រាប់ថាគាត់មានមិត្តល្អម្នាក់ដែលអាចជួយឲ្យអ្នកចូលរៀននៅសាលា/សាកលវិទ្យាល័យ ឬចូលធ្វើការក្នុងក្រុមហ៊ុនដ៏ល្អមួយយ៉ាងងាយស្រួល ដោយមិនចាំបាច់ឆ្លងកាត់ដំណាក់ជ្រើសរើស ។ តើអ្នកនឹងឆ្លើយទៅកាន់ពូអ្នកយ៉ាងដូចម្តេច? | ១. អ្នកនឹងឆ្លើយថា "ទេ" ភ្លាម ។ អ្នកមិនចង់ប្រព្រឹត្តអំពើប្រភេទនេះឡើយ<br>២. អ្នកស្ទាក់ស្ទើរយ៉ាងយូរ ហើយសម្រេចចិត្តបដិសេធដោយលើកយកហេតុផលដោះសារដើម្បីកុំឲ្យពូរបស់អ្នកអន់ចិត្ត<br>៣. អ្នកមានអារម្មណ៍មិនសូវស្រួល ប៉ុន្តែអ្នកនៅតែយល់ព្រម ពីព្រោះមនុស្សគ្រប់រូបសុទ្ធតែធ្វើអញ្ចឹងដូចគ្នា<br>៤. អ្នកនឹងនិយាយថាល្អណាស់ ហើយយល់ព្រមភ្លាមមួយរំពេច |

* កំណត់ចំណាំៈ អ្នកឆ្លើយសំណួរត្រូវជ្រើសរើសចម្លើយតែមួយគត់ក្នុងចំណោមជម្រើសទាំង ៣ ហើយមិនអាចឆ្លើយថា "មិនដឹង" ឡើយ ។

| | |
|---|---|
| ខ១២. ឧបមាថាអ្នកកំពុងដាក់ពាក្យធ្វើការងារនៅសហគ្រាស(កន្លែងធ្វើការ) មួយដែលផ្តល់នូវអ្វីដែលអ្នកចង់បាន ។ ដើម្បីបានការងារនោះ អ្នកដែលសម្ភាសអ្នកទាមទារ ១០-២០%នៃប្រាក់ខែរបស់អ្នក ។ តើអ្នកនឹងមានប្រតិកម្មយ៉ាងដូចម្តេច? | ១. អ្នកនឹងបដិសេធភ្លាម ហើយសម្រេចចិត្តបំភ្លេចការងារនោះចោល<br>២. អ្នកស្ទាក់ស្ទើរ ។ បន្ទាប់ពីគិតគូររួច អ្នកក៏សម្រេចចិត្តយល់ព្រម ប៉ុន្តែអ្នកនឹងព្យាយាមកែប្រែទម្លាប់ប្រភេទនេះបន្ទាប់ពីអ្នកបានក្លាយជាសមាជិកសហគ្រាស<br>៣. អ្នកយល់ស្របពីព្រោះវាគឺជាវិធីតែមួយគត់ដើម្បីបានការងារនោះ ។ |

## កម្រិតនៃការប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងអំពើពុករលួយ

* កំណត់ចំណាំៈ អ្នកឆ្លើយសំណួរត្រូវជ្រើសរើសចម្លើយតែមួយគត់ក្នុងចំណោមជម្រើសទាំង ៤ ហើយមិនអាចឆ្លើយថា "មិនដឹង" ឡើយ ។

| | |
|---|---|
| ខ១៣. បើសិនជាអ្នកប្រឈមមុខនឹងអំពើពុករលួយ (ឧទាហរណ៍ គ្រូបង្រៀន/សាស្ត្រាចារ្យរបស់អ្នកទាមទារប្រាក់ពីអ្នកដើម្បីឲ្យអ្នកប្រឡងជាប់) តើអ្នកនឹងរាយការណ៍ករណីពុករលួយនេះឬទេ? | ១. បាទ/ចាស ខ្ញុំក៏ធ្លាប់បានរាយការណ៍ករណីពុករលួយពីមុនដែរ(បើឆ្លើយបាទ/ចាស រម្លងទៅសួរសំនួរខ១៥)<br>២. បាទ/ចាស ខ្ញុំនឹងរាយការណ៍(បើឆ្លើយបាទ/ចាស រម្លងទៅសួរសំនួរខ១៥)<br>៣. មិនជានិច្ច កាលទេ ខ្ញុំរាយការណ៍អាស្រ័យលើប្រភេទនៃករណីពុករលួយតែប៉ុណ្ណោះ<br>៤. ទេ ខ្ញុំមិនរាយការណ៍ទេ |

* កំណត់ចំណាំៈ អ្នកឆ្លើយសំណួរអាចជ្រើសរើសចម្លើយបានតែមួយគត់ក្នុងចំណោមជម្រើសទាំង ៤ ហើយមិនអាចឆ្លើយថា "មិនដឹង" ឡើយ ។

| | |
|---|---|
| ខ១៤. បើសិនជាអ្នកមិនរាយការណ៍ តើមកពីមូលហេតុអ្វី? (សំណួរនេះសម្រាប់សួរអ្នកឆ្លើយសំណួរខ១៣ ដែលបានឆ្លើយថា មិនរាយការណ៍ ឬ មិនជានិច្ចកាល)<br>(ជម្រើសទី ៣ ឬ ទី៤ ក្នុងសំណួរ ខ១៣) | ១. ខ្ញុំខ្លាច ពីព្រោះខ្ញុំមិនទទួលបានការការពារបន្ទាប់ពីរាយការណ៍ហើយ<br>២. ខ្ញុំគិតថាការរាយការណ៍មិនមានប្រសិទ្ធភាព (ព្រោះគ្មានលទ្ធផលឬដំណោះស្រាយ)<br>៣. ខ្ញុំមិនដឹងពីនីតិវិធីក្នុងការរាយការណ៍<br>៤. ខ្ញុំមិនចង់រាយការណ៍ពីព្រោះវាមិនមែនជាកិច្ចការរបស់ខ្ញុំ |

## ព័ត៌មាន និងឥទ្ធិពលពីមជ្ឈដ្ឋាន

* កំណត់ចំណាំៈ អ្នកឆ្លើយសំណួរអាចជ្រើសរើសចម្លើយបានតែមួយគត់ក្នុងចំណោមជម្រើសទាំង ៤ ហើយមិនអាចឆ្លើយថា "មិនដឹង" ទេ ។

| | |
|---|---|
| ខ១៥. តើអ្នកដឹងច្រើនប៉ុណ្ណាអំពីច្បាប់និងបទបញ្ញត្តិរបស់រដ្ឋាភិបាលស្តីពីការលើកស្ទួយសុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ? | ១. មិនទទួលបានព័ត៌មាន<br>២. ដឹងបន្តិចបន្តួច<br>៣. ដឹងខ្លះៗ<br>៤. ដឹងច្រើន |

| ៦១៦. យើងចង់ដឹងពីទស្សនៈ/ការយល់ឃើញរបស់អ្នកខ្លះ អំពីសុចរិតភាព។ តើអ្នកគិតថា.... | ផ្តល់ព័ត៌មាននិងសារដើម្បីលើកស្ទួយសុចរិតភាពដែរឬទេ ? |
|---|---|
| ក. ក្រុមគ្រួសាររបស់អ្នក | ១. ផ្តល់ ២. មិនផ្តល់ទេ |
| ខ. ប្រព័ន្ធអប់រំ/សាលារបស់អ្នក | ១. ផ្តល់ ២. មិនផ្តល់ទេ |
| គ. មិត្តភក្តិដែលមានវ័យស្របាលគ្នា | ១. ផ្តល់ ២. មិនផ្តល់ទេ |
| ឃ. តារាល្បីៗ | ១. ផ្តល់ ២. មិនផ្តល់ទេ |
| ង. ក្រុមអ្នក អាជីវករ /សេដ្ឋកិច្ច | ១. ផ្តល់ ២. មិនផ្តល់ទេ |
| ច. អ្នកដឹកនាំ ( នយោបាយ ឬសាសនាជាដើម ) | ១. ផ្តល់ ២. មិនផ្តល់ទេ |
| ឆ. ប្រព័ន្ធផ្សព្វផ្សាយជាទូទៅ | ១. ផ្តល់ ២. មិនផ្តល់ទេ |
| ជ. វិទ្យុ | ១. ផ្តល់ ២. មិនផ្តល់ទេ |
| ឈ. ទូរទស្សន៍ | ១. ផ្តល់ ២. មិនផ្តល់ទេ |
| ញ. កាសែត | ១. ផ្តល់ ២. មិនផ្តល់ទេ<br>៣. មិនដែលអានកាសែតទេ |
| ដ. ព័ត៌មានតាមអ៊ិនធឺណែត | ១. ផ្តល់ ២. មិនផ្តល់ទេ<br>៣. មិនដែលប្រើប្រាស់អ៊ិនធើណែតទេ |
| ឋ. បណ្តាញសង្គម( ហ្វេសប៊ុក, ធ្វិតធឺរ... ) | ១. ផ្តល់ ២. មិនផ្តល់ទេ<br>៣. មិនដែលប្រើប្រាស់បណ្តាញសង្គមទេ |

| ៦១៧. យើងចង់ដឹងពីទស្សនៈ/ការយល់ឃើញរបស់អ្នកខ្លះ អំពីសុចរិតភាព។ តើអ្នកគិតថា.... | បង្ហាញពីគំរូល្អៗអំពីសុចរិតភាព ដែរឬទេ ? |
|---|---|
| ក. ក្រុមគ្រួសាររបស់អ្នក | ១. បាទ/ចាស ២. ទេ |
| ខ. ប្រព័ន្ធអប់រំ/សាលារបស់អ្នក | ១. បាទ/ចាស ២. ទេ |
| គ. មិត្តភក្តិដែលមានវ័យស្របាលគ្នា | ១. បាទ/ចាស ២. ទេ |
| ឃ. តារាល្បី | ១. បាទ/ចាស ២. ទេ |
| ង. ក្រុមអ្នក អាជីវករ /សេដ្ឋកិច្ច | ១. បាទ/ចាស ២. ទេ |
| ច. អ្នកដឹកនាំ ( នយោបាយ ឬសាសនាជាដើម ) | ១. បាទ/ចាស ២. ទេ |
| ឆ. ប្រព័ន្ធផ្សព្វផ្សាយជាទូទៅ | ១.បាទ/ចាស ២. ទេ |
| ជ. វិទ្យុ | ១. បាទ/ចាស ២. ទេ |
| ឈ. ទូរទស្សន៍ | ១. បាទ/ចាស ២. ទេ |
| ញ. កាសែត | ១. បាទ/ចាស ២. ទេ<br>៣. មិនដែលអានកាសែតទេ |
| ដ. ព័ត៌មានតាមអ៊ិនធឺណែត | ១. បាទ/ចាស ២. ទេ<br>៣. មិនដែលប្រើប្រាស់អ៊ិនធើណែតទេ |
| ឋ. បណ្តាញសង្គម( ហ្វេសប៊ុក, ធ្វិតធឺរ... ) | ១. បាទ/ចាស ២. ទេ<br>៣. មិនដែលប្រើប្រាស់បណ្តាញសង្គមទេ |

| ខ១៨. យើងចង់ដឹងពីទស្សនៈ/ការយល់ឃើញរបស់អ្នកខ្លះ អំពីសុចរិតភាព។ តើអ្នកគិតថា... | មានឥទ្ធិពលទៅលើការយល់ឃើញរបស់អ្នកអំពីសុចរិតភាពដែរឬទេ? |
|---|---|
| ក. ក្រុមគ្រួសាររបស់អ្នក | ១. មាន ២. មិនមានទេ |
| ខ. ប្រព័ន្ធអប់រំ/សាលារបស់អ្នក | ១. មាន ២. មិនមានទេ |
| គ. មិត្តភក្តិដែលមានវ័យស្របាលគ្នា | ១. មាន ២. មិនមានទេ |
| ឃ. តារាល្បី | ១. មាន ២. មិនមានទេ |
| ង. ក្រុមអ្នក អាជីវករ /សេដ្ឋកិច្ច | ១. មាន ២. មិនមានទេ |
| ច. អ្នកដឹកនាំ (នយោបាយ ឬសាសនាជាដើម) | ១. មាន ២. មិនមានទេ |
| ឆ. ប្រព័ន្ធផ្សព្វផ្សាយជាទូទៅ | ១. មាន ២. មិនមានទេ |
| ជ. វិទ្យុ | ១. មាន ២. មិនមានទេ |
| ឈ. ទូរទស្សន៍ | ១. មាន ២. មិនមានទេ |
| ញ. កាសែត | ១. មាន ២. មិនមានទេ<br>៣. មិនដែលអានកាសែតទេ |
| ដ. ព័ត៌មានតាមអ៊ិនធឺណែត | ១. មាន ២. មិនមានទេ<br>៣. មិនដែលប្រើប្រាស់អ៊ិនធើណែតទេ |
| ឋ. បណ្ដាញសង្គម(ហ្វេសប៊ុក, ធ្វិតធឺរ...) | ១. មាន ២. មិនមានទេ<br>៣. មិនដែលប្រើប្រាស់បណ្ដាញសង្គមទេ |

## តួនាទីយុវជនក្នុងការលើកស្ទួយសុចរិតភាពនិងប្រឆាំងអំពើពុករលួយ

* កំណត់ចំណាំ: អ្នកឆ្លើយសំណួរអាចជ្រើសរើសចម្លើយបានតែមួយគត់ ។ មិនត្រូវអាន ឬផ្តល់ជម្រើស "៤.មិនដឹង" ទៅអ្នកឆ្លើយសំណួរឡើយ។ ជម្រើសនេះគួរជ្រើសយកនៅក្នុងករណីដែលអ្នកឆ្លើយសំណួរ ពិបាកឆ្លើយប៉ុណ្ណោះ ។

| ខ១៩. តាមយោបល់របស់អ្នក តើយុវជនមានតួនាទីសំខាន់ប៉ុណ្ណាក្នុងការលើកស្ទួយសុចរិតភាពនៅក្នុងប្រទេស/សង្គម? (សូមជ្រើសយកចម្លើយដែលអ្នកយល់ស្របខ្លាំងជាងគេ) | ចម្លើយ * |
|---|---|
| ១. យុវជនគ្មានតួនាទីក្នុងការលើកស្ទួយសុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយទេ (គេមិនខ្វល់ពីយោបល់របស់យុវជនឡើយ) | ១ |
| ២. យុវជនមានតួនាទីតិចតួចក្នុងការលើកស្ទួយសុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ (តាមរយៈការតស៊ូមតិ និងការកែប្រែឥរិយាបថ) | ២ |
| ៣. យុវជនមានតួនាទីសំខាន់ណាស់ក្នុងការលើកស្ទួយសុចរិតភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ (តាមរយៈការតស៊ូមតិ និងការកែប្រែឥរិយាបថ) | ៣ |
| ៤. មិនដឹង | ៨* |

| | |
|---|---|
| ខ២០. តើអ្នកធ្លាប់ទទួលបានការអប់រំ ឬកម្មវិធីសិក្សាជាក់លាក់ណាមួយអំពីសុចរិតភាព ឬការប្រឆាំងអំពើពុករលួយ ឬទេ? | ១. បាទ/ចាស<br>២. ទេ (បើឆ្លើយទេ សូមរម្លងទៅសំណួរគ១) |
| បើសិនជាធ្លាប់, តាមយោបល់របស់អ្នក: | |
| ក. ការអប់រំ/កម្មវិធីអប់រំនេះរៀបចំដោយអ្នកណា?<br>(ចម្លើយអាចមានលើសពីមួយ) | ☐ ១. គ្រឹះស្ថានអប់រំ<br>☐ ២. អង្គការសង្គមស៊ីវិល<br>☐ ៣. អាជ្ញាធរមូលដ្ឋាន<br>☐ ៤. អង្គភាពប្រឆាំងអំពើពុករលួយ<br>☐ ៥. ផ្សេងៗ.................................. |
| ខ. ការអប់រំ/កម្មវិធីអប់រំនេះបានជួយអ្នកឲ្យយល់ដឹងពីសុចរិតភាព (និងអំពើពុករលួយ) ដែរឬទេ? | ☐ ១. បាទ/ចាស ប្រាកដណាស់<br>☐ ២. បាទ/ចាស ប៉ុន្តែមិនទាន់គ្រប់គ្រាន់ទេ<br>☐ ៣. ទេ |
| គ. ការអប់រំ/កម្មវិធីអប់រំនេះបានធ្វើឲ្យអ្នកចូលរួមនិងដើរតួជាអ្នកលើកស្ទួយសុចរិតភាពក្នុងសង្គម/ប្រទេសដែរឬទេ? | ☐ ១. បាទ/ចាស ប្រាកដណាស់<br>☐ ២. បាទ/ចាស ប៉ុន្តែមិនទាន់គ្រប់គ្រាន់ទេ<br>☐ ៣. ទេ |

# សំណួរលម្អិតសម្រាប់ត្រួតពិនិត្យគោលការណ៍/កម្មវិធីជាក់លាក់

| គ. ស្ថានភាពជីវភាព | |
|---|---|
| គ១. ទ្រព្យសម្បត្តិ ( ឧបករណ៍និងសម្ភារៈ )<br>( វាយតម្លៃដោយផ្អែកលើភាពជាក់ស្តែង )<br>តើអ្នកមាន<br>ក. ប្រភពទឹកប្រើប្រាស់<br>ខ. អគ្គិសនីប្រើប្រាស់ក្នុងផ្ទះ<br>គ. វិទ្យុ<br>ឃ. ទូរស័ព្ទ<br>ង. កង់<br>ច. ម៉ូតូ<br>ឆ. ទូរទស្សន៍<br>ជ. អ៊ិនធើណែតប្រើប្រាស់ | ក. មាន.......១ មិនមាន ......២<br>ខ. មាន.......១ មិនមាន ......២<br>គ. មាន.......១ មិនមាន ......២<br>ឃ. មាន.......១ មិនមាន ......២<br>ង. មាន.......១ មិនមាន ......២<br>ច. មាន.......១ មិនមាន ......២<br>ឆ. មាន.......១ មិនមាន ......២<br>ជ. មាន.......១ មិនមាន ......២ |
| គ២. បើគិតពីប្រាក់ចំណូលរបស់គ្រួសារអ្នក តើអ្នកគិតថាអ្នករស់នៅក្នុងស្ថានភាពដូចម្តេច ?<br>( សូមអានចម្លើយ។ អ្នកឆ្លើយត្រូវវាយតម្លៃដោយខ្លួនឯង ) | លំបាក ............................................ ១<br>ធម្មតាប៉ុន្តែមានការគិតគូរច្រើន................ ២<br>ធម្មតា............................................... ៣<br>បានសុខស្រួល.................................... ៤ |
| **សុខុមាលភាពរបស់អ្នកតបសម្ភាសន៍** | |
| គ៣. ជារួម តើអ្នកសប្បាយចិត្តនឹងជីវិតរបស់អ្នកឬទេ ?<br>តើអ្នកអាចនិយាយបានថាអ្នកៈ | ☐ មិនសប្បាយចិត្តទាល់តែសោះ ............... ១<br>☐ មិនសូវសប្បាយចិត្ត ............................ ២<br>☐ ធម្មតា ............................................... ៣<br>☐ សប្បាយចិត្តគួរសម ............................ ៤<br>☐ សប្បាយចិត្តណាស់ ............................. ៥ |

| លទ្ធភាពទទួលបានព័ត៌មាន: តើអ្នកទទួលបានព័ត៌មានពីប្រភពខាងក្រោមនេះញឹកញាប់ប៉ុណ្ណាដែរ? (នៅពេលធម្មតា ដែលមិនមានបុណ្យទាន) | |
|---|---|
| គ៤. វិទ្យុ | ☐ មិនដែលសោះ ............ ១<br>☐ តិចជាងមួយដងក្នុងមួយខែ ............ ២<br>☐ ២ឬ៣ដងក្នុងមួយខែ ............ ៣<br>☐ ២ឬ៣ដងក្នុងមួយសប្ដាហ៍ ............ ៤<br>☐ រៀងរាល់ថ្ងៃ ............ ៥ |
| គ៥. ទូរទស្សន៍ | ☐ មិនដែលសោះ ............ ១<br>☐ តិចជាងមួយដងក្នុងមួយខែ ............ ២<br>☐ ២ឬ៣ដងក្នុងមួយខែ ............ ៣<br>☐ ២ឬ៣ដងក្នុងមួយសប្ដាហ៍ ............ ៤<br>☐ រៀងរាល់ថ្ងៃ ............ ៥ |
| គ៦. កាសែត | ☐ មិនដែលសោះ ............ ១<br>☐ តិចជាងមួយដងក្នុងមួយខែ ............ ២<br>☐ ២ឬ៣ដងក្នុងមួយខែ ............ ៣<br>☐ ២ឬ៣ដងក្នុងមួយសប្ដាហ៍ ............ ៤<br>☐ រៀងរាល់ថ្ងៃ ............ ៥ |
| គ៧. អ៊ិនធឺណែត | ☐ មិនដែលសោះ ............ ១<br>☐ តិចជាងមួយដងក្នុងមួយខែ ............ ២<br>☐ ២ឬ៣ដងក្នុងមួយខែ ............ ៣<br>☐ ២ឬ៣ដងក្នុងមួយសប្ដាហ៍ ............ ៤<br>☐ រៀងរាល់ថ្ងៃ ............ ៥ |
| ឧបករណ៍សម្រាប់ទំនាក់ទំនង | |
| គ៨. តើប្រភពផ្តល់ព័ត៌មាន ៣ប្រភេទចម្បងណាខ្លះដែរអ្នកប្រើប្រាស់ដើម្បីទទួលព័ត៌មាន ឬទំនាក់ទំនង (វិទ្យុ ទូរទស្សន៍, កាសែត ក្ដារប្រកាសព័ត៌មាន តាមរយៈមេភូមិ មិត្តភក្តិ និងក្រុមគ្រួសារ អ៊ិនធឺណែត សារទូរស័ព្ទ ជាដើម)<br><br>• កំណត់ចំណាំសម្រាប់អ្នកសួរសំណួរ: អ្នកឆ្លើយសំណួរអាចឆ្លើយពីប្រភពទទួលបានព័ត៌មានផ្សេងទៀត បើសិនជាពាក់ព័ន្ធ ប៉ុន្តែអ្នកសួរសំណួរមិនត្រូវផ្តល់ជម្រើសផ្សេងទៀតដល់អ្នកឆ្លើយឡើយ ។ | ______________ ☐☐<br>______________ ☐☐<br>______________ ☐☐<br><br>(សូមអ្នកសួរសំណួរសរសេរចម្លើយ) |

| សំណួរសម្ភាសន៍ | |
|---|---|
| គ៩. តើអ្នកគិតយ៉ាងណាដែរចំពោះកម្រងសំណួរសម្ភាសន៍នេះ ? | ☐ ពិបាកឆ្លើយខ្លាំង ............................ ១<br>☐ ពិបាកឆ្លើយ .................................. ២<br>☐ មិនសូវងាយស្រួល .......................... ៣<br>(មានសំណួរខ្លះពិបាកឆ្លើយ)<br>☐ ងាយស្រួលឆ្លើយ ........................... ៤ |

*ការសង្កេតរបស់អ្នកធ្វើសម្ភាសន៍ (មិនត្រូវសួរទៅអ្នកតបសម្ភាសន៍ទេ)

អ្នកតបសម្ភាសន៍ឆ្លើយដោយ

ក. យកចិត្តទុកដាក់ខ្លាំង

ខ. យកចិត្តទុកដាក់បង្គួរ

គ. មិនសូវយកចិត្តទុកដាក់

នៅកម្ពុជា ៦៥ភាគរយនៃប្រជាជន មានអាយុក្រោម ៣០ឆ្នាំ ហើយជាង ៣០ ភាគរយនៃពលរដ្ឋត្រូវបាន គេចាត់ទុកថាជាយុវជន។ ដើម្បីសម្រេចបានជោគជ័យក្នុងការលើកកម្ពស់សុចរិតភាព និងទប់ស្កាត់អំពើពុករលួយ ការធ្វើការជាមួយយុវជនឲ្យបានកាន់តែច្រើន គឺជារឿងមួយដែលចាំបាច់។ ការស្ទង់មតិយុវជនស្តីពីសុចរិតភាពនេះ ធ្វើឡើងដើម្បីស្វែងយល់និងប៉ាន់ប្រមាណ ឥរិយាបថ និងការយល់ឃើញអំពីសុចរិតភាព និងអំពើពុករលួយក្នុងចំណោមក្រុមប្រជាជនដ៏សំខាន់នេះ។ ការស្ទង់មតិតាមរូបភាពតំណាងថ្នាក់ជាតិ លើកដំបូងគេនៅប្រទេសកម្ពុជានេះ បានសម្ភាសយុវជន ១២០០នាក់ អាយុពី ១៥ ដល់៣០ឆ្នាំ នៅទូទាំងប្រទេស។លទ្ធផលនៃការអង្កេតនេះអាចផ្តល់នូវភស្តុតាងនិងទិន្នន័យសម្រាប់អង្គភាពរដ្ឋាភិបាល និងអង្គការនានា ដែលមានបំណងស្វែងយល់ឲ្យកាន់តែស៊ីជម្រៅអំពីយុវជន និងដើម្បីកំណត់វិស័យសំខាន់ៗ សម្រាប់តម្រង់ទិសកិច្ចផ្តួចផ្តើមសកម្មភាពប្រឆាំងអំពើពុករលួយ។